ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយជំនឿខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ៣៤ លេខ ១ ខែ មករា

ព.ស. ២៥០៤ គ.ស. ១៩៦២

- ភ្នំពេញ -

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ
ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកសាសនា* — ទំព័រ


— វិចារណកថា . . . . . . . . . . . . . . ១
— លោកុត្តរភិសម័យ (ត) អ្នកឧកញ៉ា ទា-សាទ អតីតរដ្ឋមន្ត្រីរៀបរៀង . . . . . ៦
— ព្រះអភិធម្មបិដក (គម្ពីរព្រះយមកៈ) (ត) លោកប៊ូ-ប៉ូ ប្រែរៀបរៀង . . . . . . ១៤
— មធុរសវាហិណី(ត)សម្ដេចព្រះធម្មលិខិតល្វី-ឯម ប្រែ ព្រះញាណកោសលញ-ឈឹនពិនិត្យ ២៤
— មហោសថជាតក(ត)លោក អ៊ឹម-ភន ចម្លងពីសាស្ត្រាស្លឹករឹតព្រះពុទ្ធវង្ស កឹម-គួរ ពិនិត្យ ៣០
— អំពីទង់ពុទ្ធសាសនា លោក ថង-វង រៀបរៀង . . . . . . . . . . ៣៨


*ផ្នែកអក្សរសាស្ត្រ*


— វប្បធម៌ខ្មែរ (ត) លោក លី-ធាមតេង រៀបរៀង . . . . . . . . . . ៤២
— ពាក្យខ្មែរប្រែចេញពីបរទេស (ត) ដោយគណៈកម្មការវប្បធម៌ . . . . . . . ៤៣
— វចនានុក្រមសំស្ក្រឹត-ខ្មែរ (ត) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . . ៤៨
— រឿងសាមកុក (ត) ឧកញ៉ា នូ កន ប្រែ . . . . . . . . . . . ៤៩
— រឿងព្រេងចិន (ត) លោក ភិយ ប៉ុក ប្រែរៀបរៀង . . . . . . . . . ៦២
- ភូមិសាស្ត្រសេដ្ឋកិច្ចអាហ្វ្រិកខាងត្បូង លោក ញ៉ែម-ទិម ប្រែ . . . . . . ៧៧


*ផ្នែកកំណត់និងប្រវត្តិការណ៍*


- អនុសំវច្ឆរមហាសន្និបាតនៃមន្ត្រីសង្ឃលើក ទី ១៨ លោក ថង-វង រៀបរៀង . . ៨៦


មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជារ ២៣០រ៰០

34è Année — N° 1 — Janvier 1962

# KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire publiée par l'Institut-Bouddhique de Phnom-Penh

## SOMMAIRE

**Partie religieuse** page


— Editorial . . . . . . . . . . . . . . . . . . . . . . . 1
— Lokkuttara Bhisamaya par l'Oknha TEA-SAN (suite) . 6
— Prah Abhidhamma pitaka (Kampi prah Yamaka) (suite) par M. BOU-PO . . . . . . . . . . . 14
— Madhurasavahini (suite) traduit par Samdech Prah Dhammalikhita LOUIS-EM, revu et corrigé par Vén NHEAN-CHHOEUN . . . . . . . . . . 24
— Mahosatha Jataka (suite) relevé du manuscrit sur feuilles de latanier par M. IM-PHON, revu et corrigé par Vén. KEM-TO . . . . . . . . . . . 30
— Le drapeau bouddhique par M. THANG-VONG . . . . 38


**Partie Littéraire**


— La culture khmère (suite) par M. LY-THEAM-TENG . . 42
— Activités de la Commission culturelle (suite) . . . . 47
— Dictionnaire Sanscrit-Khmèr (suite) par Vén. PANG-KHAT . . . . . . . . . . . . . 48
— Histoire de Sam-Kok (suite) traduite par l'Oknha NOU-KAN . . . . . . . . . . . . . . . . 49
— Légendes populaires de la Chine par M. RAY-BUC . . 62
— Géographie économique de l'Afrique du Sud traduite par M. NHEM-KHEM . . . . . . . . 77


**Notes et Chroniques**


— 18ème Réunion annuelle des Dignitaires religieux par M. THANG-VONG . . . . . . . . . . . 86


Abonnement annuel (comprenant 12 numéros) : 230 f 00

## ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការលាមក ឲ្យធ្វើល្អទៅ ។
ឲ្យដុសខាត់ចិត្ត កុំឲ្យហ្មងសៅ
នេះឯងលោកហៅ ពុទ្ធសាសនា ។

ប.ព.

## វិចារណកថា

# ពួកពុទ្ធបរិស័ទ សូមរួបរួមសាមគ្គីគ្នា
# ដើម្បីញុំាងព្រះពុទ្ធសាសនា ឲ្យលូតលាស់ចំរើន

---

ព្រះពុទ្ធបរមគ្រូ មុននឹងបរិនិព្វានទៅ ព្រះអង្គទ្រង់បានផ្តាំពុទ្ធបរិស័ទទាំង ៤ ពួកគឺ ភិក្ខុ-ភិក្ខុនី-ឧបាសក-ឧបាសិកាថា ព្រះពុទ្ធសាសនាដែលនឹងចំរើនរុងរឿងបាន ឬ វិនាសសាបសូន្យទៅវិញនោះ អាស្រ័យមកអំពីពុទ្ធបរិស័ទចេះរួបរួមគ្នា ឬមិនចេះរួបរួមគ្នាគោរពប្រតិបត្តិតាមព្រះបរមពុទ្ធោវាទ ដែលព្រះអង្គបានត្រាស់សំដែងទុក ដែលចែកចេញជាធម្មក្ខន្ធមាន ៨ ម៉ឺន ៤ ពាន់ព្រះធម្មក្ខន្ធ ដូចពុទ្ធបរិស័ទបានជ្រាបបានចេះដឹងមកគ្រប់សព្វអស់ហើយ ។

នៅប្រទេសកម្ពុជាយើងនេះ ប្រជាពលរដ្ឋខ្មែរសុទ្ធតែកាន់ព្រះពុទ្ធ-

សាសនាស្ទើរតែទាំងអស់ ទាំងច្បាប់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រ ក៏បានតំកល់ទុកព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ ហើយពុទ្ធបរិស័ទគ្រប់ជាន់ថ្នាក់ បាននាំគ្នាគោរពប្រតិបត្តិមកអស់កាលជាច្រើនសតវត្សរ៍ណាស់មកហើយផង ។ ពួកពុទ្ធបរិស័ទនាសម័យបច្ចុប្បន្ននេះ ទាំងបព្វជិត-ទាំងគ្រហស្ថភាគច្រើនណាស់ ដែលបានខំប្រឹងប្រែងរៀនសូត្រតាមព្រះពុទ្ធឱវាទនេះ ដើម្បីនឹងបានជាប្រទីបធ្លុះបំភ្លឺមើលច្បាប់ខុសត្រូវ ដែលខ្លួនត្រូវប្រតិបត្តិឲ្យបានហ្មត់ចត់ ។

តាមការសង្កេតរបស់ក្រសួងធម្មការឃើញថា សព្វថ្ងៃនេះមានពួកពុទ្ធបរិស័ទខ្លះ មិនព្រមរួបរួមសាមគ្គីគ្នា ដើម្បីញាំងព្រះពុទ្ធសាសនាឲ្យរីកចំរើនរុងរឿងឡើយ ។ ច្រើនតែនាំគ្នាប្រតិបត្តិដោយកាន់ច្រឡំ ប្រកាន់អស្មិមានះ យកហេតុបន្តិចបន្តួចមកជាលេស នាំបង្កឲ្យទៅជាអធិករណ៍ធំដុំឡើង នាំប្រកាន់ថា ពួកគេ ពួកយើង ហើយកើតរឿងប្តឹងផ្តល់ពីគ្នាឯង ដែលជាពុទ្ធបរិស័ទដើរវត្តជាមួយគ្នា រកទីបំផុតចប់មិនឃើញ ។ ទោះបីរាជការមុខក្រសួងសម្របសម្រួលឲ្យរួបរួមគ្នាយ៉ាងណាក៏ដោយ នៅតែមិនព្រមទទួលរួបរួមគ្នាជាដាច់ខាត ប្រកាន់យកត្រូវតែតាមបក្សពួករៀងៗខ្លួន ។ ការមិនរួបរួមសាមគ្គីគ្នាបែបនេះ នាំឲ្យ

ពុទ្ធបរិស័ទចំណុះជើងវត្តនោះ ទទួលផលអាក្រក់ច្រើនប្រការជាអាទិ៍គឺ:

– នាំឲ្យជាកទាបសាបរលាប បើផ្ទឹមទៅនឹងពុទ្ធបរិស័ទចំណុះជើងវត្តឯទៀត ដែលគេមានសាមគ្គីធម៌រួបរួមគ្នា ។

– ធ្វើបុណ្យទានម្ដង ៗ មិនបានរុងរឿងល្អ ឬអាក់ខានធ្វើមិនកើតផងក៏មាន ដោយបណ្ដាលមកពីបក្សពួកជំទាស់គ្នាទៅវិញទៅមក ។

– នាំឲ្យបង់ខាតប្រាក់កាស ខាតពេលធ្វើរបររកស៊ីដោយសារតែទាស់ទែងវង្វេងគំនិតមិនស្របយោបល់គ្នា ប្ដឹងផ្ដល់គ្នា ។

– កុដិ . វិហារ . សាលា ដែលមានហើយចេះតែបាក់បែក ចាស់ទ្រុឌទ្រោមគ្រាំគ្រា ដែលមិនទាន់មាន ក៏ចេះតែគ្មានរហូតទៅជាលំដាប់ ព្រោះឪកាសមិនបើកឲ្យជួសជុល-ឲ្យស្ថាបនាឡើងកើត ។

– គ្រហស្ថ-បព្វជិត ដែលត្រូវការសិក្សាព្រះបរិយត្តិធម៌ ព្រះពុទ្ធវចនៈរបស់ព្រះពុទ្ធបរមគ្រូ ដើម្បីឲ្យបានចេះដឹងជ្រៅជ្រះនោះ ក៏អាក់ខានរកពេលរៀនសូត្រមិនកើត ព្រោះខ្វះការសប្បាយទាំង៤យ៉ាងគឺ: សេនាសនសប្បាយ, ធម្មសប្បាយ, បុគ្គលសប្បាយ នឹងអាហារសប្បាយ ។ ម្ល៉ោះហើយបព្វជិត-គ្រហស្ថ អ្នកសិក្សារៀនសូត្រ ក៏រាត់រយាត់បាកការរៀនសូត្រអស់ មកខំប្រឹងរៀនឯការចាក់រុកបុកម្ដេញគ្នា ខំប្រឹងប្ដឹងផ្ដល់

ពីគ្នាយកឈ្នះចាញ់ ដែលជាអំពើឥតប្រយោជន៍ឯណេះវិញ ។

– កាលបើកុដិ - សាលា - វិហារ - សាលារៀនមិនគ្រប់គ្រាន់ហើយ គម្ពីរដីកា ក្បួនខ្នាតខាងព្រះពុទ្ធសាសនា នឹងអ្នកចេះដឹងនូវព្រះពុទ្ធវចនៈជ្រៅជ្រះក៏មិនមានជាប្រាកដ ។ កាលបើគ្មានអ្នកចេះដឹងព្រះពុទ្ធវចនៈ គឺព្រះពុទ្ធសាសនាដែលជាទ្រព្យរបស់ព្រះពុទ្ធបរមគ្រូហើយ , ព្រះពុទ្ធសាសនានឹងវិនាសសាបសូន្យទៅឯង មិនអាចឋិតថេរចីរកាលដរាបដល់ ៥០០០ ព្រះវស្សាបានឡើយ ហើយគេអាចចាត់ទុកពុទ្ធបរិស័ទពួកក្រុមនោះថា ជាអ្នកញ៉ាំងព្រះពុទ្ធសាសនាឲ្យចូលក្នុងផ្លូវវិនាសសាបរលាបមិនឲ្យលូតលាស់ចំរើនឡើងបាន ។

## ពុទ្ធបរិស័ទនាំផ្សាយ !

ផលអាក្រក់ដែលបណ្ដាលមកពីការបែកសាមគ្គី ដូចបានរៀបរាប់សង្ខេបមកខាងលើនេះ យើងជាអ្នកកាន់ព្រះពុទ្ធសាសនាគួរត្រិះរិះពិចារណាឲ្យហ្មត់ចត់ គួរកុំប្រកាន់គ្នា កុំឈ្លោះទាស់ទែងគ្នារវាងពុទ្ធបរិស័ទគ្នាឯង ព្រោះសេចក្ដីប្រតិបត្តិឃ្លាងគ្នាបន្តិចបន្តួច គប្បីតែអត់សង្កត់សន្ដោសគ្នា យោគយល់គ្នាទៅវិញទៅមកជាដរាប ដើម្បីបណ្ដុះសាមគ្គីធម៌ឲ្យកើតមានឡើង ។ កាលបើសេចក្ដីសាមគ្គី គឺការព្រមព្រៀងគ្នាកើតមាន

ហើយ កិច្ចការគ្រប់ជំពូកក្នុងវត្តអារាម ក៏ចេះតែមានសកម្មភាពប្រព្រឹត្តទៅជាលំដាប់ ៗ កាលបើកិច្ចគ្រប់ជំពូកក្នុងវត្តអារាមបានចំរើនហើយ ព្រះពុទ្ធសាសនាក៏នឹងបានចំរើនលូតលាស់ជាលំដាប់ទៅដែរ ៗ អាយុកាលនៃព្រះពុទ្ធសាសនា ក៏មានដំណើរឋិតថេរចីរកាលរហូតដល់ប្រាំពាន់ព្រះវស្សា ឬច្រើនលើសពីនេះទៅទៀតពុំខានឡើយ ៗ

ក្រសួងធម្មការ មានសេចក្តីសង្ឃឹមយ៉ាងមាំថា ពុទ្ធបរិស័ទនឹងចេះពិចារណារកការខុសត្រូវ ហើយចេះរួបរួមព្រមគ្នាថែរក្សាព្រះពុទ្ធសាសនា ឲ្យបានរឹងរឹតតែចំរើនរុងរឿង លែងមានអធិករណ៍រវាងព្រះសង្ឃនឹងព្រះសង្ឃ, ព្រះសង្ឃនឹងឧបាសក-សិកា ឬឧបាសក-សិកា នឹងឧបាសក-សិកាដូចគ្នាតទៅទៀតមិនខាន ៗ

លោកុត្តភិសម័យ

## ភាគទី ៤

អ្នកឧកញ៉ា ងា-សាង អតីតរដ្ឋមន្ត្រី រៀបរៀង

(គតិៈលេខ ១១ ឆ្នាំ ១៩៦១)

---

# ការត្រាស់ដឹងមគ្គ ៤ ផល ៤ និងនិព្វាន

ព្រះអនាគាមីអង្គនោះ កាលបើបានដឹងច្បាស់នូវអរូបភពនោះហើយ ក៏រំពឹងពិចារណាគិតឃើញថា អរូបភពនេះ ក៏មិនមែនជាភពប្រកបដោយបរមសុខ គួរឲ្យមានចិត្តប្រាថ្នាទៅកើតស្ងាប់នោះទេ បើដូច្នេះឃើញថា មានតែអរហត្តមគ្គ និងអរហត្តផលនោះទេ ដែលអាចនាំមកនូវបរមសុខ គឺសុខយ៉ាងសុខុមក្រៃលែងពោលគឺនិព្វាននោះបាន ។

កាលបើព្រះអនាគាមី រំពឹងគិតឃើញយ៉ាងដូច្នេះហើយ លោកក៏ដំកល់ចិត្តឲ្យតាំងនៅជាកណ្តាលធ្វើព្រងើយកន្តើយ មិនអើពើចំពោះអរូបរាគៈ មានះ ឧទ្ធច្ចៈ ឲ្យបានរឿយ ៗ លុះត្រាតែខន្ធសន្តានរីងហួតស្ងួតចាក ឧទ្ធម្ភាគិយទាំង ៣ នោះអស់ទៅ ដែលជាហេតុនឹងនាំព្រះអនាគាមីឲ្យលះសំយោជនៈបាន ៩ នៅសល់តែអវិជ្ជា ១ ទៀតទេ ។

អាស្រ័យហេតុនេះ ទើបព្រះអនាគាមីចំរើនអាកិញ្ចញ្ញាយតនជ្ឈាន ដែលមានវត្ថុយ៉ាងល្អិតក្រៃលែង ស្ទើរតែមិនមានវត្ថុជាអារម្មណ៍រៀងកប

ដកប លុះត្រាតែបានសម្រេចនូវអរូបជ្ឈានចិត្តទី ៣ ដូចមានលក្ខណៈតទៅនេះ ។

៣ - រីឯអរូបជ្ឈានចិត្តទី ៣ ដែលសម្រេចកើតមានឡើងនេះ ជាអរូបជ្ឈានចិត្តប្រព្រឹត្តទៅកាន់នត្ថិនិមិត្ត គឺនិមិត្តជាគ្រឿងសំគាល់នូវសភាពដែលគ្មានអ្វីបន្តិចបន្តួចសោះ ពោលគឺកាន់សភាពដែលគ្មានអ្វីសំគាល់ថាជាសំយោជនៈ ដែលជាហេតុនឹងញ៉ាំងព្រះអនាគាមីឲ្យលះអវិជ្ជាគឺសេចក្ដីល្ងង់ដែលជាសម្ផ្ទាននៃសំយោជនៈ ៩ ខាងដើមនោះ ដាច់ស្រឡះដោយសមុច្ឆេទប្បហានទៅខណៈនោះទៅ ។

ដោយអានុភាពនៃការលះអវិជ្ជាដាច់ស្រឡះ ដោយសមុច្ឆេទប្បហាន, ព្រះអនាគាមីក៏បានសម្រេចនូវបញ្ញាវិសុទ្ធិ គឺសេចក្ដីបរិសុទ្ធនៃបញ្ញានៅខណៈនោះជាលំដាប់ទៀត ។

បន្ទាប់អំពីនោះ ព្រះអនាគាមីត្រូវចំរើននេវសញ្ញានាសញ្ញាយតនជ្ឈានដែលមានសញ្ញាយ៉ាងល្អិតក្រៃលែង ស្ទើរតែមិនមានសញ្ញាជាអារម្មណ៍ឲ្យបានរឿយ ។ ដកបលុះត្រាតែបានសម្រេចនូវអរូបជ្ឈានចិត្តទី ៤ ដូចមានលក្ខណៈតទៅនេះ ។

៤ – រីឯអរូបជ្ឈានចិត្តទី ៤ ដែលសម្រេចកើតមានឡើងនេះ ជាអរូបជ្ឈានចិត្តប្រព្រឹត្តទៅកាន់សុញ្ញានិមិត្ត គឺនិមិត្តជាគ្រឿងសំគាល់នូវ

សភាពដែលសូន្យទទេគ្មានអ្វីសោះ ពោលគឺសូន្យគ្មានសំយោជនៈ ដែលជាហេតុនាំឲ្យព្រះអនាគាមីបានសម្រេចនូវវិមុត្តិវិសុទ្ធិ គឺសេចក្ដីបរិសុទ្ធនៃការរួចចាកសំយោជនៈដោយនិស្សរណវិមុត្តិ គឺរួចចាកដោយការរលាស់ចេញផុតទៅអស់ហើយ ។

ដោយអានុភាពនៃការសម្រេចនូវបញ្ញាវិសុទ្ធិ និងវិមុត្តិវិសុទ្ធិ ព្រះអនាគាមីក៏បានត្រាស់ដឹងនូវអរហត្តមគ្គ គឺមគ្គចិត្តទី ៤ ដែលលះសំយោជនៈ ១០ ដាច់ស្រឡះដោយសមុច្ឆេទប្បហាន និងបានសម្រេចនូវអរហត្តផល គឺផលចិត្តទី ៤ ដែលរួចចាកសំយោជនៈ ១០ ដោយនិស្សរណវិមុត្តិ, បានឡើងឋានៈជាព្រះអរហន្ត គឺជាអរិយបុគ្គលដែលឆ្ងាយចាកកិលេស និងជាអរិយបុគ្គល ដែលបានទៅដល់ដំណាក់ចុងបំផុតនៃផ្លូវ ដែលនាំដំណើរឆ្ពោះទៅកាន់និព្វាន គឺបរមសុខនោះ ។

ឯមគ្គចិត្តទី ៤ និងផលចិត្តទី ៤ នេះ គឺជាចិត្តតាំងនៅក្នុងសុខមាលសុខរួចផុតស្រឡះចាកកំដៅភ្លើងកិលេស គឺភ្លើងរាគៈ ទោសៈ និងមោហៈ ដែលនាំទទួលរងសេចក្ដីក្ដៅក្រហល់ក្រហាយ, សេចក្ដីអន្ទះអន្ទែងនិងសេចក្ដីស្រេកឃ្លានចង់ស្រេបស្រាលត្រេកត្រអាល ក្នុងវត្ថុសង្ខារទៀតហើយ ដែលជាហេតុនាំឲ្យព្រះអរហន្តអាចដោះខ្លួនឲ្យរួចផុតពីតណ្ហា ៣ ប្រការ ។

សរុបសេចក្ដីទៅឃើញថា ព្រះអរហន្តអង្គនេះ ទ្រង់និងបានត្រាស់

ដឹងអរហត្តមគ្គ នឹងអរហត្តផល ត្រូវខំព្យាយាមបំពេញគុណធម៌ផ្សេងៗ រៀងតាមលំដាប់ដូចតទៅនេះ៖

១- បានចំរើនបរិកម្មាសិណ ដែលជាហេតុនាំឲ្យលោកបានសម្រេចអប្បនាសមាធិ ។

២- បានចំរើនវិបស្សនាភាវនា ដែលជាហេតុនាំឲ្យលោកលះសំ-យោជនៈ ៣ គឺសក្កាយទិដ្ឋិ, វិចិកិច្ឆា, សីលព្វតបរាមាស នឹងនាំឲ្យបានសម្រេចវិសុទ្ធិ គឺសេចក្ដីបរិសុទ្ធិ ៤ ប្រការ មានទិដ្ឋិវិសុទ្ធិជាដើម ដើម្បីត្រាស់ដឹងសោតាបត្តិមគ្គ នឹងសោតាបត្តិផល ។

៣- បានចំរើនបឋមជ្ឈាន នឹងទុតិយជ្ឈាន ដែលជាហេតុនាំឲ្យលោកលះអង្គវិតក្កៈ នឹងវិចារៈ នឹងនាំឲ្យវចីសង្ខារនិរោធ គឺរលត់អស់ទៅដើម្បីត្រាស់ដឹងសកទាគាមិមគ្គ នឹងសកទាគាមិផល ។

៤- បានចំរើនតតិយជ្ឈាន នឹងចតុត្ថជ្ឈាន ដែលជាហេតុនាំឲ្យលោកលះកាមរាគៈ បដិឃៈ នឹងនាំឲ្យបានសម្រេចចិត្តវិសុទ្ធិ គឺសេចក្ដីបរិសុទ្ធិនៃចិត្ត ដើម្បីត្រាស់ដឹងអនាគាមិមគ្គ នឹង អនាគាមិផល ។

៥ · បានចំរើនរូបជ្ឈាន ៤ ដែលជាហេតុនាំឲ្យលោកលះឧទ្ធម្ភាគិយ-សំយោជនៈ ៥ នឹងនាំឲ្យលោកបានសម្រេចបញ្ញាវិសុទ្ធិ នឹងវិមុត្តិវិសុទ្ធិ ដើម្បីត្រាស់ដឹងអរហត្តមគ្គ នឹងអរហត្តផល ។

ម្យ៉ាងវិញទៀត ដោយកម្លាំងអានុភាពនៃការសម្រេចនូវរូបជ្ឈាន ៤ នឹងអរូបជ្ឈាន ៤ នោះ ព្រះអរហន្តត្រូវបានសម្រេចនូវអភិញ្ញា ៦ ទៀត គឺ ឥទ្ធិវិធិ ចេះសម្តែងឫទ្ធិផ្សេងៗ មានចេះទៅមកតាមផ្លូវអាកាសជាដើម ១, ទិព្វសោតៈ គឺមានត្រចៀកទិព្វ ១, ចេតោបរិយញ្ញាណ ចេះកំណត់ដឹងចិត្តអ្នកដទៃ ១, បុព្វេនិវាសានុស្សតិ ចេះរលឹកនឹកឃើញជាតិពីអតីតកាល ១, ទិព្វចក្ខុ គឺមានភ្នែកទិព្វ ១ , និងអាសវក្ខយញាណ ចេះធ្វើអាសវៈឲ្យអស់ ១ ។

រីឯអភិញ្ញា ៦ នេះ គឺជាវិជ្ជា ៦ ដែលមានរាយឈ្មោះក្នុងបណ្ដាវិជ្ជា ៨ នោះឯង ។

## ៥- ការត្រាស់ដឹងលោកុត្តរធម៌ទី ៩ គឺនិព្វាន

ឯនិព្វាន គឺបរមសុខមាន ២ ប្រការគឺ៖

ឧបាទិសេសនិព្វាន គឺបរមសុខរួចផុតចាកភ្លើងកិលេស១,

អនុបាទិសេសនិព្វាន គឺបរមសុខរួចផុតចាកភ្លើងទុក្ខ ១ ។

មានតែព្រះអរហន្តដែលបានសម្រេចមគ្គ ៤ នឹងផល ៤ រួចស្រេចហើយនោះទេ ដែលអាចនឹងត្រាស់ដឹងនូវនិព្វានទាំង ២ ប្រការនោះបាន តែប៉ុន្តែឧបាទិសេសនិព្វាន ជាសច្ឆិកាតព្វធម៌ គឺធម៌ដែលព្រះអរហន្តគប្បីធ្វើឲ្យជាក់ច្បាស់ប្រាកដឡើង ទើបអាចនឹងត្រាស់ដឹង នូវឧបាទិសេស-

និព្វាន គឺបរមសុខរួចផុតចាកកំដៅភ្លើងកិលេសនោះបាន ។

ដើម្បីនឹងបំពេញករណីយកិច្ចនេះ ព្រះអរហន្តអង្គនោះ ក៏ស្និទ្ធស្នាល ចំរើនអនុបស្សនា ៣ ប្រការគឺ សុញ្ញតានុបស្សនា, អនិមិត្តានុបស្សនា, និង អប្បណិហិតានុបស្សនា ដើម្បីពិចារណាបញ្ជាក់ឲ្យដឹង តើអរហត្តផល គឺផលចិត្ត ដែលទើបនឹងរួចចាកសំយោជនៈ ១០ នោះ បានតាំងសិប់ នៅកន្លងវិមោក្ខ គឺកន្លងការរួចចាកកិលេស ៣ ប្រការហើយឬនៅ ? ។

កាលបើព្រះអរហន្តអង្គនោះបានពិចារណា សង្កេតដឹងច្បាស់ដោយ វិមុត្តិញាណទស្សនៈ អរហត្តផលនោះ បានតាំងនៅសិប់កន្លងវិមោក្ខ ៣ ប្រការគឺ:

– សុញ្ញតវិមោក្ខ គឺការរួចផុតចាកកិលេស ព្រោះសូន្យគ្មាន កិលេសសោះ ១,

– អនិមិត្តវិមោក្ខ គឺការរួចផុតចាកកិលេស ព្រោះគ្មានអ្វីជា គ្រឿងសំគាល់ថាកិលេសសោះ ១,

– អប្បណិហិតវិមោក្ខ គឺការរួចចាកកិលេស ព្រោះគ្មានអ្វី ជាទីតាំងនៅនៃកិលេសសោះ ១,

ពិតប្រាកដកាលណាហើយ គឺនៅខណៈនោះហើយដែលគប្បីសន្និ- ដ្ឋានថា ព្រះអរហន្តអង្គនោះបានធ្វើនិព្វានសច្ឆិកិរិយា ពោលគឺបានធ្វើ

កិរិយាជាក់ច្បាស់នៃនិព្វានឲ្យកើតមានប្រាកដឡើងហើយ ពីព្រោះវិមោក្ខ ៣ ប្រការនោះ ជាគ្រឿងសំគាល់ថា ភ្លើងកិលេសរលត់អស់ពីខន្ធសន្តានទៅហើយ ។ គឺនៅខណៈជាមួយគ្នានោះហើយ ដែលព្រះអរហន្តអង្គនោះបានត្រាស់ដឹងឧបាទិសេសនិព្វាន គឺបរមសុខ រួចចាកភ្លើងកិលេសនោះឯង ។

ចាប់តាំងពីពេលដែលព្រះអរហន្តអង្គនោះ បានសម្រេចនិព្វានគឺបរមសុខក្នុងបច្ចុប្បន្នកាលណាហើយ ព្រះអរហន្តអង្គនោះ ត្រូវបានទទួលនាមថ្មី២ទៀតគឺ នាមជាព្រះខីណាស្រព គឺជាអ្នកអស់អាសវៈហើយ និងនាមជាព្រះអសេក្ខៈ គឺជាអ្នកអស់ការសិក្សា ពោលគឺគ្មានអ្វីត្រូវលះ ឬត្រូវបំពេញតទៅទៀតឡើយ ។

ក៏ប៉ុន្តែ ព្រះខីណាស្រពពុំបានគង់សម្រាកនៅស្ងៀមទំនេរជាដរាបដែរ ដូនកាលគេឃើញព្រះខីណាស្រពអង្គនោះ គង់ក្នែនសម្ងំនៅស្ងៀមព្រងើយហាក់ដូចកំពុងស្ងឹងស្ងាត់មិនដឹងខ្លួនអ្វីសោះ ។

ត្រង់ឥរិយាបថនេះ គេអាចសំគាល់ដឹងថា ព្រះខីណាស្រពកំពុងបណ្តែតអារម្មណ៍ ពោលគឺបណ្តែតអរហត្តផលឲ្យដំកល់នៅក្នុងវិមោក្ខ ៣ ប្រការដែលជាហេតុនាំឲ្យព្រះអង្គអាចតាំងនៅក្នុងចិត្តសង្ខារ និងកាយ-សង្ខារនិរោធ គឺក្នុងកិរិយារលត់នៃសញ្ញានិងវេទនា ព្រមទាំងខ្យល់ដកដង្ហើមចេញចូលអស់រយៈពេលជាច្រើនថ្ងៃទើបភ្ញាក់ដឹងខ្លួនឡើងវិញ ។

ចំពោះឥរិយាបថដ៏ចម្លែកនេះ គប្បីសំគាល់ថា ព្រះអរហន្តអង្គនោះ កំពុងចូលកាន់និរោធសមាបត្តិ ។

វចនានុក្រម ត្រង់ពាក្យនិរោធសមាបត្តិប្រាប់ថា ព្រះអរហន្តអាចស្ថិតនៅក្នុងនិរោធសមាបត្តិ យ៉ាងយូរបានត្រឹមតែ ៧ ថ្ងៃទេ ។

បើសង្កេតតាមដំណើរហេតុដូចមានខាងលើនេះ គេអាចដឹងថាគឺវិមោក្ខ ៣ ដែលព្រះអរហន្តបានត្រាស់អរហត្តផល គឺផលចិត្តទី ២ ឲ្យជ្រកធ្វើជាវិហារសមាបត្តិ សម្ងំនៅជាបរមសុខនោះហើយ ដែលហៅថានិរោធសមាបត្តិ ពីព្រោះក្រៅពីវិមោក្ខ ៣ ប្រការនោះ ពុំមានអារម្មណ៍ឯណាដទៃទៀត ដែលអាចឲ្យអរហត្តផលចិត្តប្រកបដោយបរមសុខធ្វើជាវិហារសមាបត្តិជ្រកសម្ងំនៅបានឡើយ ។

ព្រះអរហន្តអង្គនោះ រមែងតែចូលកាន់និរោធសមាបត្តិដូច្នេះ ជារឿយ ៗ នៅក្នុងចន្លោះពេលទំនេររៀងរាល់ដល់អាយុក្ស័យមកដល់វេលាណា ទើបលោកលែងអាយុសង្ខារចូលកាន់អនុបាទិសេសនិព្វាន គឺបរម-សុខដែលរួចផុតស្រឡះចាកទាំងក្លើងកិលេសទាំងក្លើងទុក្ខ ហើយដែលជាហេតុនាំឲ្យព្រះអរហន្តអង្គនោះ បានសម្រេចនូវអវសានជាតិ គឺជាតិជាទីបំផុតក្រោយបំផុត ទុងចេញរួចផុតចាកត្រៃលោក លែងត្រឡប់មកអន្ទោលវិលកើតស្លាប់ក្នុងត្រៃភពទៀតហើយ ។

(នៅមានត)

# ព្រះអភិធម្មបិដក

## គម្ពីរព្រះយមកៈ

លោក ប៊ូ - ប៊ុ ប្រែរៀបរៀង

( កពីលេខ ១១ ឆ្នាំ ១៩៦១ )

---

## ខន្ធយមកៈ

ឥទានិ មូលយមកេ ទេសិតនយេន កុសលា-ទិធម្មេ ខន្ធវសេន សង្គណ្ហិត្វា មូលយមកានន្តរំ ទេសិតស្ស ខន្ធយមកស្ស វណ្ណនា ហោតិ ។

វារៈនេះ សូមវិសជ្ជនាក្នុងខន្ធយមកៈតទៅ ដំណើរសេចក្តីថា វណ្ណនា ការពណ៌នានៃនូវខន្ធយមកៈ ដែលសម្តេចព្រះមហាមុនីទ្រង់សង្គ្រោះនូវធម៌ទាំងឡាយ មានកុសលធម៌ជាអាទិ៍ ដោយអំណាចជាពួកជាកងគ្នា តាមន័យដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់ទេសនាក្នុងមូល-យមកៈ ហើយត្រាស់សំដែងក្នុងមូលយមកៈជាលំដាប់នោះ រមែងមានប្រាកដក្នុងកាលឥឡូវនេះ ។

ឥមស្មិំ ខន្ធយមកេ ក្នុងខន្ធយមកៈនេះ មានវារៈ ៣ គឺ បញ្ញត្តិវារៈ ១ បវត្តិវារៈ ១ បរិញ្ញាវារៈ ១ ។ បណ្តាវារៈទាំង ៣ ប្រការនោះ វារៈណាប្រព្រឹត្តទៅដោយអំណាចនៃការជម្រះ នូវឈ្មោះនៃខន្ធ

ទាំងឡាយ ការៈនោះឈ្មោះថា បញ្ញត្តិការៈ ។ ឯបវត្តិការៈ បានដល់ ការដែលត្រាស់ទេសនាប្រព្រឹត្តទៅ ដោយអំណាចកើតនិងរលត់ខន្ធទាំងឡាយ នូវបរិញ្ញាខន្ធទាំងឡាយដ៏ប្រព្រឹត្តទៅដោយលំដាប់ដូច្នេះ ។

ក្នុងខន្ធយមកៈនេះ ព្រះពុទ្ធអង្គទ្រង់ត្រាស់ទេសនានូវខន្ធទាំងឡាយប្រាំ ប៉ុន្តែទ្រង់ត្រាស់ទេសនាបុច្ឆាជាគូ ៗ ត្រាស់វិសជ្ជនាជាគូ ៗ គ្នា គឺត្រាស់ទេសនានូវរូបក្ខន្ធ, វេទនាខន្ធ, សញ្ញាខន្ធ, សង្ខារក្ខន្ធ, វិញ្ញាណក្ខន្ធ ។

ខន្ធទាំងប្រាំនោះ ទ្រង់ត្រាស់បុច្ឆាក្នុងរូបក្ខន្ធជាមុនថា យំកិញ្ចិ រូបំ រូបក្ខន្ធ គឺកងនៃរូបនោះ ឬ ឈ្មោះថា រូបក្ខន្ធ ?

មានពាក្យអធិប្បាយថា បិយរូបំ សាតរូបំ រូបដែលបុគ្គលគប្បីស្រឡាញ់ ជាទីស្រឡាញ់ ជាទីត្រេកអរនោះ ឈ្មោះថារូបក្ខន្ធមែនឬទេ ? រូបក្ខន្ធទាំងពួងនោះឈ្មោះថា រូបក្ខន្ធ មែនឬទេ ?

ទ្រង់ត្រាស់បុច្ឆាដូច្នេះហើយ ទើបទ្រង់ត្រាស់វិសជ្ជនាថា បិយ-រូបំ ក៏ រូបជាទីស្រឡាញ់ និងជាទីត្រេកអរក្តី ចូរលើកទុកចុះ មហាភូត-រូបបួន និងឧបាទាយរូបម្ភៃបួនក្តី ក៏សង្គ្រោះចូលក្នុងរូបក្ខន្ធ ។ នោះឯងឈ្មោះថា រូប ។ នោះឯងឈ្មោះថា រូបក្ខន្ធ ។

ក្នុងវេទនាខន្ធនោះ ទ្រង់ត្រាស់បុច្ឆាថា វេទនាគឺការសោយអារម្មណ៍នោះ ឈ្មោះថាវេទនាខន្ធមែនឬទេ ? ទ្រង់ត្រាស់វិសជ្ជនាថា

អាមន្តា ភេ! គឺវេទនានោះឯង ឈ្មោះថា វេទនាខន្ធ ។ នោះឯង ឈ្មោះថា វេទនា ។

ក្នុងសញ្ញាខន្ធទ្រង់ត្រាស់បុច្ឆាថា សញ្ញានោះឬឈ្មោះថា សញ្ញាខន្ធ? សញ្ញាខន្ធនោះឬឈ្មោះថា សញ្ញា? ទើបទ្រង់ត្រាស់វិសជ្ជនាថា អាមន្តា ភេ! សញ្ញានោះឯងឈ្មោះថា សញ្ញាខន្ធ ។ នោះឯងឈ្មោះថា សញ្ញា ។

ក្នុងសង្ខារក្ខន្ធ នឹងវិញ្ញាណក្ខន្ធ ព្រះពុទ្ធអង្គទ្រង់ត្រាស់បុច្ឆានឹងវិសជ្ជនាជាគូ ៗ គ្នា ដូចន័យដែលសំដែងហើយក្នុងរូបក្ខន្ធ ។

ខន្ធទាំងប្រាំមានរូបក្ខន្ធជាដើម អ្នកប្រាជ្ញគប្បីពិចារណាឲ្យឃើញដោយឧបមាថា ខន្ធទាំងប្រាំប្រៀបដូចជាសឹកសត្រូវដែលមានដាវកាន់លើកឆាឡើង នឹងប្រៀបដូចជាវត្ថុសម្រាប់ទំពាបរិភោគ ។ ម្យ៉ាងទៀត គប្បីពិចារណាឲ្យឃើញថា បញ្ចក្ខន្ធមិនទៀង, ជាទុក្ខ, មិនមែនជារបស់ខ្លួន ព្រោះហេតុបច្ច័យ គឺកុសលនឹងអកុសលតាក់តែងឡើង នេះពោលដោយសង្ខេបល្មមឲ្យពិចារណាឃើញងាយ ៗ ។ វិត្ថារតោបនេត្ត បើនឹងពោលដោយពិស្តារ ក្នុងបញ្ចក្ខន្ធនោះគឺ៖

រូប ប្រៀបដូចដុំនៃពពុះទឹក,

វេទនា ប្រៀបដូចក្រពេញទឹកដែលផុសព្រូច ៗ ឡើងពីខ្សែទឹក,

សញ្ញា ប្រៀបដូចព្រិញថ្ងៃ ឬហៅថា ថ្ងៃបណ្តើរគួច,

សង្ខារ ប្រៀបដូចដើមចេក ,

វិញ្ញាណ ប្រៀបដូចស្រ្តីមានមាយា ឬមានពុតត្បុត ។

បិណ្ឌោ ហិ ធិសប្ពកោ ឯវ មែនពិត រីដុំនៃពពុះទឹកនោះ ឥតខ្លឹមសារសោះ ព្រោះមិនទៀងទាត់ មិនមាំមួន ។ ដុំពពុះទឹកនោះ បុគ្គលនឹងយកមកធ្វើជាភាជនៈសម្រាប់ដាក់វត្ថុទាំងពួង គឺធ្វើជាចាន, ជាឆ្នាំង, ជាថូ, ជាពាងមិនកើត ។ ន សារចេតិ ដុំពពុះទឹកនោះ មិនបានសម្រេចប្រយោជន៍អ្វីសោះ រមែងបែកខ្ចាត់ខ្ចាយទៅ យ៉ាងណា ។ ន សក្កា គហេតុំ បុគ្គលណាមួយមិនអាចនឹងកាន់យកថាជារបស់ទៀងទាត់, ថាជារបស់មាំមួន នឹងសំគាល់ថាជារបស់ខ្លួនក៏មិនបាន ។ គហិតំបិ សូម្បីបុគ្គលនឹងចាប់កាន់ដុំពពុះទឹកនោះ ក៏ចាប់មិនបាន មិនគង់នៅគង់ដៃ តែងបែកធ្លាយសាបសូន្យអស់ទៅយ៉ាងណា ។

រូបំ សត្តានំ រូបកាយរបស់មនុស្សសត្វទាំងឡាយនេះ មិនទៀង, ជាទុក្ខ, មិនមែនជារបស់ខ្លួន ក៏មានឧបមេយ្យយ៉ាងនោះ ។

ម្យ៉ាងទៀត ដុំនៃពពុះទឹកនោះ ជាទីចនោះតូចខ្លះធំខ្លះ ជាប់ត ។ គ្នាច្រើនដំណាលឡើង ទៅជាលំនៅរបស់សត្វទឹកទាំងឡាយមានត្រីជាដើម យ៉ាងណា ។ ឯវរូបំ រូបកាយនៃមនុស្សសត្វទាំងឡាយក៏ជាចនោះតូចខ្លះ ធំខ្លះ ជាប់ត ។ គ្នាជាច្រើនដំណា ក៏ជាទីអាស្រ័យនៅនៃសត្វទាំងឡាយមានដង្កូវជាដើម មានឧបមេយ្យយ៉ាងនោះដែរ ។ អសីតិកាមិ-

ការុណាធិ ត្រកូលនៃដង្កូវទាំងឡាយ ៨០ ត្រកូល រមែងមកអាស្រ័យនៅក្នុងរូបកាយនេះ ។ រូបកាយនេះ ជាទីកើត ចាស់ ឈឺ ស្លាប់ ជាទីប៉ាធាគី កន្ទ្រង់ផុតដង្កូវទាំងអស់នោះ ។ អញ្ញត្ត អាគន្តា ហ្វូងដង្កូវទាំងអស់នោះ មិនមែនមកអំពីទីឯណាទេ ប្រាកដជាកើតមាននៅក្នុងរូបកាយនេះឯង ។

ផេណុបិណ្ឌា ៤ ប្រការមួយទៀត ដុំពពុះទឹកនោះមុនដំបូងប៉ុនស្លឹកពុទ្រា លុះយូរទៅប៉ុនកំពូលភ្នំ ចេះតែចំរើនធំឡើងៗ តាមលំដាប់ដូចម្តេច ។ អាទិតោ កាលលមត្តំ រូបនេះចាប់ផ្តើមមុនដំបូងប៉ុនដំណក់ប្រេងល្ងជាកលលៈ លុះយូរទៅក៏ចំរើនធំឡើង ។ តាមលំដាប់មានឧបមេយ្យដូច្នោះ ។

ប្រការមួយទៀត ដុំនៃពពុះទឹកនោះ តាំងប៉ោងឡើងហើយអណ្តែតទៅដល់ផ្ទៃនៃមហាសាគរ ក៏រមែងបែកធ្លាយទៅជាប្រាកដដូចម្តេច ។ កាលលកតោបិ សូម្បីរូបនេះចាប់ផ្តើមមុនដំបូងជាកលលៈ ហើយប្រែក្លាយទៅជាអព្វុទៈ ជាបេសិ (ដុំសាច់) ទៅតាមលំដាប់ បើមិនបានរលត់រលាយរូបនេះទេ ចេះតែចំរើនធំឡើងរហូតដល់ប្រសូតចាកផ្ទៃមាតាហើយរស់នៅយូរឆ្នាំទៅទៀត ។ បើទុកជារូបនេះរស់នៅយូរឆ្នាំ ក៏មិនលើសពីមួយរយឆ្នាំដែរ គង់តែរលត់រលាយបាត់រូបនេះទៅវិញជាមិនខាន ហេតុនេះ បានជាលោកប្រៀបរូបកាយទៅនឹងដុំពពុះទឹក ។

វេទនាខន្ធ ប្រៀបដូចក្រពេញទឹក(១) ។ ធម្មតាក្រពេញទឹកនោះ បុគ្គលចាប់ដាក់ក្នុងបាតដៃមិនបានទេ សូម្បីយកភាជនៈអ្វី ៗ ទៅដួសក៏មិនបានដែរ គ្រាន់តែបះពាល់ភ្លាមរលត់រលាយបាត់ទៅ ដូចម្តេច ៗ វេទនាខន្ធ កងនៃវេទនា គឺការសោយអារម្មណ៍នេះ មានឧបមេយ្យដូចក្រពេញទឹកនោះដែរ ។

ពិតណាស់វេទនាខន្ធនោះ ទោះបីកើតជានិច្ចឥតអាក់ខានវេលាណា ក៏ជាការមិនទៀងទាត់ តែងប្រែប្រួលផ្លាស់ប្តូរជាធម្មតា គឺថា បុគ្គលបានសោយអារម្មណ៍ជាសុខហើយ មិនមែនចេះតែបានសុខនោះជាប់ឋិតថេរចីរកាលទៅទេ គង់មានពេលខ្លះឬថ្ងៃខ្លះផ្លាស់ទៅសោយទុក្ខវិញ កាលបានទុក្ខហើយ មិនមែនចេះតែបានទុក្ខរហូតទៅទេ គង់មានវេលាបានសុខវិញ ។ សុខនឹងទុក្ខតែងផ្លាស់ប្តូរគ្នាជាវេនដូច្នេះ បានជាលោកប្រាប់ថាវេទនាមិនទៀងទេ ។ នេះនិយាយចំពោះតែមនុស្សម្នាក់ ៗ ជួនកាលបានសុខ, ជួនកាលបានទុក្ខ ។ សោមនស្សក្តី ទោមនស្សក្តី ឧបេក្ខាក្តី ក៏តែងប្រែប្រួលផ្លាស់ប្តូរគ្នា ដូចជាសុខទុក្ខនេះដែរ ។

ឧប្បជ្ជន្តិ ចេវ និរុជ្ឈន្តិ ច វេទនានោះរមែងកើតឡើងហើយរលត់ទៅវិញ រលត់ទៅហើយត្រឡប់កើតឡើងវិញ ចេះតែកើតហើយរលត់ ៗ ហើយកើតដរាបទៅ កើតជាសុខខ្លះ ជាទុក្ខខ្លះផ្លាស់ប្តូរ

១– សំដៅយកទឹកដែលផុះព្រួចៗ ពីក្រោមឡើងលើ ហៅក្រពេញទឹក, ដូចទឹកដែលគេដាំក្នុងឆ្នាំង ហើយផុះព្រួចៗឡើងលើមុនដំបូង ទើបកើតទៅភាគពុះពោងអណ្តែតខាងក្រោយ ។

គ្នា ដូចន័យខាងដើម ។ ឯវេទនានឹងកើតឡើងបានដោយអាស្រ័យហេតុ ៤ ប្រការ គឺ៖

១- វត្ថុជាទីកើត,

២- អារម្មណ៍ជាទីគោងទាញ,

៣- កិលេស,

៤- ការខ្ទាំងខ្ទប់ ឬប៉ះពាល់ ។

សញ្ញាខន្ធ ប្រៀបដូចព្រិញថ្ងៃ ព្រោះប្រាសចាកខ្លឹមសារ ។ ព្រិញថ្ងៃនោះ បើកើតឡើងហើយ គេក្រឡេកមើលពីចម្ងាយទៅឃើញហាក់ដូចជាមានរូបកង់គួរនឹងចាប់កាន់បាន សំឡឹងមើលដូចសណ្ឋានទៃផ្ទះជាដើម លុះចូលទៅជិតហើយ ស្រាប់តែបាត់អស់ទៅ នឹងចាប់កាន់មិនបាន ដូចម្តេច សញ្ញាមានឧបមេយ្យដូច្នោះ ។

អបិច បរិជន្តិ ប្រការមួយទៀត ព្រិញថ្ងៃនោះតែងប្រែប្រួលទៅផ្សេងៗ យ៉ាងណា សញ្ញាក៏ប្រែប្រួលយ៉ាងនោះដែរ ។ សញ្ញាឧម្មិលោ វិយ សញ្ញាប្រៀបដូចរលកកើតឡើងក្នុងមហាសមុទ្រ តែងប្រែប្រួលទៅជាធម្មតា ។ រលកមិនដែលនឹងនៅមួយកន្លែងយ៉ាងណា សញ្ញាក៏តែងប្រែប្រួលយ៉ាងនោះដែរ ។

សង្ខារក្ខន្ធ ប្រៀបដូចដើមចេក ។ កទលិខន្ធសទិសា សង្ខារា សង្ខារទាំងឡាយ ប្រៀបដូចដើមចេក ព្រោះថាជាធម្មជាតិឥត

ខ្លឹមសារ ។ ឧ សញ្ញោតិ បុគ្គលណាក៏មិនអាចយកខ្លឹមដើមចេក ទៅឈូសចាំងធ្វើជារបស់ផ្សេងៗ បានដែរ ព្រោះដើមចេកនោះគ្មានខ្លឹមសោះ មានតែបណ្ដូលខាងក្នុងប៉ុណ្ណោះ ។

សង្ខារទាំងឡាយនោះ បុគ្គលមិនអាចនឹងពោលថាជារបស់ទៀងទាត់បានឡើយ ព្រោះថាសង្ខារធម៌ខ្លះ កុសលប្រគល់ឲ្យ, បច្ច័យគឺកុសលតាក់តែង ជួនកាលអកុសលប្រគល់ឲ្យ, បច្ច័យគឺអកុសលតាក់តែង ។ កាលបើកុសលតាក់តែង ក៏ប្រកបដោយរូបកាយទ្រង់ទ្រាយពណ៌សម្បុរដ៏ល្អស្រស់ គួរឲ្យពេញចិត្តស្រឡាញ់ ប្រកបដោយសិរីសម្បត្តិបរិបូណ៌ ដោយសវិញ្ញាណកទ្រព្យ និងអវិញ្ញាណកទ្រព្យ ជាច្រើនរាប់មិនអស់ ។

សង្ខារបើអកុសលប្រគល់ឲ្យ គឺអកុសលជាបច្ច័យប្រជុំតាក់តែង ក៏មានរូបកាយអាក្រក់គួរឲ្យគេស្អប់ខ្ពើម ប្រាសចាកសិរីនិងពណ៌សម្បុរ មានសរីរាវយវៈជាទោស និងជាមនុស្សកំសត់ទុគ៌ត ជាមនុស្សអភ័ព្វទុព្វលភាព មិនជាទីស្រឡាញ់ពេញចិត្តរបស់អ្នកណាម្នាក់ឡើយ ។ ហេតុនោះ បានជាពោលថា សង្ខារទាំងឡាយមិនទៀងទាត់ ឥតខ្លឹមសារ ឧបមាដូចជាដើមចេក ។

ពហុវត្តុបត្តសមោធានោ ដើមចេកជាទីប្រជុំនៃស្រទាប់ដ៏ច្រើនយ៉ាងណា ពហុធម្មសមោធានោ សង្ខារធម៌នេះជាទីប្រជុំនៃធម៌ទាំងឡាយដ៏ច្រើន យ៉ាងនោះ ។ នានាលក្ខណោ ដើមចេក

មានលក្ខណៈផ្សេង ៗ គឺពណ៌ស៊ុក នឹងពណ៌ស្រទបខាងក្រៅបែបម្យ៉ាង, ពណ៌ខាងក្នុងបែបម្យ៉ាង មិនស្របគ្នាឡើយ នេះមានឧបមាដូចម្តេច ៗ សង្ខារក្ខន្ធមានលក្ខណៈផ្សេងៗ គឺលក្ខណៈនៃផស្សៈផ្សេងទៅម្យ៉ាង, លក្ខណៈនៃចេតនាផ្សេងទៅម្យ៉ាង មិនត្រូវត្រង់គ្នា មានឧបមេយ្យដូច្នោះ ៗ

វិញ្ញាណំ បិ មាយា សទិសំ ឯវិញ្ញាណក្ខន្ធ ប្រៀបដូចជាស្ត្រីមានមាយា ប្រកបដោយអាកប្បកិរិយាលួងលោមបញ្ឆោតបុរសឲ្យវង្វេងវិលវល់លះកាត់មិនដាច់ ៗ អាកតោ វិយ កតោ ធ្វើអាការមកនឹងទៅ ហាក់ដូចជាទៅស្និតនៅជាប់ក្នុងចិត្តរបស់បុរស ៗ នឹងដេកដើរឈរអង្គុយក្តី ៗ បើបុរសនោះបានជួបប្រទះនឹងស្ត្រីមាយា គឺពោលពាក្យនឹងធ្វើអាកប្បកិរិយាជាហេតុញ៉ាំងចិត្តឲ្យកើតជម្រេកក្នុងស្ត្រីមាយានោះ ឲ្យវង្វេងស្មារតីទៅក្នុងស្ត្រីមាយានោះ ៗ

ន័យម្យ៉ាងទៀត វិញ្ញាណក្ខន្ធ នេះ ប្រៀបដូចនាយពាណិជប្រកបដោយមាយាច្រើនធ្វើពាណិជ្ជកម្ម មហាជនំ វញ្ចេតិ នាយពាណិជដែលមានមាយានោះ តែងនិយាយល្បួងលួងលោមបញ្ឆោតមហាជនឲ្យគាន់ប្រឡំដោយសំដីរបស់ខ្លួនថា ឥទំ វត្ថុំ អនគ្ឃំ វត្ថុនេះ ខ្ញុំមិនលក់ឲ្យថ្លៃច្រើនពេកទេ កាលពីដើមរកទិញបានងាយ ៗ ឥឡូវនេះ បើទុកជាអ្នកមានប្រាក់ច្រើន ក៏រកទិញមិនបានដែរ ជារបស់ក្រមានហើយគាត់ថ្លៃមិនកើតផង គឺថាជារបស់ថ្លៃណាស់ ប៉ុន្តែ បើអ្នក

ចង់បានសុំទិញខ្ញុំហើយ ខ្ញុំក៏ឥតថាអ្វីដែរ គាត់ចិត្តលក់ជូនទៅចុះ ឲ្យមកខ្ញុំតែប៉ុណ្ណោះរៀល ឬប៉ុណ្ណោះរៀលល្មមហើយ តាមប្រាក់អ្នកមាន ព្រោះជាអ្នកធ្លាប់លក់ដូរដូចគ្នា ។ អ្នកទិញឮសំដីដូច្នោះក៏ទទួលចិត្ត វង្វេងទៅទៅដោយកលមាយារបស់នាយពាណិជ ជឿតាមស្ដុងហើយ ក៏ចាប់ពប់ប្រាក់ប្រគល់ទៅឲ្យនាយពាណិជ សេចក្ដីនេះ មានឧបមាយ៉ាងណា ៗ ឯវិញ្ញាណក្ខន្ធ ក៏ធ្វើអារម្មណ៍ឲ្យប្រាដកដូចមកកាន់មនោទ្វារវិថី បញ្ឆោតចិត្តឲ្យមកទទួលអារម្មណ៍មានរូបជាដើមថា អារម្មណ៍នេះល្អ អារម្មណ៍នេះមិនល្អ មានឧបមេយ្យដូចនាយពាណិជនោះដែរ ៗ

បណ្ឌិតទាំងឡាយ គប្បីយល់ឃើញថា អារម្មណ៍មានរូបជាដើមនេះមិនល្អទេ ៗ ប៉ុន្តែ រូបទាំងពួងនោះល្អទៅតាមលោកសន្មតថាល្អយ៉ាងណា ៗ លុះដល់ជរាព្យាធិចូលមកគ្របសង្កត់ហើយ ក៏លែងល្អ ៗ បើគ្មានជរាព្យាធិគ្របសង្កត់ទេ ក៏ឃើញហាក់ដូចជាល្អខ្លះដែរ ដោយ-សារគេខំតាក់តែងគ្រឿងអលង្ការ មានសំពត់អាវមេឡូរមៀតមាសពេជ្រជាដើម ៗ តាមធម្មតា រូបគ្មានល្អត្រង់ណាសោះ ជារបស់ស្មោកគ្រោកគួរខ្ពើមរអើម ព្រោះកើតមកអំពីធាតុដីទឹកភ្លើងខ្យល់ទាំងបួនប្រជុំគ្នា នេះពោលតាមបរមត្ថវោហារ ៗ បើពោលតាមពាក្យអ្នកស្រុកថា រូបមានល្អខ្លះ មានអាក្រក់ខ្លះ ៗ

(នៅមានត)

មធុរសភាសិណី

# សម្តេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

ព្រះញាណកោសល ញាណ-ឈឹន ពិនិត្យ

(តពីលេខ ១១ ឆ្នាំ ១៩៦៩)

---

## ១ - សហាយស្ស បរិច្ចត្តជីវិតវត្ថុកថា

សំដែងរឿងនិទាន បុរសលះបង់ជីវិតដល់សំឡាញ់ ដោយករៈបាលីថា: ភគវតិ បរិនិព្វុតេ ដូច្នេះជាដើម អធិប្បាយថា កាលព្រះមានព្រះភាគទ្រង់ចូលព្រះបរមនិព្វានទៅហើយ ក្រោយនោះមានព្រាហ្មណ៍ពីរនាក់ មួយឈ្មោះសោមព្រាហ្មណ៍ មួយឈ្មោះសោមទត្តព្រាហ្មណ៍ នៅអាស្រ័យក្នុងនគរសាវត្ថីជាមួយគ្នា ។ ឯសោមព្រាហ្មណ៍ តែងលេងល្បែងបាស្កាភ្នាល់ ជាមួយនឹងសោមទត្តព្រាហ្មណ៍ជាសំឡាញ់រឿយ ៗ អថេកទិវសំ មានថ្ងៃមួយជាខាងក្រោយ សោមទត្តព្រាហ្មណ៍បានលេងឈ្នះសោមព្រាហ្មណ៍ ហើយដោះយកសំពត់បង់កអំពីស្មានឹងចិញ្ចៀនអំពីម្រាមដៃរបស់សោមព្រាហ្មណ៍នោះ កាលដែលនឹងត្រឡប់ទៅកាន់ផ្ទះវិញ ក៏និយាយទៅនឹងសំឡាញ់ថា: ម្នាលសោមព្រាហ្មណ៍សំឡាញ់! អ្នកចូរមក យើងនឹងទៅកាន់ផ្ទះឥឡូវនេះឯង ។

លំដាប់នោះសោមព្រាហ្មណ៍ និយាយតបវិញថា អើ! សំឡាញ់

ខ្ញុំមានសំពត់សាដកតែមួយ ខ្ញុំពុំអាចនឹងចុះទៅកាន់ថ្នល់បានឡើយ, អំពើដែលខ្ញុំទៅក្នុងទីនេះ ប្រសើរជាជាងទៅដោយពិត ។

ឯសោមទត្តព្រាហ្មណ៍បានស្តាប់ហើយ ក៏និយាយថា អើ! សំឡាញ់ បើដូច្នោះត្រូវអ្នកកាន់យកសំពត់សាដកសំពប់បង់កនេះ ដណ្តប់ហើយដើរទៅចុះ, លុះពោលយ៉ាងនេះហើយក៏ឲ្យសំពត់សាដកនោះ ដល់សោម. ព្រាហ្មណ៍ជាសំឡាញ់នោះឯង ហើយនិយាយតឿនទៀតថា ម្នាលសំឡាញ់! អ្នកត្រូវមក យើងនឹងទៅកាន់ផ្ទះក្នុងកាលឥឡូវនេះឯង ។ ឯសោមព្រាហ្មណ៍ជាសំឡាញ់ក៏ពុំព្រមទៅសោះ, ខណៈនោះសោមទត្ត-ព្រាហ្មណ៍បានសួរម្តងទៀតថា ព្រោះហេតុអ្វីបានអ្នកមិនទៅ? សោម-ព្រាហ្មណ៍ប្រាប់ថា ម្នាលសំឡាញ់! បានជាខ្ញុំមិនទៅ ដ្បិតមនុស្សជាបរិស័ទទាំងឡាយមានកូននឹងប្រពន្ធជាដើម តែគេពុំឃើញចិញ្ចៀនក្នុងដៃខ្ញុំហើយគេនឹងធ្វើជម្លោះឈ្លោះទាស់ទែងនឹងខ្ញុំពុំលែងឡើយ ព្រោះហេតុដូច្នោះបានជាខ្ញុំមិនទៅ ។

កាលនោះ សោមទត្តព្រាហ្មណ៍ បាននិយាយនឹងសោមព្រាហ្មណ៍ថា ម្នាលសំឡាញ់អើយ! បើអ្នកមានប្រាថ្នាយ៉ាងណា ខ្ញុំនឹងឲ្យដល់អ្នកយ៉ាងនោះចុះ លុះនិយាយហើយ ក៏យកចិញ្ចៀននោះហុចឲ្យសោមព្រាហ្មណ៍ពាក់វិញដូចដែល ហើយនាំគ្នាដើរទៅកាន់ផ្ទះរបស់ខ្លួនទីទៃ ៗ ទៅ ។ ព្រាហ្មណ៍ទាំងពីរនាក់នោះ ក៏យកគ្នាជាមិត្តសំឡាញ់ដោយហេតុ

មានប្រមាណប៉ុណ្ណោះ ក្នុងកាលនោះហោង ៗ

លុះកាលជាចំណែកខាងក្រោយ មនុស្សទាំងឡាយព្រួតគ្នាចាប់យកសោមទត្តព្រាហ្មណ៍បាន ព្រោះអំពើធ្វើបរទារកម្ម ចួចប្រពន្ធគេ ហើយនាំយកទៅថ្វាយព្រះបរមក្សត្រិយ៍ ឲ្យទ្រង់កាត់សេចក្ដីតាមច្បាប់សំរាប់បវេណីនគរ ៗ

ឯសម្ដេចព្រះនរាធិបតីជាម្ចាស់ផែនដី លុះទ្រង់បានទតឃើញរូបសម្បត្តិនៃសោមទត្តព្រាហ្មណ៍ហើយ ព្រះអង្គពុំបានកាត់ទោសដល់ព្រាហ្មណ៍ឡើយ ព្រះអង្គគ្រាន់តែព្រះរាជទានដំបូន្មានថា ម្នាលព្រាហ្មណ៍ដ៏ចំរើន ! អ្នកកុំធ្វើអំពើយ៉ាងនេះទៀត ត្រូវអ្នកវៀរលែងឲ្យស្រឡះចេញ ហើយទ្រង់បញ្ជាឲ្យដោះលែងសោមទត្តព្រាហ្មណ៍នោះឲ្យត្រឡប់ទៅផ្ទះខ្លួនវិញ ៗ

ចំណែកសោមទត្តព្រាហ្មណ៍នោះ ក៏ពុំបានវៀរលែងអំពើដែលខ្លួនធ្លាប់ធ្វើនោះឡើយ, នៅតែធ្វើដដែល មនុស្សទាំងឡាយចាប់បាននាំយកមកថ្វាយព្រះបរមក្សត្រិយ៍ជាគម្រប់ពីរដង បីដង ទ្រង់គ្រាន់តែទូន្មានប្រដៅហើយដោះលែងទៅវិញដូចមុនទៀត លុះគេចាប់បានក្នុងវារៈជាគំរប់ ៤ ដងក៏នាំយកមកថ្វាយព្រះបរមក្សត្រិយ៍ទៀត ព្រះរាជាទ្រង់ក្រោធពិរោធខ្លាំងហើយ ត្រាស់បញ្ជាពួកពេជ្ឈឃាដថា អ្នកទាំងឡាយត្រូវចាប់ចងព្រាហ្មណ៍នោះឲ្យមាំ នាំយកទៅកាន់កន្លែងសំរាប់សំឡាប់មនុស្ស

ហើយសំឡាប់កំពោលឲ្យធ្លាក់ទៅចុះ ។

ធម្មតាមនុស្សអ្នកត្រេកអររីករាយក្នុងបាបកម្ម ដ៏លាមកយ៉ាងនេះ ទោះបីបុគ្គលខ្លួនប្រដៅដោយអាការច្រើនដូចម្តេចក្តី ក៏គង់ពុំអាចនឹងហាមបុគ្គលដែលប្រព្រឹត្តលាមកនោះឲ្យរាងចាលបានឡើយ ។ ព្រោះហេតុដូច្នោះ បានជាព្រះគន្ថរចនាចារ្យលោកពោលជាបទព្រះគាថា ថា:

សោណា ចេវ សិង្គាលា ច កាយសា និលមក្ខិកា
កុណបេ សត្តេ អច្ចន្តំ ន សក្កោន្តិ និសេធិតុំ
តថា ចាណាតិចារេសុ បរទារេ សុរាយ ច
មុសាវាទេសុ ថេយ្យេសុ តេ សត្តា ន និវារយា ។

អធិប្បាយថា: ពួកឆ្កែក្តី ពួកចចកក្តី ពួកក្អែកក្តី ពួករុយខៀវក្តី តែងត្រេកអរលង់ទៅក្នុងសាកសព មានខ្មោចដំរីនិងសេះជាដើម ដែលបុគ្គលមិនអាចនឹងឃាត់ហាមបាន មានឧបមាយ៉ាងណា, ជនអសប្បុរសទាំងឡាយ ជាអ្នកត្រេកអរក្នុងអំពើសម្លាប់សត្វក្តី អំពើលួចប្លន់ទ្រព្យគេក្តី អំពើលួចប្រពន្ធគេក្តី អំពើពោលពាក្យកុហកបញ្ឆោតគេក្តី អំពើផឹកទឹកស្រវឹងគឺសុរាទឹងមេរ័យក្តី ដែលបុគ្គលមិនអាចនឹងឃាត់ហាមបាន ក៏មានឧបមេយ្យយ៉ាងនោះឯង ។

ព្រោះហេតុដូច្នោះ សោមទត្តព្រាហ្មណ៍នេះ ជាអ្នកត្រេកអរតែក្នុងអំពើលួចប្រពន្ធគេ ព្រះបរមក្សត្រិយ៍ទ្រង់ខ្លួនឃាត់ហាមដោយការៈជា

ច្រើនដង ក៏គង់ពុំព្រមវៀរលែងឡើយ នៅតែប្រព្រឹត្តធ្វើអំពើនោះដដែល ដោយពិត ។

លំដាប់នោះ រាជបុរសទាំងឡាយចាប់ចងសោមទត្តព្រាហ្មណ៍យ៉ាងមាំ តាមព្រះរាជបញ្ជា ហើយនាំបណ្ដើរយកទៅដើម្បីនឹងសំឡាប់ ។

កាលនោះ សោមព្រាហ្មណ៍ជាសំឡាញ់ បានឃើញរាជបុរសទាំងឡាយ នាំយកសោមទត្តព្រាហ្មណ៍ទៅប្រុងនឹងសម្លាប់ដូច្នោះ ក៏មានដួងហឫទ័យញាប់ញ័រអាណិតពេកណាស់ បានចូលទៅកាន់សំណាក់រាជបុរសមួយរំពេច ហើយអង្វរសូមឃាត់ថា បពិត្រលោកដ៏ចំរើន! សូមលោកទាំងឡាយកុំអាលសំឡាប់ព្រាហ្មណ៍នេះឡើយ រង់ចាំខ្ញុំក្រាបបង្គំទូលព្រះបរមក្សត្រិយ៍ សូមព្រះអង្គទ្រង់ជ្រាបសិន លុះសោមព្រាហ្មណ៍បានសូមអង្វរយ៉ាងនេះហើយ ក៏ចូលទៅគាល់ព្រះបរមក្សត្រិយ៍ ហើយស្ថិតនៅក្នុងទីសមគួរ ទើបលើកដៃប្រណម្យ ក្រាបបង្គំទូលសូមទោសថា បពិត្រព្រះសម្មតិទេព! សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោសព្រះរាជទានជីវិតដល់សោមទត្តព្រាហ្មណ៍នេះឲ្យទាន, ប្រសិនបើព្រះអង្គមិនទ្រង់ព្រះមេត្តាប្រោសទេ ទ្រង់ប្រាថ្នានឹងសំឡាប់ពិតមែន សូមព្រះអង្គសំឡាប់ខ្ញុំម្ចាស់ជំនួសវិញចុះ តាមសព្វព្រះរាជហឫទ័យ ។

ព្រះកុមិន្ទ្រាធិបតីបរមក្សត្រិយ៍បានទ្រង់ព្រះសណ្ដាប់ហើយ ស្ដេចនៅស្ងៀមពុំមានព្រះបន្ទូលថាអ្វីសោះឡើយ ។

ឯកជបុរសទាំងឡាយ ក៏ដោះលែងសោមទត្តព្រាហ្មណ៍ ហើយចាប់ចងសោមព្រាហ្មណ៍នាំយកទៅសំឡាប់ក្នុងកាលនោះឯង ។

បពិត្រសប្បុរសទាំងឡាយអើយ ! យើងទាំងឡាយគួរពិចារណាថា សោមព្រាហ្មណ៍នោះ មានសទ្ធាចិត្តកតញ្ញូកតវេទី អាចប្ដូរជីវិតរបស់ខ្លួនដោះលែងសោមទត្តព្រាហ្មណ៍ ដែលមានគុណដល់ខ្លួនឲ្យរួចអំពីសេចក្ដីស្លាប់បាន ស៊ូស្លាប់ដោយខ្លួនឯង នេះជាគុណអស្ចារ្យពន់ពេកណាស់ ។

ព្រោះហេតុដូច្នេះ បានជាមានពុទ្ធភាសិតថា:

កតុបការមត្តានំ សរន្តា កោចិ មនុស្សា
ជីវិតំ ចជតិ សោ អេវ សោមទត្តស្ស អត្ថតោ ។

អធិប្បាយថា មនុស្សណាមួយ កាលបើបាននឹករលឹកនូវឧបការគុណ ដែលអ្នកដទៃគេបានធ្វើដល់ខ្លួនហើយ ត្រូវតែធ្វើតបគុណវិញឲ្យដូចជាសោមព្រាហ្មណ៍ដែលបានលះបង់ជីវិតរបស់ខ្លួន ឲ្យដល់សោមទត្តព្រាហ្មណ៍ដែលមានគុណដល់ខ្លួនដូច្នោះឯង ។

ដោយអំណាចផលានិសង្សដែលបានឲ្យជីវិតទាននោះ សោមព្រាហ្មណ៍សោតក៏បានអន្ទោលទៅកើតក្នុងស្ថានទេវលោកនាយ ស្ថិតនៅក្នុងប្រាសាទមាសយ៉ាងធំដ៏ប្រសើរ មានស្រីទេពអប្សរមួយពាន់ ហោមហែមជាយសបរិវារ សោយនូវសម្បត្តិទិព្វដ៏មានសិរីសួស្តី ក្នុងស្ថានសួគ៌ទេវលោកនោះឯង ។

(នៅមានត)

# មហោសថជាតក

លោក អ៊ឹម-គង ចម្លងពីសាស្ត្រាស្លឹករឹត

ព្រះពុទ្ធវង្ស ភឹម-ត្រូ ពិនិត្យ

(តពីលេខ ១១ ឆ្នាំ ១៩៦·)

---

ទើបអាចារ្យទាំង ៤ ទូលថា ពិតប្រាកដណាស់ កុំបីអម្ចាស់សង្ស័យឡើយ, បើអម្ចាស់ពុំជឿ ក៏ចូរអម្ចាស់ឲ្យហៅមហោសថឡើងមក ហើយអម្ចាស់ដណ្ដឹងនូវអាថ៌កំបាំងថា គួរសំដែងថ្លែងប្រាប់អ្នកឯណាប្រសើរ បើមហោសថពុំជាសត្រូវឡើយ ក៏មហោសថក្រាបទូលថា គួរសំដែងប្រាប់អ្នកនោះ ឈ្មោះដូច្នោះ ៗ ហោង, បើមហោសថជាសត្រូវមែនពិតប្រាកដហើយ មហោសថនឹងក្រាបទូលថា ពុំគួរគប្បីសំដែងប្រាប់អ្នកដទៃ ក្រៃនឹងអាត្មាឯងឡើយ អម្ចាស់នឹងបានជ្រាបនាកាលគ្រាឥឡូវនេះប្រាកដពុំលែងឡើយ ហើយអម្ចាស់នឹងជឿយើងខ្ញុំថាក្រាបទូលពិតប្រាកដ ដោយដំណើរយើងខ្ញុំយល់នោះហោង ៗ ព្រះបាទវិទេហរាជ ស្ដេចស្ដាប់ពាក្យអាចារ្យទាំង ៤ ក្រាបទូលនូវប្រការអម្បាលនោះហើយ ក៏ជឿទទួលយកពាក្យនោះថា គាប់ដូច្នោះហោង, ឯកាធិ.វសំ មានកាលសម័យថ្ងៃមួយគួរ អ្នកប្រាជ្ញទាំង ៤ នូវព្រះបរមពោធិសត្វមហាបុរសរ័តន៍វិសេស ឡើងទៅគាល់អង្គុយក្នុងដំហានមួយ សមគួរនឹងអាត្មា, ទើបព្រះបាទវិទេហរាជបរមបពិត្រ មានព្រះបន្ទូលត្រាស់សួរថា

ហៃអាចារ្យទាំង ៤ អើយ! អញនឹងចង់ដណ្ដឹងនូវអាថិប្រស្នាមួយមានទព្វ័បញ្ចបណ្ណិកបញ្ហាសូត្រ ក្នុងវីសតិនិបាត ហើយស្ដេចសូត្រនូវគាថានេះថា:

បញ្ចបណ្ឌិតា សមាគតា បញ្ហាមេ បដិភាតិ តំ សុណាថ និន្ទិយមត្ថំ បសំសិយំ វា កាស្សេវាវិការេយ្យ គុយ្ហមត្ថិ ។

សេចក្ដីថា: ម្នាលអ្នកប្រាជ្ញទាំង ៥ អើយ! ចូរអ្នកស្ដាប់អញនឹងដណ្ដឹងនូវប្រស្នានេះ រីអស់អ្នកផងទាំងឡាយ គប្បីសំដែងនូវអាថិគួរតិះដៀលក្ដី នូវអាថិគួរសសើរក្ដី នូវអាថិកំបាំងទាំងពួងក្ដី តើគួរសំដែងថ្លែងប្រាប់អ្នកឯណា ? ។

សេនកោ រីអាចារ្យសេនកៈ ស្ដាប់ព្រះបន្ទូល សួរដណ្ដឹងអាថិប្រស្នានូវប្រការអម្បាលនោះហើយ ត្រេកអរក្នុងចិត្តផ្សិតត្រូវនឹងគំនិតហើយទើបទូលថា:

មហារាជ បពិត្រមហារាជអើយ! រីយើងខ្ញុំទាំង ៥ ជាអ្នកប្រាជ្ញសឹងពិចារណាស្រេចប្រពៃដោយគួរទីទៃ ១ ហើយ សូមអម្ចាស់ឆ្លើយប្រស្នានោះជាមុនឲ្យច្បាស់ប្រាកដហើយ ផ្សិតព្រះអង្គជាអធិបតី ជាអម្ចាស់នៃយើងខ្ញុំទាំងឡាយ សឡឹមយើងខ្ញុំឆ្លើយថ្វាយជាឯក្រោយព្រះអង្គវិញ ។

ព្រះបាទវិទេហរាជ ស្ដាប់ពាក្យអាចារ្យសេនកៈនូវប្រការអម្បាលនោះហើយ ស្ដេចនឹងឆ្លើយប្រស្នា ហេតុស្ដេចលោភក្ដីកិលេសតណ្ហានៃអាត្មាហើយមានព្រះបន្ទូលថា:

វីប្រពន្ធឯណា មានសីលប្រព្រឹត្តស្រគត់ស្រគំឥន្ទ្រិយ ស្រដីប្រពៃ គឺអ្នកដទៃលួចពុំបាន ដោយនូវសម្មាគិលេស ដ៏លុះអំណាចចំណង់នៃប្តី សំឡាញ់គាប់ចិត្ត គាប់គួរថ្វៃសំដែងនូវអាចិដំនៀលក្តី ស្រដីសរសើរក្តី នូវសេចក្តីកំបាំងតាំងពួងក្តី គួរគប្បីប្រាប់ប្រពន្ធនោះហោង ។ ស្ដេចមានព្រះបន្ទូលដូច្នោះហើយ ស្ដេចដណ្ដឹងទៅអាចារ្យសេនកៈថា តើព្រះ-ស្តែននឹងថ្វៃប្រាប់នរណា ? ។

ទើបអាចារ្យសេនកៈទូលថា:

មហារាជអើយ! វីក្មេងឯណា គាប់ចិត្តជាពំនាក់សំណាក់បាន គួរគប្បីថ្វៃប្រាប់ក្មេងនោះហោង ។

លំដាប់នោះ, ព្រះមហាក្សត្រ មានព្រះបន្ទូលដណ្ដឹងអាចារ្យបុក្កុសថា ព្រះស្តែនតើគួរថ្វៃប្រាប់នរណា ? ។

ទើបអាចារ្យបុក្កុសក្រាបទូលថា:

បពិត្រមហារាជអើយ! បងប្អូន បើមានសីល ប្រព្រឹត្តស្រគត់ស្រគំឥន្ទ្រិយ គួរសំដែងប្រាប់នូវអាចិដំនៀលក្តី អាចិសេចក្តីកំបាំងក្តី គួរគប្បីប្រាប់ប្អូននោះហោង ។

លំដាប់នោះ, ស្ដេចដណ្ដឹងអាចារ្យកាមិន្ទថា តើព្រះស្តែនគួរសំដែងប្រាប់នរណា? ។ ទើបអាចារ្យកាមិន្ទក្រាបទូលថា:

បពិត្រមហារាជអើយ! បើកូនបាននឹងចិត្ត ស្រគត់ស្រគំឥន្ទ្រិយ ពុំស្រដីឡេះឡោះ ពុំដែលមានមោះនឹងអាតុរទៀយ, គួរថ្វៃនូវអាចិ

ដំណោះដំទៀតក្តី គួរសំដែងអំពើកំបាំងសេចក្តីទាំងឡាយប្រាប់កូននោះហោង ។

លំដាប់នោះ, ព្រះមហាក្សត្រដណ្តឹងអាចារ្យទេវិន្ទថា តើព្រះស្តេចគួរសំដែងប្រាប់នរណា? ។ ទើបអាចារ្យទេវិន្ទក្រាបទូលថា:

បពិត្រមហារាជ ដ៏ជាក្សត្រធំឧត្តមប្រសើរក្រៃលែងក្សត្រផងទាំង·ឡាយអើយ! បើម្តាយនោះរក្សាព្យាបាលកូននោះហើយស្រឡាញ់ពេញចិត្តឥតអ៊ីប្រៀបបាន ពុំដែលស្រដីឲ្យរះភ្នៀសចិត្តកូននោះឡើយ, បពិត្រអើយ! គួរគប្បីប្រាប់ម្តាយនោះហោង ។

កាលនោះ, ព្រះបាទវិទេហរាជ ស្តេចដណ្តឹងអាចារ្យទាំង ៤ ឲ្យឆ្លើយដោយនូវខ្លួនទីទៃ ៗ , ស្តេចជ្រាបសេចក្តីនូវប្រការអម្បាលនោះ ហើយ ស្តេចដណ្តឹងពោធិសត្វថា ហៃមហោសថអើយ! បាយល់ដូចម្តេច? ទើបពោធិសត្វថ្លែងទូលដោយបទគាថា ដូច្នេះថា :

គុយ្ហស្ស ហិ គុយ្ហមេវ សាធុ
ន ហិ គុយ្ហស្ស បសត្ថមាវិកម្មំ
អនិប្ផន្នាយ សហេយ្យ ធីរោ
និប្ផន្នត្ថោ យថាសុខំ ភណេយ្យាតិ ។

ពោធិសត្វទូលថា: ទេវ បពិត្រព្រះកូម៉ុទ្ទូនរិទ្ទូនរនាថ ព្រះបាទនារាយណ៍នរបតី ស្រីសម្មតិទេពក្សត្រថ្លៃប្រសើរអើយ ! វត្ថុកំបាំងឯណាប្រពៃ អ្នកប្រាជ្ញផងទាំងឡាយ ពុំដែលថែងតាយនិយាយប្រាប់អ្នកដទៃ

នៃគ្រឹនអាក្លាងនឡើយ បើអាចកុំបុរំនោះ បានសំរិទ្ធដូចក្តីប្រាថ្នាហើយ គប្បីស្រដីតាមដោយនូវស្រណុកចិត្តហោង ។

ស្តេចស្តាប់ពាក្យពោធិសត្វទូលនូវប្រការអម្បាលនោះហើយ ស្តេចមានព្រះហឫទ័យនោះពុំសប្បាយ ស្ងប់សញ្ចប់ដាក់ព្រះនេត្រា ពុំមានព្រះបន្ទូលអ្វីតទៅទៀតឡើយ ។ សេនកោ រីអាចារ្យសេនកៈ ក៏រម៉ិលមើលព្រះភក្ត្រព្រះបាទវិទេហកដ ។ ឯព្រះបាទវិទេហកដ ក៏រម៉ិលមើលមុខអាចារ្យសេនកៈ ។

ព្រះបរមពោធិសត្វ យល់នូវហេតុអ្នកទាំងអម្បាលនោះហើយ អ្នកគិតថា សមអាចារ្យទាំង ៤ បានឡើងមកក្រាបទូលស្តេច រកបំបែកឲ្យជាសត្រូវនឹងអញដូចអំពីមុនហើយ, រីប្រស្នាអាចារ្យសេនកៈ កាលទៅសួរដណ្តឹងអញដោយនូវសីមា ជាល្បងលនទេតូវ តឲ្យនេះនាំពាក្យនោះមកជាទោសវិញហើយ ។ បពិត្រអើយ ! រីព្រះបាទវិទេហកដ នឹងអាចារ្យទាំង ៤ ព្រមទាំងព្រះពោធិសត្វ លុះដណ្តឹងប្រស្នាក់ចុះងទាំងអម្បាលនោះហើយ, ព្រះអាទិត្យក៏អស្តង្គតដងឹតហើយ លោកឲ្យអុជប្រទីបភ្លឺទាំងព្រះរាជមន្ទីរ, ទើបពោធិសត្វគិតគន់ចិត្តថា នាប៉ហៅកិច្ចព្រះមហាក្សត្រ នឹងជាទម្ងន់ដូចម្តេច ។ ក៏អញនឹងដឹងពុំបានឡើយ, បើដូច្នោះហើយ គួរអញចុះទៅឲ្យឆាប់គាប់ហោង ។ ពោធិសត្វគិតនូវប្រការអម្បាលនោះហើយ ក្រាបថ្វាយបង្គំប្រណម្យលាព្រះមហាក្សត្រចុះចេញ

ទៅ ហើយពោធិសត្វអ្នកគិតថា អាចារ្យទាំង ៤ ក្រោយប្រស្នាព្រះមហា-ក្សត្រ អ្នកខ្លះថាគួរប្រាប់គ្លើ, អ្នកខ្លះថាគួរប្រាប់ប្អូន, អ្នកខ្លះថាគួរប្រាប់កូន, អ្នកខ្លះថាគួរប្រាប់ម្តាយ, រីអាថ៌កំបាំងអាចារ្យទាំង ៤ នាក់នេះ គាត់បានស្រដីនិយាយគ្នាប្រាកដឯងមិនទេឡើយ, រីអញក៏នឹងដឹងអំពើអ្នកទាំង ៤ នាថ្ងៃនេះឯងប្រាកដពុំលែងឡើយ ។ រីអ្នកប្រាជ្ញទាំង ៤ នោះ បើចុះអំពីគាល់ព្រះមហាក្សត្រអំពីមុនរៀងមក តែងទៅអង្គុយលើខ្នងអាងបាយ និយាយគ្នានៅខាងទ្វារព្រះរាជវាំង ហើយទើបហួសទៅផ្ទះរៀង ៗ ហោង, ពោធិសត្វអ្នកគិតយល់ហេតុនូវប្រការអម្បាលនោះហើយ ទើបអ្នកប្រើបុរសជាបរិវារឲ្យយកកំពលមកក្រាលក្រោមអាងបាយនោះ ហើយពោធិសត្វចូលទៅក្រោមអាងបាយ ហើយផ្តាំនឹងបុរសនោះថា បើអាចារ្យទាំង ៤ ហួសចុះទៅ ព្រះស្តែងមកបើកយកអញចេញអំពីក្រោមអាងនោះ បុរសជាបរិវារស្តាប់ពាក្យពោធិសត្វដូច្នោះហើយ បុរសនោះក៏ថយឆ្ងាយចេញទៅចាំឃ្លាំមើល ដូចបណ្តាំពោធិសត្វផ្តាំនោះហោង ។ សេនកោ រីអាចារ្យសេនកៈយល់ពោធិ-សត្វទៅហើយ ក្រាបទូលថា មហារាជ បពិត្រមហារាជអើយ ! អម្ចាស់មិនជឿពាក្យយើងខ្ញុំ ឥឡូវនេះប្រាកដមែនដូចយើងខ្ញុំទូលឬទេ ? ព្រះបាទវិទេហរាជ ស្តាប់ពាក្យអាចារ្យសេនកៈទូលបំបែកដូច្នោះហើយ ស្តេចពុំបានពិចារណាឡើយ ក៏គិតភ័យ ស្តេចដណ្តឹងទៅអាចារ្យសេនកៈ

ថា អាចារ្យសេនកៈអើយ ! ឥឡូវនេះ យើងនឹងធ្វើម្ដេច ? ។ អាចារ្យសេនកៈក្រាបទូលថា មហារាជ បពិត្រមហារាជអើយ ! គំនិតនេះ មិនគួរឲ្យអ្នកដទៃដឹងដល់តិចឡើយ កុំបង្អង់លង់ឡើយ, យើងខ្ញុំនឹងសម្លាប់កុមារគហបតីឲ្យស្រឡះជ្រះមន្ទិល ដ្បិតវាជាសត្រូវនឹងព្រះអង្គ ។ ស្ដេចស្ដាប់ពាក្យអាចារ្យសេនកៈទូលដូច្នោះហើយ ស្ដេចចាប់ព្រះខាន់ហូតហុចទៅអាចារ្យសេនកៈ ហើយមានព្រះបន្ទូលថា ហៃអាចារ្យសេនកៈអើយ ! អ្នកឯណាដទៃ នាំបើហៅនឹងចង់ឲ្យប្រយោជន៍ដល់អញនេះ ឥតអ្នកមានឡើយ, មានតែព្រះស្នងឯង ចូរព្រះស្នងយកទូវដាវនោះទៅ ហើយព្រះស្នងប្រើបុរសឯណាស្និទ្ធនឹងចិត្តស្មើអាត្មាព្រះស្នង ហើយព្រះស្នងផ្ដាំថា ឲ្យកាន់ដាវនេះទៅ ហើយព្រះស្នងប្រើបុរសឯណាមួយឈរខាងលើផ្ទែកមាត់ទ្វារ ហើយបើមហោសថបុត្រគហបតីចេញពីមាត់ទ្វារ នឹងឡើងមកបំរើអញព្រឹកនេះហើយ ចូរអ្នកទាំងឡាយកាត់ក យកក្បាលមហោសថ នាំឡើងមកថ្វាយអញនាព្រឹកនេះឯងហោង ។ (គេចត្តារោ បណ្ឌិតា) វិអ្នកបណ្ឌិតទាំង ៤ ក្រាបថ្វាយបង្គំប្រណម្យទូលថា ទេវ បពិត្រមហារាជអើយ ! កុំព្រះអង្គព្រួយព្រះរាជហឫទ័យឡើយ យើងខ្ញុំទាំង ៤ នឹងសម្លាប់មហោសថថ្វាយព្រះអង្គ, ហើយអាចារ្យទាំង ៤ លាចុះទៅអំពីព្រះរាជមន្ទីរ ទៅអង្គុយលើខ្នងអាងហ្វាយនោះ ទើបអាចារ្យសេនកៈស្រដីថា ឥឡូវនេះ ខ្នងនៃសត្រូវយើងយល់

ហើយ ម្នាលគ្នាយើងអើយ ! យើងសម្លាប់កូនគហបតីនេះឲ្យបាន លុះ នៅដោយបំណងយើងហោង ៗ អាចារ្យទាំង ៣ ធ្វើជាកោតខ្លាចអាចារ សេនកៈហើយស្រដីថា មានតែអម្ចាស់ឯងទេ ទើបគិតការធ្ងន់នេះបាន ៗ ឯដ៏កាលនោះ អាចារ្យសេនកៈដណ្តឹងទៅអាចារ្យទាំង ៣ ថា កាលអ្នក ទូលព្រះមហាក្សត្រថា អាថ៌កំបាំងសំដែងប្រាប់កូន, ប្រាប់ប្អូន, ប្រាប់ ម្តាយ, ឥឡូវនេះ ឋានស្ងាត់ឥតអ្នកឯណាទឹងបានឮដល់មួយឡើយ, កំយើងទឹងសំដែងប្រាប់គ្នាឲ្យបានដឹង, ទើបអាចារ្យទាំង ៣ ស្រដីថា ចូរ អ្នកសំដែងមុនទើបអាចារ្យសេនកៈថា អាថ៌កំបាំងខ្ញុំនេះ បើមហោសថដឹង ហើយ សមទឹងពាំពាក្យនេះទៅទូលស្តេច ៗ ជ្រាបហើយ រីជីវិតនៃខ្ញុំឥត អង្គឹមានឡើយ ។ អាចារ្យទាំង ៣ ថា នៃអាចារ្យអើយ ! កុំបីខ្លាចឡើយ នាបីហៅថាទឹងបែកនៃក្តីកំបាំងឮចេញពីឋាននេះឥតអង្គឹមានឡើយ, ចូរ អ្នកថ្លែងប្រាប់មកហោង ៗ អាចារ្យសេនកៈគោះទូរបាតអាងបាយនោះ នឹងក្រឹកថា ក្រែងកូនគហបតីមកលបពួននៅក្រោមបាតអាងបាយនេះ ៗ រីអ្នកប្រាជ្ញទាំង ៣ ស្រដីថា នៃអ្នកអាចារ្យអើយ ! កូនគហបតីនោះ កំអួតគិតតូចអី មិនគួរគេប្បីទឹងមកចូលនៅក្រោមឋានមានសភាពដូច្នេះ ធ្លាប់នៅលើឥស្សរសម្បត្តិនោះ គាត់ទឹងមកកេអ៊ីនៅក្រោមនេះ ចូរអ្នក ថ្លែងសំដែងទូរអាថ៌កំបាំងនោះកុំបារម្ភឡើយ ៗ

(នៅមានត)

# អំពីទង់ពុទ្ធសាសនា

លោក ជង់-វង់ រៀបរៀង

---

តាំងពីព្រះសម្ពុទ្ធបរមគ្រូ ទ្រង់បរិនិព្វានទៅ ពុំទាន់មានប្រទេសជាពុទ្ធសាសនិកណាមួយ បានផ្ដើមបង្កើតទង់ពុទ្ធសាសនាឲ្យមានរូបរាងឡើងជាពិតប្រាកដ ដូចក្នុងប្រពៃណីឯទៀតៗ នោះទេ ។

លុះដល់ថ្ងៃអង្គារ ៦ កើត ខែជេស្ឋ ឆ្នាំខាល ទោស័ក ព.ស.២៤៩៤ ត្រូវនឹងថ្ងៃទី ៦ ខែមិថុនា គ.ស. ១៩៥០ ទើបពុទ្ធិកប្រទេសទាំង ២៩ មានប្រទេសស្រីលង្កាជាដើម បានបង្កើតពុទ្ធិកសមាគមពិភពលោក ហើយបានធ្វើសន្និសីទលើកទី ១ នៅប្រទេសស្រីលង្កា ដែលគណៈប្រតិភូខ្មែរយើង មានសម្ដេចព្រះមហាសុមេធាធិបតី ( ជួន-ណាត ) ជាតញ្ញាណ សង្ឃនាយកគណៈមហានិកាយជាប្រធានទៅរួមប្រជុំផង បានមូលមតិគ្នា បង្កើតទង់ពុទ្ធសាសនាឡើង ហៅថា "ទង់ពុទ្ធិកសមាគមពិភពលោក" តាមលក្ខន្តិកៈនៃសមាគមនេះ ដែលមាន ២៧ មាត្រា, ត្រង់មាត្រាទី ២៦ ចែងថា ៖

"ទង់របស់ពុទ្ធិកសមាគមពិភពលោក ជាទង់មានពណ៌ ៦ តម្រូវ

ទង់ឆព្វណ្ណរង្សី របស់ព្រះសម្ពុទ្ធជាម្ចាស់ ទុកជាមូលដ្ឋានតាមគំរូដែលក្រុមប្រឹក្សាប្រតិបត្តិការបានធ្វើហើយ" ។

ដូច្នេះ ទង់ពុទ្ធសាសនា ក៏ឧប្បត្តិឡើងជាស្ថាពរតាំងពីកាលនោះមក ។

ទង់ពុទ្ធសាសនា មាន ៦ ពណ៌នោះគឺៈ ១- ខៀវ, ២- លឿង, ៣- ក្រហម, ៤- ស, ៥- ហង្សបាទ (ជម្ពូទុំដូចជើងហង្ស), ៦- ផ្លេក (ពន្លឺពេជ្រ) = (គឺគេយកពណ៌ទាំង ៥ ខាងដើមមួយ ៗ មកដាក់បញ្ចូលគ្នាក្នុងផ្ទាំងទី ៦ នេះ ជា ១ ពណ៌) ។

ព្រះបរមលោកនាថ ព្រះអង្គមានរស្មី ៦ ពណ៌ផ្សាយចេញពីព្រះវរកាយយ៉ាងនេះ ដោយលទ្ធផលនៃទានបរមត្ថបារមី ដែលព្រះអង្គបានសាងមកពីអតីតកាលយ៉ាងមហាស្ចារ្យ ហើយដែលមិនអាចអ្នកណាមួយធ្វើដូចព្រះអង្គបាន ។

ឯរស្មីមួយ ៗ ជាដំណាងព្រះជាតិមួយ ៗ គឺៈ

១- រស្មីពណ៌ខៀវៈ ជាដំណាងព្រះអង្គ កាលទ្រង់សោយព្រះជាតិជាព្រះបាទស្រីគិកស្រ្ត ។ កាលនោះ ព្រះឥន្ទ្រាធិរាជបាននិម្មិតខ្លួនជាព្រាហ្មណ៍ចាស់ម្នាក់ ចូលមកសូមព្រះនេត្រព្រះអង្គទាំងគូ ។ ព្រះអង្គទ្រង់ឆ្កៀលព្រះនេត្រទាំងពីរឲ្យទៅឥន្ទព្រាហ្មណ៍ ។

២- រស្មីពណ៌លឿងៈ ជាដំណាងព្រះអង្គ កាលទ្រង់សោយព្រះជាតិជាវិធុរបណ្ឌិត ។ កាលនោះ ព្រះឥន្ទ្រាធិរាជបាននិម្មិតខ្លួនជាយក្សធ្វើជាងមាស ។ វិធុរបណ្ឌិត បានអារសាច់ខ្លួនឲ្យជាងមាស ដើម្បីដំដែធ្វើជាមាសបិទព្រះពុទ្ធរូប ។

៣- រស្មីពណ៌ក្រហមៈ ជាដំណាងព្រះអង្គ កាលទ្រង់សោយព្រះជាតិជាបទុមមាណព ។ គ្រានោះ មានពស់មួយប្រកបដោយពិសដ៏ពន្លឹក ចឹកមាតាព្រះអង្គ ។ ទ្រង់យកកាំបិតមកពុះទ្រូង លូកយកបេះដូងមកផ្សំថ្នាំមើលមាតាឲ្យគង់ជីវិត ។

៤ រស្មីពណ៌សៈ ជាដំណាងព្រះអង្គ កាលទ្រង់សោយព្រះជាតិជាព្រះបាទវេស្សន្តរ បានប្រទានដំរីមង្គលមួយ ជាសត្វសម្រាប់កម្សាន្តដ៏មានអវយវៈសសុទ្ធ ដល់ពួកព្រាហ្មណ៍កលិង្គរដ្ឋ ពួកអ្នកនគរនាំគ្នាខឹង បំបរបង់ព្រះអង្គឲ្យទៅនៅនាវង្កតបពិត ។

៥- រស្មីពណ៌ហង្សបាទៈ ជាដំណាងព្រះអង្គ កាលទ្រង់សោយព្រះជាតិជាវិជ្ជាធរ ។ មាតាព្រះអង្គត្រូវយក្សចាប់យកបាន, ព្រះអង្គទ្រង់អារសាច់ឲ្យយក្សបរិភោគដំនួសជីវិតមាតា ។

៦- រស្មីពណ៌ផ្លេកៈ ជាដំណាងព្រះអង្គ កាលទ្រង់សោយព្រះជាតិជាទន្សាយឈ្មោះសោមបណ្ឌិត មានព្រះកម្លាំងសទ្ធាចង់បំពេញទាន ។

គ្រានោះ ព្រះឥន្ទ្រាធិរាជបាននិម្មិតខ្លួន ជាព្រាហ្មណ៍ចាស់ម្នាក់អត់អាហារដើរចូលមក ។ ទន្សាយសោមបណ្ឌិត បានលោតចូលក្នុងភ្នក់ភ្លើង ដើម្បីចំអិនសាច់ព្រះអង្គឲ្យដល់ឥន្ទព្រាហ្មណ៍បរិភោគ ។

ស្នាមទាំង ៦ ពណ៌នេះ បានផ្សាយចេញអំពីព្រះវរកាយនៃព្រះអង្គ ក្នុងពេលត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណ, ក្នុងពេលសំដែងបាដិហារ្យ ដើម្បីបំបាក់បង់នូវអស្មិមានះ នៃព្រះញាតិរបស់ព្រះអង្គ ដែលសំគាល់ថា ព្រះអង្គជាមនុស្សនៅក្មេងមិនគួរគោរព នឹងក្នុងពេលដែលព្រះអង្គទ្រង់ធ្វើយមកបាដិហារ្យផ្ចាញ់ពួកតិរ្ថិយ លើដើមគណ្ឌាមព្រឹក្ស ( ដើមស្វាយរបស់នាយគណ្ឌៈ ) ។

ដូច្នេះហើយ បានជាពុទ្ធិកសមាគមពិភពលោក ដែលធ្វើនៅប្រទេសស្រីលង្កាលើកទី ១ នោះ ផ្ដើមធ្វើទង់ពុទ្ធសាសនា មាន ៦ ពណ៌តម្រូវនឹងឆព្វណ្ណរង្សីរបស់ព្រះសម្ពុទ្ធជាម្ចាស់ ។

# ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ ខ្មែរគួរក្រវើន
ឲ្យរីកចម្រើន គង់វង់គត់មត់ ។
ព្រោះអក្សរជាតិ គោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ ។

ប.ព.

## វិធី ១ៈ ក្នុងការកសាងវប្បធម៌

លោក លី-ធាមតេង រៀបរៀង

( គតិលេខ ១១ ឆ្នាំ ១៩៦១ ទិងបប់ )

---

ក្នុងទស្សនាវដ្ដីយើងលេខមុន យើងបានចុះម្ដងហើយ អំពីវិធី១ៈ ក្នុងការកសាងវប្បធម៌ ដែលកាលនោះ យើងបានចែកជាពីរផ្នែកគឺៈ ទី ១ ផ្នែកស្រាវជ្រាវវប្បធម៌ចាស់ដែលមានមកស្រាប់ និងទី ២. ផ្នែកបង្កបង្កើតវប្បធម៌ថ្មីដែលមិនទាន់មាន ។ ផ្នែកទី ១ យើងបានពោលរ៉ាយរ៉ាប់ក្បោះក្បាយរួចមកហើយ ឥឡូវយើងត្រូវពោលពីផ្នែកទី ២ ទៀត ។

ផ្នែកនេះ ក៏មានសារៈសំខាន់ ហើយជាការចាំបាច់ណាស់ដែរ គឺយើងជៀសរាងពីសេចក្ដីខ្វះខាតក្នុងបែបបទសិក្សា សំរាប់ឲ្យជនជាតិយើងទាន់កាលៈទេស ដូចអារ្យប្រទេសនានា ។ ខសំខាន់ជាកម្មវត្ថុ នៃផ្នែក

ទី ២ នេះគឺ មានមុខងារកែរកតាមបែបវិទ្យាសាស្ត្រ (Etudes scientifigues) ដើម្បីប្រមូលក្រនូវចំណេះវិជ្ជាសព្វសារពើ ដែលខ្មែរយើងមានមកស្រាប់ពីបុរាណ ហើយផ្សំជាសំយោគវិធី ជាមួយនឹងវិជ្ជាទំនើបថ្មី ដែលអ្នកប្រាជ្ញបច្ចុប្បន្នបានរកឃើញជាលំដាប់ ៗ ឧទាហរណ៍ដូចជា៖ អក្សរសាស្ត្របុរាណ ផ្សំនឹងអក្សរសាស្ត្រទំនើបថ្មី, សិល្បបុរាណ ផ្សំនឹងសិល្បៈថ្មីៗ, ការផ្សាយព្រះពុទ្ធសាសនាតាមវិធីចាស់ នឹងការផ្សាយបែបថ្មី ផ្អែកទៅលើគោលវិទ្យាសាស្ត្រជាដើម ។

ហេតុបានជាយើងយល់ថា គប្បីឲ្យមានការកែនូវវិធីបែបថ្មី ៗ ដោយបញ្ចូលវប្បធម៌ចាស់នឹងវប្បធម៌ថ្មីតាមបែបសំយោគវិធី (Synthèse) នឹងផ្លាស់ប្តូរវិធីឃោសនា ឲ្យមានភាពជាក់ស្តែង តាមវិទ្យាសាស្ត្រដូចនេះ ព្រោះយើងយល់ថា សន្តានចិត្តយុវជនសម័យថ្មីនឹងយុវជនអ្នកសិក្សាពីដើម មានបរវត្តប្លែកគ្នា ដ្បិតនៅសម័យបច្ចុប្បន្ន កុមារភាពតែងបានទទួលនូវការអប់រំពីគ្រប់មជ្ឈដ្ឋានច្រើនជាងកាលពីសម័យព្រេងនាយ ៗ ដូច្នេះ ក្មេងទាំងនោះតែងមានការពិចារណាច្រើនជាងក្មេងពីដើម បានសេចក្តីថា បើមុននឹងកប្រគល់ចិត្តទៅក្នុងជំនឿអ្វីមួយ ៗ វាតែងពិចារណារកហេតុផលឲ្យឃើញភាពសមរម្យសក្តិសិទ្ធិជាមុនសិន ៗ ប្រសិនណាជាជំនឿនោះ

ជាជំនឿតទ្ទិមានហេតុមានផលពិតមែន ទើបគេនាំគ្នាជឿហើយនាំគ្នាអនុវត្ត តាមទ្រឹស្ដី តាមជំនឿនោះទៅ ផ្ទុយទៅវិញ បើគេពុំឃើញមូលហេតុជាសភាពពិតជាក់ស្ដែងទេ គេក៏តែងនាំគ្នាវាយលចិត្តឆ្ងាយពីជំនឿ (Croyances) ទាំងនោះបន្តិចម្ដង ៗ រហូតដាច់ស្រឡះ ។ មានការគួរសង្កេត ១ បែបទៀតគឺថា បើទោះបីជាវប្បធម៌ចាស់យើងមានរូបរាងជាក់ប្រាកដជាបែបបទសិក្សាស្រាប់មកហើយក៏ដោយ បើយុវជនអ្នកសិក្សាពុំបានយល់ពីលក្ខខ័ណ្ឌក្បួនខ្នាតនោះជាក់លាក់ទេ គេក៏មុខជាយល់ច្រឡំថា «ជាតិយើងពុំមានក្បួនខ្នាតទាំងនេះជាក់លាក់ទេ ដោយគេពុំឃើញអ្វីជាគោលចារឹកសោះ» ។ បើមតិច្រឡំនេះកើតឡើងដរាបណា ដរាបនោះប្រាកដជាមានការអនុវត្តន៍តាមន័យច្រឡំជាមិនខានដែរ ទឹងនាំឲ្យអ្នកសិក្សាទាំងនោះដៀលត្មះបុព្វបុរសយើងថា មិនចេះគិតគូរចងក្រងក្បួនខ្នាតអ្វីទុកមកសោះនាំឲ្យគេពិបាករកគោលចារឹកអ្វីរៀនសូត្រគ្មាន ៗ មិនតែប៉ុណ្ណោះ ផលអាក្រក់មួយទៀតកើតមកជាមួយនោះដែរ គឺអ្នកសិក្សានោះឯង បែរជាស្រវាទៅរកក្បួនខ្នាតរបស់ជាតិដទៃមកកាប់អាខថា ជាវត្ថុឆើតឆាយគប្បីនាំគ្នារៀនសូត្រតាមទៅវិញជាមិនខាន ហើយថែមទាំងប្រមែប្រមូលយកក្បួនខ្នាតបរទេសទាំងនោះមកទុកដាក់ថាជាលក្ខគោល ដែលគេនាំគ្នា

និងមិនឲ្យតម្លៃដ៏លើសលុប ។

បើនិងពិនិត្យតាមដំណើរហូរហែ ដូចបញ្ជាក់មកនេះ យើងឃើញថា ការៈយើងបច្ចុប្បន្នគង់ដំណើរកសាងជាតិ ក៏គប្បីនិយមទុកដាក់ថា បញ្ហាកសាងវប្បធម៌ឲ្យមានក្បួនខ្នាតគ្រប់គ្រាន់សំរាប់សិក្សា, សំរាប់ផ្សាយទូទៅក្នុងស្រុកក្តី ក្រៅស្រុកក្តី, ជាបញ្ហាបន្ទាន់មួយដែរ ព្រោះដំណើរទៅរកវឌ្ឍនធម៌ គោងតែឲ្យបានស្របគ្នាគ្រប់ចង្កាក់ទាំងអស់ បើភ្លេចចោលឲ្យខ្វះចន្លោះត្រង់ណាមួយ ក៏ជាហេតុនាំឲ្យទៅសល់ការយឺតយ៉ាវពុំល្អមើលដែរ ។ សមបើ ផ្នែកវប្បធម៌នេះ ជាផ្នែកបណ្តុះសតិស្មារតីដែលជាមូលដ្ឋានគំនិតបញ្ញាអ្នកស្រុកផងនោះ យើងយល់ថា រឹតតែជាការចាំបាច់បន្ទាន់ណាស់ទៅទៀត ដើម្បីលើកតម្លៃមុខមាត់ មុខវិជ្ជានេះទាំងខាងក្នុងប្រទេសទាំងខាងក្រៅប្រទេស ។ ប្រហែលជាដោយផ្អែកទៅលើការយល់ចំពោះសភាពចាំបាច់ដូច្នេះហើយ បានជាប្រទេសខ្លះដែលជាប្រទេសកសាងជាតិថ្មី ៗ ដែរ គេបានលៃលកឲ្យមានក្រសួងមួយទទួលការពិសេសតែផ្នែកវប្បធម៌ (Ministère de la Culture) ដោយមានមុខងារស្រាវជ្រាវចងក្រង និងផ្សាយទូទៅដោយឡែកពិសេសពីផ្នែកសិក្សាធម្មតា (Enseignement) ព្រោះក្រសួងនេះ មានមុខងារបង្ហាត់បង្រៀន

យ៉ាងធ្ងន់ធ្ងរណាស់ទៅហើយ ដូចជាយើងឃើញក្រសួងសិក្សាធិការនៅប្រទេសយើងជាអាទិ៍ ដែលសព្វថ្ងៃនេះ ការសិក្សានៅប្រទេសយើងតាមការឧបត្ថម្ភដ៏ពេញទំហឹងនៃរដ្ឋាភិបាលសង្គមរាស្ត្រនិយម ក្រោមព្រះរាជ-កិច្ចដឹកនាំយ៉ាងភ្លឺស្វាង នៃសម្តេចសហជីវិនព្រះប្រមុខរដ្ឋ ជាទីគោរពនៃយើង, កំពុងតែរីកសាយភាយពាសពេញទិសទីក្នុងព្រះរាជអាណាចក្រតាំងពីបឋមសិក្សា, មធ្យមសិក្សា រហូតដល់ឧត្តមសិក្សាថែមទៀត ។

ក្នុងទស្សនាវដ្តីយើង លេខក្រោយៗទៀត បើពុំមានអ្វីជាឧបសគ្គទេ យើងល្បងលើកយកបញ្ហាដ៏ទូលំទូលាយក្នុងអារ្យធម៌ទូទៅ មកធ្វើអត្ថាធិប្បាយបន្តិចម្តងៗតទៅទៀត ដើម្បីពង្រីកស្មារតីអ្នកអានយើងឲ្យរឹតតែភ្លឺស្វាងច្បាស់ឡើង តាមលទ្ធភាពសព្វស្តើងរបស់យើង ។

# ពាក្យខ្មែរប្រែចេញពីបរទេស

## ដោយគណៈកម្មការវប្បធម៌

(គតិលេខ ១១ ឆ្នាំ១៩៦១)

| | | |
|---|---|---|
| Dysenterie amibienne | | រោគមូល |
| Dysenterie bacillaire | | រោគមូលរាក |
| Peste | *n.f.* | ពិសប៉េស្ត |
| Fièvre jaune | *n.f.* | គ្រុនលឿង |
| Infection puerpérale | | ជម្ងឺក្រឡាភ្លើង |
| Ophtalme des nouveaux-nés | | ជម្ងឺភ្នែកទារក |
| Rougeole | *n.f.* | កញ្ជ្រិល |
| Fièvre de malte | | គ្រុនម៉ល្តិ |
| Lèpre | *n.f.* | ឃ្លង់ |
| Fièvre récurrente | | គ្រុនលស់ |
| Respect | *n.m.* | គារវៈ |
| Vénération | *n.f.* | សក្ការភាព |
| Révérence | *n.f.* | គរុការភាព |
| Egard | *n.m.* | មានទភាព |
| Considération | *n.f.* | សេចក្តីរាប់រក |
| Déférence | *n.f.* | សេចក្តីរាប់អាន |
| Hommage | *n.m.* | សាទរភាព |

(នៅមានត)

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

*ព្រះមហា ទាំង . ទាត់ រៀបរៀង*

(តពីលេខ ១១ ឆ្នាំ ១៩៦១)

---

អតិលុទ្ធ គុ. ដែលលោភក្រៃលែង ។ *អតិលុទ្ធា,* ស្រី. សេចក្តីលោភក្រៃលែង ។

អតិលោភ បុំ. សេចក្តីលោភក្រៃលែង ។ *អតិលោភតា* ស្រី. ការនៃសេចក្តីលោភក្រៃលែង ។

អតិលោម គុ. ដែលមានរោមក្រៃលែង, ដែលមានរោមច្រើន ។

អតិលោល គុ. ដែលឡេះឡោះក្រៃពេក, ដែលរេវតរេវាតក្រៃពេក ។

អតិលោលុប គុ. ដែលចង់បានក្រៃពេក ។

អតិលោហិត អតិលោហិនី គុ. ដែលក្រហមក្រៃលែង, ដែលក្រហមឆ្អៅ ។

អតិលោល្យ នបុំ. សេចក្តីប្រាថ្នាក្រៃលែង ។ *អតិលោល្យវន្ត* គុ. ដែលមានសេចក្តីប្រាថ្នាក្រៃលែង ។

អតិវក្ត្ឫ ៣. ន. អ្នកនិយាយក្រៃលែង. អ្នកនិយាយច្រើន, អ្នកមើលងាយ ។

អតិវាទី ៣គុ. និយាយក្រៃលែង. គេះដៀល, និយាយបរដើម ។

អតិវិក្លវ គុ. ដែលមានចិត្តជាប់ទីងក្លួកទ្វំ (*គោ*) គុ. ដែលមានចិត្តទន់ភ្លន់ ។

*(នៅមានត)*

# រឿងសាមកុក

## កណ្ឌទី ៤៦

ឧកញ៉ាវិបុលរាជសេនា ញ៉ុក-ថែម ប្រែរៀបរៀង

( តពីលេខ ១១ ឆ្នាំ ១៩៦១ )

---

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាសបើបានអាន
> នឹងចេះឧបាយកលចំណាន
> ទាំងមានសន្តានស្នេហាជាតិ
>
> យូ - អ៊ុន

លុះថ្ងៃបានឫក្សជោគជ័យល្អ នាងងីកុកថៃ ក៏ឲ្យរៀបតុតាំងលៀង អាហារអស់បណ្ដានាម៉ឺនសព្វមុខមន្ត្រី ហើយនឹងរៀបវិវាហមង្គលឡៀវពី នឹងនាងស៊ុនហ៊ូយិនតាមប្រវេណី លុះវេលាយប់បណ្ដានាម៉ឺនក៏លាត្រឡប់ ទៅផ្ទះរៀងខ្លួន នាងងីកុកថៃ ក៏អុចទៀនបំភ្លឺទាំងសងខាងមាគ៌ាតាំងពីទី លំនៅឡៀវពី រហូតទៅដល់បន្ទប់នាងស៊ុនហ៊ូយិន ហើយឲ្យចាស់ទុំនាំ ឡៀវពីចូលទៅរួមដំណេកនឹងនាងស៊ុនហ៊ូយិន លុះឡៀវពីដើរដល់កន្លែង នាងស៊ុនហ៊ូយិននៅ ក៏ឃើញសុទ្ធតែពួកស្រីទាំងពួងតែងខ្លួនសៀតក្រប៊ី ដូចពួកទាហានចូលច្បាំងក្នុងសង្គ្រាម ហើយឃើញគ្រឿងសាស្ត្រាវុធ

ផ្សេង ៗ រៀបបញ្ជូរញ្ជូរទុកជាច្រើន ទៀតពីភ័យតក់ស្លុតឈរស្ងាំងកាំង ៗ

ស្រីចាស់ម្នាក់និយាយនឹងទៀតពីថា លោកកុំភ័យ ! នាងស៊ិនហ៊ិយ៉ិននេះ តាំងពីតូចមក ចូលចិត្តតែហាត់រៀនខាងក្បួនអាវុធបែបពួកពីជ័យសង្គ្រាម ហើយចូលចិត្តមើលទាហានកាន់គ្រឿងអាវុធ ចូលប្រយុទ្ធគ្នា បានជាវេលានេះ នាងក៏ហ្វឹកហាត់ពួកស្រ្តីឲ្យកាន់ក្របី នឹងចូលតយុទ្ធគ្នាដោយគ្រឿងអាវុធផ្សេង ៗ ឲ្យលោកមើល ទៀតពីថា ឯការកាន់គ្រឿងអាវុធច្បាំងគ្នានេះ មិនជាការគួរសមនឹងឲ្យនាងស៊ិនហ៊ិយ៉ិនមើលសោះ ព្រោះចិត្តខ្ញុំជាអ្នកញញើតខ្លាចណាស់ ឲ្យប្រមូលរៀបលាក់ទុកឲ្យអស់ទៅ ស្រីចាស់នោះក៏ចូលទៅប្រាប់នាងស៊ិនហ៊ិយ៉ិន ៗ ឮដូច្នោះក៏អស់សំណើចហើយថា ធ្វើការសង្គ្រាមមកដល់អាយុប៉ុណ្ណេះហើយ ឃើញគ្រឿងសាស្ត្រាវុធត្រឡប់ជាខ្លាចវិញ ហើយនាងក៏បង្គាប់ពួកស្រីបំរើទាំងឡាយឲ្យប្រមូលគ្រឿងអាវុធទាំងអស់នោះយកទៅទុកដាក់អស់ ហើយក៏អញ្ជើញទៀតពីចូលទៅដល់ដំណេកនាងស៊ិនហ៊ិយ៉ិន អ្នកទាំង ២ ក៏បានរួមសុខទុក្ខនឹងគ្នាតាមប្រពៃណីធម្មតាជាទីសោមនស្សស្មោះសរទៅវិញទៅមកៗ លុះនៅនឹងគ្នាយូរថ្ងៃ ទៀតពីក៏រៀបចំចំណាយរបស់ទ្រព្យសព្វគ្រឿងមាសប្រាក់ ឲ្យជាបំណាច់រង្វាន់ពួកស្រីបំរើក្នុងទីនោះជាច្រើនគ្រប់ ៗ គ្នា ប្រាថ្នានឹងចងចិត្តឲ្យគិតកប់អានស្រឡាញ់ខ្លួន ហើយក៏ប្រើស៊ិនខៀនឲ្យនាំពាក្យមានទាំងពួងទៅដកបទុងបេងឯស្រុកកេងជីវគ្រប់ប្រការ ៗ

ឯស៊ុនគួនសរសេរសំបុត្រឲ្យដំណឹងទៅជ័រយ៉េ នៅស្រុកឆសឹងគុន តាមហេតុទាំងពួងគ្រប់ប្រការ ជ័រយ៉េដឹងហើយ ក៏តូចចិត្តគិតបរិវិតក្កៈពន់ប្រមាណ ទើបរិះគិតគលឧបាយបានម្យ៉ាងទៀត ក៏ឆ្លៀតសរសេរសំបុត្រផ្ញើមកស៊ុនគួនសេចក្តីថាៈ ពីដើមខ្ញុំគិតធ្វើការនេះ ប្រាថ្នានឹងធ្វើអន្តរាយឡៅតី ដើម្បីនឹងទារយកស្រុកកេងជ័រមកវិញប៉ុណ្ណោះ ការដែលគិតធ្វើនោះក៏ត្រឡប់ជាខុសខាងយើង ឲ្យបានចំណេញទៅខាងឡៅតីទៅវិញ ដូច្នេះតម្រេះរបស់ខ្ញុំនឹងគិតរកឧបាយតទៅទៀត តែថាឡៅតីនេះ ជាមនុស្សមានតម្រេះប្រាជ្ញាណាស់ ធ្វើកិរិយាខាងក្រៅជាល្អពេះ-កយនឹងអាណាប្រជានុរាស្ត្រទាំងឡាយទូទៅ សមបានខុនបេងមកជាប្រឹក្សាជំនំថែមទៀត មានទាំងគួនអ៊ូ, ទៀវហ៊ុយ, ជូឡុងជានាយទាហានឯក មុខជាមិនមែនទៅនៅក្រោមបង្គាប់អ្នកឯណា ការនេះសុំឲ្យលោកប្រើប្រាជ្ញាប្រលោមយកខ្លួនឡៅតី ឲ្យកាន់កាំងវង្វេងនៅក្នុងស្រុកគងជី ដំណតទៅ ឡៅតីនឹងភ្លេចបោះបង់ខុនបេង, គួនអ៊ូ, ទៀវហ៊ុយ, យើងនឹងលើកទ័ពទៅវាយយកស្រុកកេងជ័រ គង់នឹងសម្រេចបានដោយងាយ បើឡៅតីត្រឡប់ទៅស្រុកវិញបាន ក៏ដូចលែងត្រីទៅក្នុងសមុទ្រ គង់គិតត្រឡប់ធ្វើជាសត្រូវទៅថ្ងៃមុខ ឲ្យលោកពីគ្រោះមើលតាមគួរចុះ ហើយក៏ប្រើទាហានឲ្យកាន់សំបុត្រនោះទៅឲ្យស៊ុនគួនឯស្រុកឡាំស៊ី ។

ស៊ិនគួនទទួលសំបុត្រនោះមើលដឹងសេចក្ដីហើយ ក៏ឲ្យហៅទៀវលៀវមកប្រឹក្សា ទៀវលៀវក៏និយាយនឹងស៊ិនគួនថា សេចក្ដីដែលដីវយ៉ើគិតល្អណាស់ ត្រូវនឹងគំនិតខ្ញុំបាទដែរ សុំឲ្យលោកសាងគ្រឹះស្ថានមួយឲ្យឡៅពីនៅ ហើយជីកជាស្រះស្រង់ដាំព្រលិតលំចង់ស្បន្ក៏ដ នឹងឈូកសឈូកប្រាលគ្រប់ពណ៌ រួចធ្វើជាសួនច្បារដាំផ្កា ដែលមានក្លិនក្រអូបក្រអៃបសព្វទិសា ជ្រើសរើសរកស្រីកញ្ញា ដែលមានរូបឆោមលោមពណ៌ល្អឲ្យបំរើបម្រាស់ឡៅពី ជាទីតម្រេកត្រេកត្រអាល ឯឡៅពីជាមនុស្សចិត្តស្រាលធ្លាប់ចិលក្រមកយូរហើយ មិនធ្លាប់មានរុងរឿង បើយើងទុកបំរុងឲ្យច្រើនសប្បាយ ឲ្យមាសប្រាក់ពេញតាយមិនមានខ្វះខាត ក៏នឹងត្រេកអរភ្លើចចិត្តភ្លេចគិតដល់ខុងបេង, គួនអ៊ូ នឹង ទៀវហ៊ុយ សូន្យសោះ ឯ ខុងបេង, គួនអ៊ូ នឹង ទៀវហ៊ុយ នោះក៏នឹងខូចចិត្តលែងគិតស្រណោះឡៅពីជាទីពឹង យើងក៏គង់នឹងបានស្រុកកេងជីវដោយងាយ សុំលោកប្រញាប់រិះគិតធ្វើតាមគំនិតដីវយ៉ើថានោះចុះ ។

ស៊ិនគួនឮដូច្នោះ ក៏មានចិត្តត្រេកអរណាស់ ទើបចាត់មការឲ្យកសាងគ្រឹះស្ថានមានជីកស្រះស្រង់នឹងសួនផ្កាសម្រេចហើយ ក៏ឲ្យអញ្ជើញឡៅភី នាងស៊ិនហ៊ួយ៉េង ទៅនៅសំណាក់ ហើយចាត់ខ្ញុំស្រីប្រុសជាមនុស្សបំរើនឹងមាសប្រាក់ជាច្រើន ហើយឲ្យជ្រើសរើសរកស្រីកញ្ញា ដែលដែលមានរូបឆោមល្អចំនួន ១០ នាក់ ឲ្យច្រៀងរាំបម្រើឡៅភី គ្រប់ទិន

ទិវារាត្រី ៗ នាងដ៏កុកកៃប ឃើញស៊ុនគួនរាប់អានស្រឡាញ់ឡៀតដូច្នោះ ក៏មិនបានដឹងកលឧបាយ មានចិត្តសប្បាយសោមនស្សពេកណាស់ ៗ

សម័យនោះ ឡៀតក៏ទៅជាមនុស្សមានទ្រព្យសម្បត្តិ បរិបូណ៌ដោយបរិវារ ក៏ធ្វេសវង្វេងមិនបានគិតរៀបត្រឡប់ទៅស្រុកកេងជីវសោះឡើយ ម៉ោះហើយ ដូឡុង ក៏គ្មានកិច្ចការអ្វីធ្វើ តែងនាំទាហានទាំង ៥០០ ដើរចេញទៅ ឲ្យទាហានទាំងនោះហាត់ជិះសេះបាញ់ធ្នូរាល់ ១ ថ្ងៃ លុះយូរទៅក៏កន្លងចូលឆ្នាំថ្មី ដូឡុង ក៏ភ្ញាក់ស្មារតីនឹកឃើញដល់ពាក្យខុងបេងផ្ដាំទុកថា បើទៅដល់ស្រុកឡាំស៊ី ឲ្យហែកស្រោមសំបុត្រទី ១ បើកមើល បើដល់ចូលឆ្នាំថ្មី ឲ្យហែកស្រោមសំបុត្រទី ២ បើកមើល ឯសំបុត្រទី ៣ ឲ្យហែកមើល ក្នុងគ្រាដែលមានអាសន្នក្រ គ្រានេះ ហៅហ្វាយយើងមកនៅក៏យូរលង់ដល់ចូលឆ្នាំថ្មី ឃើញធ្វេសស្មារតីវង្វេងទៅដោយសេចក្ដីស្រឡាញ់ករិយាថ្មីពេកណាស់ មិនដែលជួបប្រទះនិយាយការអ្វីនឹងយើងដល់ម្ដងសោះ គួរនឹងហែកស្រោមសំបុត្រទី ២ បើកមើលចុះ ៗ

ដូឡុងគិតដូច្នោះ ក៏ហែកស្រោមសំបុត្រទី ២ មើលឃើញសេចក្ដីថា បើឡៀតធ្វេសស្មារតី ដោយសេចក្ដីប្រតិព័ទ្ធចំពោះករិយាថ្មី ដោយកលឧបាយស៊ុនគួន មិនបានគិតរលឹកនឹកនឹងចង់ត្រឡប់ទៅស្រុកវិញទេ ឲ្យដូឡុងទៅល្បួងបញ្ឆោតឡៀតថា ចូចូលើកទ័ពមកវាយស្រុកកេងជីវ

ហើយ ខុងបេងឲ្យគួនអ៊ូ ទៀវហ៊ុយ ចេញច្បាំងកំងកជាពន្ធ៍កណាស់ កងទ័ពចូច្ចូ ក៏នៅមិនទាន់វិលត្រឡប់ បើនិយាយរៀបរាប់ដូច្នេះហើយ ឡៅពីនៅតែអាឡោះអាល័យភរិយា ក៏ត្រូវឲ្យថា រំលឹកឡៅពីឲ្យនាំរឿងពីរ ដែលជីវយ៉ីនឹងស៊ុនគួនធ្វើកលឧបាយនោះ ឲ្យនាងស៊ុនហ៊ូយិនស្តាប់ ឯនាងស៊ុនហ៊ូយិននោះ ជាមនុស្សប្រកបដោយសត្យភិតត្រង់ គង់នឹងដាច់ចិត្តដិតដោយតាមឡៅពីទៅជាប្រាកដ ជូឡុងលុះដឹងតាមសេចក្តីសំបុត្រដូច្នោះហើយ ក៏ចូលទៅសុំជួបនឹងឡៅពី លុះទៅដល់ទ្វារផ្ទះក៏ឲ្យស្រីម្នាក់ចូលទៅជំរាបឡៅពីថា ជូឡុងចូលមកចង់ជួប ព្រោះមានការអាសន្នប្លែក ឡៅពីឮដូច្នោះ ក៏ចេញទៅជួបនឹងជូឡុង ។ ក៏ធ្វើជាភ័យរលះរលាំងនិយាយនឹងឡៅពីថា លោកមកនៅបានសេចក្តីសុខសម្រាន្តក្នុងដែនស្រុកនេះហើយ ប្រហែលជាភ្លេចស្រុកកេងជីវសោះទេដឹង ឡៅពីក៏សួរថា ហេតុម្តេចបានជាភ័យភិតបែបដូចរត់ចូលមក ជូឡុងឆ្លើយថា តាមសេចក្តីសំបុត្រខុងបេងសរសេរទុកមកនោះគ្រប់ប្រការ ឡៅពីឮដូច្នោះក៏ថា ចាំយើងទៅប្រឹក្សានឹងនាងស៊ុនហ៊ូយិនសិន ជូឡុងថាដែលលោកនឹងប្រឹក្សានោះមុខជានាងស៊ុនហ៊ូយិនមិនឲ្យលោកទៅទេ លោកកុំឲ្យនាងស៊ុនហ៊ូយិនដឹងឡើយ ពេលយប់នេះយើងនឹងនាំគ្នារត់ទៅ ដើម្បីនឹងបានជួយខុងបេងប្រឹងរិះគិតធ្វើការច្បាំងនឹងចូច្ចូ ។

ឡៅពីនិយាយថា អ្នកវិលទៅក្រៅសិនចុះ ចាំយើងត្រិះរិះមើលសិន ដូឡុងក៏គំនាប់លាឡៅពីចេញទៅ ឡៅពីក៏ត្រឡប់ចូលមកក្នុងធ្វើជាយំសោក ប្រាប្តាទឹងឡេករិយាសាកសួរ នាងស៊ុនហ៊ួយមិនឃើញហើយក៏សួរថា អ្នកមានទុក្ខរឿងអ្វីបានជាយំសោកដូច្នេះ ឡៅពីក៏ថ្លែងប្រាប់ថា បងគិតរំពឹកដល់គុណមាតាបិតា កាលលោករស់នៅក៏មិនបានតបគុណអ្វីឡើយ លុះលោកអនិច្ចកម្មទៅហើយក៏មិនបានទៅគោរពបូជាដូចមិនមានសេចក្ដីកតញ្ញូសោះ បងមកនៅនឹងប្អូនគ្រានេះ ក៏យូរណាស់ហើយ គ្រានេះក៏ចូលឆ្នាំថែមទៅទៀត បងគិតនឹកដល់គុណូបការៈបិតាមាតាដូច្នេះ បានជាមិនមានសេចក្ដីសប្បាយ នាងស៊ុនហ៊ួយមិនថា អ្នកកុំនិយាយបញ្ឆោតខ្ញុំថ្មីទៀត សេចក្ដីដែលដូឡុងមកជំរាបអ្នកនោះ ខ្ញុំក៏បានឮជាក់ហើយ អ្នកនឹងចង់ត្រឡប់ទៅស្រុកកេងជីវជាប្រញាប់ ហេតុអ្វីអ្នកមកសារសព្ទប្រាប់ខ្ញុំដូច្នេះវិញ ។

ឡៅពីតបថា សេចក្ដីទាំងអម្បាលនេះ បើប្អូនដឹងអស់ហើយនឹងបង្អង់នៅយូរ មិនវិលទៅស្រុកកេងជីវឯណាបាន បើកើតថ្វស់ការណ៍ឡើងមនុស្សទាំងពួងក៏នឹងនាំគ្នាសើចជំនៀលដៀលត្មះថា បងធ្វេសវង្វេងដោយភរិយា ទាល់តែអន្ដរាយស្រុកដោយចូច តែថាបើនឹងទៅឥឡូវនេះសោត បងក៏ជាប់ចិត្តអាល័យប្អូនដូចរូបខ្លួនបង ហេតុនេះ បានជាបងទប់សំណោកពុំបាន នាងស៊ុនហ៊ួយមិនឆ្លើយថា ខ្លួនខ្ញុំជាបាទបរិច្ចាគជាប់

ស្រេចជារបស់អ្នកហើយ បើអ្នកនឹងរិះគិតដោយប្រការយ៉ាងណា ខ្ញុំត្រូវតែស្តាប់តាមអធ្យាស្រ័យនៃអ្នកទាំងអស់ ។ ទៀតពីឆ្លើយថា ប្អូននិយាយនេះត្រូវណាស់ តែបងនៅបារម្ភចិត្តមាតារបស់ប្អូននឹងស៊ិនគួនជាបងក្រែងមិនព្រមឲ្យទៅ បើប្អូនមានមេត្តា មិនឲ្យទ្រូងបងរងកម្មទ្រាំទុក្ខក្នុងរឿងនេះក៏ចូរត្រិះរិះគិតឲ្យស្រួលទៅផងចុះ បងនឹងគិតស្រូតរូតត្រឡប់ទៅស្រុកកេង-ដីវិញជាប្រញាប់ នឹងបានរិះគិតប្លាំងតស៊ូនឹងចូឆ្ង ហើយទៀតពីក៏ធ្វើថាយំសញ្ជប់ជ្រប់កគ្រា ។

នាងស៊ិនហ៊ួយងក៏ល្ងួងលោមថា កុំឲ្យអ្នកកើតទុក្ខអ្វីឡើយ ខ្ញុំនឹងទៅស្រដីអង្វរករអ្នកម្តាយ ប្រហែលជានឹងព្រមឲ្យយើងទៅស្រុកនាយទាំងពីរនាក់ទេ ទៀតពីថា បើប្រសិនមាតាប្អូនព្រមឲ្យទៅហើយ តែបើស៊ិនគួនមិនព្រមឲ្យទៅវិញ ប្អូននឹងគិតម្តេចទៅទៀត នាងស៊ិន-ហ៊ួយងថា ខ្ញុំនឹងទៅលាមាតាថា ដល់ចូលឆ្នាំថ្មីជាថ្ងៃខែត្រូវធ្វើពិធីសែនរំលឹកគុណបិតាមាតា អ្នកត្រូវការទៅធ្វើតាមទំនៀមនឹងខាននៅស្ងៀមក៏ពុំបាន ខ្ញុំក៏ត្រូវទៅជាមួយបង បើមាតាព្រមអនុញ្ញាតហើយ ហើយនឹងនាំគ្នាលបរត់ទៅកុំឲ្យស៊ិនគួនដឹងខាន ។

ទៀតពីឮដូច្នោះ ក៏មានចិត្តសោមនស្សត្រេកអរពន់ប្រមាណ បាននិយាយនឹងនាងស៊ិនហ៊ួយងថា បងមិនបង់ចិត្តដែលបានប្អូនជាកែវស្រឡាញ់

ប្អូន បើប្អូនរិះគិតបានដូចប្រាជ្ញថាកូនគ្រោះនេះ នោះបងនឹងស្លាប់បងក៏មិនភ្លេចគុណប្អូន ហើយឡៅពិក៏ឲ្យហៅដូង្សឹមកបង្គាប់ថា ដល់ថ្ងៃនក្ខត្តឫក្សចូលឆ្នាំថ្មី ឲ្យលើកទាហានទាំងអស់ចេញទៅព្រមគ្នារង់ចាំយើងនៅផ្លូវហ្វូងខាងក្រៅស្រុក យើងនឹងនាងស៊ុនហ៊ួយអិននឹងធ្វើឧបាយកលនាំគ្នាតែទៅ អ្នកចូរត្រៀមបំរុងការទុកឲ្យព្រម ដូង្សឹមទទួលប្រសាសន៍ហើយ ក៏លាចេញទៅចាត់ការតាមឡៅពិបង្គាប់ ។ ខណៈនោះ ព្រះចៅហៀនតេសោយរាជសម្បត្តិបាន ១៦ ឆ្នាំ ជាថ្ងៃនក្ខត្តឫក្សចូលឆ្នាំថ្មី ។ ស៊ុនគួនក៏ឲ្យរៀបតុតាំងលៀងអាហារដល់នាម៉ឺនតូចធំទាំងពួង ។

ឡៅពិនឹងនាងស៊ុនហ៊ួយអិន ក៏នាំគ្នាចូលទៅគំនាប់លានាងង៉ុកថៃ ហើយនាងស៊ុនហ៊ួយអិនដំរាបមាតាថា ឡៅពិរលឹកនឹកដល់គុណបិតាមាតាគណាញាតិទាំងពួងដែលចាកឋានទៅហើយនោះ បានបញ្ចុះសពទុកនៅស្រុកទុនគួន មកសូមប្រណិប័តន៍លាអ្នកម្ដាយទៅសែនសពបិតា-មាតា តែល្មមជាហេតុតាមទំនៀមទំលាប់ដូនតា ខ្ញុំក៏សុំលាអ្នកម្ដាយទៅជាមួយផង ។

នាងង៉ុកថៃឆ្លើយថា ការនេះជាទំនៀមប្រវេណី កូនចៅត្រូវដឹងគុណបិតាមាតា មួយទៀតនាងឯងក៏នៅមិនទាន់បានទៅគំនាប់សពបិតាមាតាខាងប្ដីសោះ បើចង់ទៅក៏ទៅចុះ នាងស៊ុនហ៊ួយអិនក៏មានអំណរ

ណាស់  ទាំងពីរនាក់ក៏គំនាប់លាមាតាមកទីលំនៅវិញ  ហើយរៀបចាត់ចែងគ្រឿងមាសប្រាក់ និងរបស់ទ្រព្យសត្វគេទាំងពួង  រើសយកតែរបស់ណាដែលល្អមានតម្លៃដាក់ផ្ទុកលើរថ  ឡៅពីក៏ឡើងជិះសេះ  ឲ្យនាងស៊ុនហ៊ូយមិនឡើងជិះរថជាមួយនឹងបាវស្រី ១ ដែលស្និទ្ធ  ចេញចាកស្រុកឡាំស៊ុ ទៅតាមផ្លូវដែលសញ្ញាឲ្យជូឡុងនៅរង់ចាំនោះ  លុះជូឡុងក្រឡេកឃើញឡៅពីនឹងនាងស៊ុនហ៊ូយមិនបររថមកដល់  មានអំណរណាស់  ក៏លើកទាហានទាំងពួងការពារពីក្រោយទៅ ។

ឯស៊ុនគួននឹងនាម៉ឺនទាំងពួងសេពសុរាបរិភោគអាហារ  នៅទាល់តែរសៀលល្ងាច  ទាហានទាំងពួងឃើញស៊ុនគួនស្រវឹងស្រាខ្លាំងណាស់ មិនដឹងស្មារតី  ក៏បបួលគ្នាគ្រាហ៍ស៊ុនគួនចូលទៅក្នុងផ្ទះ  អស់បណ្ដានាម៉ឺនមុខមន្ត្រីទាំងពួងក៏នាំគ្នាវិលទៅទីលំនៅរៀងខ្លួន  ខណៈនោះមានទាហានម្នាក់ដឹងសេចក្ដីថា  ឡៅពីនឹងនាងស៊ុនហ៊ូយមិន  នាំគ្នារត់ទៅហើយ  ក៏ស្រូតរូតចូលទៅទីដំណេកស៊ុនគួន  ឃើញស៊ុនគួនស្រវឹងស្រា  មិនដឹងខ្លួនទាល់តែក្វីឡើង  ស៊ុនគួនក៏ស្វាងស្រាភ្ញាក់ភ្លែក  ទាហានក៏ជំរាបថា  ឡៅពី នឹងនាងស៊ុនហ៊ូយមិនរត់ទៅបាត់ពីម្សិលមិញទៅហើយ  ស៊ុនគួនឮដូច្នោះ  ក៏ភ័យស្លុតស្មារតី  ឲ្យហៅនាម៉ឺនមុខមន្ត្រីមកប្រជុំប្រឹក្សា ។

ទៀវដៀវឆ្លើយថា ឡៅពីមានតម្រេះប្រាជ្ញាជ្រៅណាស់ បើវិលទៅដល់ស្រុកហើយ យូរទៅនឹងជាសត្រូវដល់លោកវិញ សុំលោកស្រូតប្រញាប់ចាត់ទាហាន ឲ្យលើកទៅតាមចាប់យកខ្លួនឡៅពីមកវិញ ស៊ុនគួនយល់ឃើញត្រូវផង ទើបឲ្យហៅគ័នប៊ូនឹងកូដៀង មកបង្គាប់ថា អ្នកឯងទាំងពីរនាក់ត្រូវលើកទាហាន ៥០០ តាមទៅចាប់ខ្លួនឡៅពី មកឲ្យបាន គ័នប៊ូ, កូដៀង ក៏លើកទាហានតាមទៅ ស៊ុនគួនមានសេចក្តីខឹងក្តៅខ្លាំងណាស់ យកដបទឹកខ្មៅបោលសំដៅទៅត្រូវជញ្ជាំងផ្ទះ ធាល់តែដបនោះបែកល្អិតខ្ទេច ទៀវតៅថា លោកមកក្រោធខឹងយ៉ាងណាក៏មិនជាការមានប្រយោជន៍សោះ ខ្ញុំបាទយល់ឃើញថា គ័នប៊ូ, កូដៀងដែលលោកប្រើឲ្យលើកទាហានតាមទៅនោះ មុខជាមិនបានខ្លួនឡៅពីមកទេ ព្រោះនាងស៊ុនហ៊ូយិនជាស្រីមានតម្រេះប្រាជ្ញា ហើយមាតាលោកក៏ពបអានស្រឡាញ់ស្មើជីវិត នាងក៏ព្រមចិត្តទៅជាមួយនឹងឡៅពី មុខជាទាហានទាំងអស់នឹងក្រែងខ្លាចពុំអាចចូលទៅចាប់បាន ។

ស៊ុនគួនឮដូច្នោះក៏យល់ត្រូវ ទើបយកក្រប៊ីអាជ្ញាសិទ្ធិប្រគល់ឲ្យជីវយ៉ឹម នឹង ជីវថាយ ហើយបង្គាប់ថា អ្នកឯងខំស្រូតលើកទាហានទៅតាមគ័នប៊ូ, កូងដៀង ទៅទៀត បើទាន់ហើយឲ្យយកក្រប៊ីនេះកាត់ក្បាលឡៅពី នឹងនាងស៊ុនហ៊ូយិនមកឲ្យយើងឲ្យខាងតែបាន : បើមិនបានទេ

យើងនឹងកាត់ក្បាលអ្នកឯងជំនួស ។ ជីវយឹម, ជីវថាយ ក៏ទទួលប្រសាសន៍ ស៊ុនគួន លើកទាហាន ១ ពាន់ តាមទៅ ។

ឯឡៅពី រត់ទៅក្នុងថ្ងៃនោះ លុះពេលយាម ២ ក៏ឈប់សម្រាក ទាហានមួយស្របក់ ហើយក៏ស្រូតលើកទៅដល់ដែនស្រុកឆសង់គុណ បានឮសំឡេងទាហានស្រែកហៅ ហើយលើកដិតដោយតាមពីក្រោយ ហុយធូលី ងងឹតពេញផ្លូវ ឡៅពីក៏ប្រឹក្សានឹងជូឡុងថា ឥឡូវទាហាន លើកដិតតាមមកច្រើនណាស់ យើងនឹងរិះគិតប្រការម្តេច? ។ ជូឡុងឆ្លើយ ថា លោកខំស្រូតរូតឲ្យលឿនទៅមុខចុះ ខ្ញុំបាទនឹងទាហានទាំងពួងនឹង ពាំងការពារពីក្រោយ ឡៅពីក៏នាំនាងស៊ុនហ៊ូយិន រត់រកផ្លូវទៅតាម ជើងភ្នំក្រោយស្រុកឆសង់គុណ ។

ខណៈនោះ ជីវយីដឹងថា ឡៅពីនឹងនាងស៊ុនហ៊ូយិន នាំគ្នារត់មក ពីស្រុកឡាំស៊ី ក៏គិតរំពឹងថា ឡៅពីរត់មកគ្រានេះ បើមកផ្លូវគោកមុខ ជាក់ស្រុកយើងមកតាមជើងភ្នំជាប្រាកដ ទើបប្រើឈីសេង, តេងហង. ឲ្យលើកទាហាន ៣ ពាន់ ទៅចាំស្កាត់ផ្លូវ ។ ឈីសេង, តេងហេង ក៏ ឡើងមើលលើភ្នំ ក្រឡេកទៅឃើញឡៅពីមកពីចម្ងាយក៏ចេញស្កាត់ផ្លូវ នៅពីមុខហើយស្រែកថា ជីវយី ប្រើយើងឲ្យមកចាំនៅទីនេះយូរហើយ

ចូរអ្នកចុះពីលើសេះ យើងនឹងចាប់ខ្លួនទៅឲ្យដីវយើ ។

ទៀតពី បានឮដូច្នោះ ក៏ភ័យស្លុតស្មារតី មើលទៅឃើញទាហាន ស្ទាក់ផ្លូវជាច្រើន ទើបបំផាយសេះរត់ត្រឡប់មករកដូឡុង ហើយប្រាប់ថា ទាហានចាំស្ទាក់ផ្លូវពីមុខច្រើនណាស់ យើងនឹងរិះគិតប្រការម្ដេច ។ ដូឡុងឆ្លើយថា លោកកុំវិតក្កឡើយ កាលយើងនឹងមកនោះ ខុងបេងក៏បាន ឲ្យសំបុត្រមក ៣ ច្បាប់ បានមើល ២ ច្បាប់ហើយ ក៏បានធ្វើការរួចខ្លួន ហូតមកដល់ពេលនេះ នៅសំបុត្រច្បាប់ទី ៣ ខុងបេងផ្ដាំថា បើមានភ័យ អាសន្នមកដល់ខ្លួនវេលាណា ត្រូវឲ្យហែកស្រោមមើល ឥឡូវដល់ភ័យ អាសន្នមកហើយ ត្រូវតែហែកមើលសំបុត្រនោះឲ្យដឹង ទុំងបានរិះគិតទៅ ទៀត ហើយដូឡុងក៏ហែកស្រោមសំបុត្រច្បាប់ទី ៣ ហុចឲ្យទៅទៀតពី មើល ។

(នៅមានត)

# រឿងព្រេងចិន

លោក ភិយ-ប៊ុគា ប្រែរៀបរៀង

(តពីលេខ ១១ ឆ្នាំ ១៩៦១)

---

ឆ្នាំនោះ ក៏មានដំណើរដោយឆាប់រហ័ស, រហូតដល់ពេលប្រណាំងសេះម្ដងទៀត ។ មាតាបិតានឹងកូនប្រសាស្រី ក៏ត្រូវទៅកាន់ពិធីបុណ្យនោះ ។ ជនទាំង ៣ នាក់នេះ ក៏ច្រៀងរាំជាមួយនឹងអ្នកដែលទៅទស្សនាប្រណាំងសេះទាំងអស់ ហើយផឹកស្រាដែលធ្វើពីដើមសែក្លិ (Seigle) ។ តែដល់ពេលអវសាន នាងជាកូនប្រសាស្រី ក៏ពោលទៅកាន់មាតាក្មេកថា :

"ម៉ែ! ខ្ញុំមិនស្រួលខ្លួន, ឈឺក្បាល, ចង់ត្រឡប់ទៅផ្ទះវិញ សូមម៉ែអនុញ្ញាតឲ្យខ្ញុំទៅផ្ទះវិញ ជិះសេះទេសញីនេះណា៎ម៉ែ!" ។

ដោយតាចាស់យាយចាស់ស្រឡាញ់កូនប្រសាស្រីពន់ពេក, លោកក៏បើកឲ្យនាងត្រឡប់ទៅផ្ទះវិញ, ជិះសេះទេសញីនោះ ។ កាលណានាងចុះពីលើភ្នំទៅខាងម្ខាង, ដោយនាងយល់ថា បិតាមាតាក្មេកមិនឃើញនាង ក៏បំផាយសេះយ៉ាងលឿនទៅកាន់ផ្ទះវិញ ដល់ផ្ទះនាងបានរកមើលកញ្ចាញ់ចេកនោះ មិនឃើញសោះឡើយ, នាងដើររកចុះឡើង សព្វច្រកល្ហក, ស្រាប់តែឃើញស្បែកកញ្ចាញ់ចេកស្ថិតនៅ

ជិតមាត់ត្រពាំង ៗ ស្បែកនេះ មានទ្រង់ទ្រាយដូចកញ្ចាញ់ចេកជាស្វាមី នាង ៗ នាងកាន់សំណកនោះ ដោយចិត្តសោមនស្សពន់ពេក ហើយនាងនឹកក្នុងចិត្តថា "នេះជាស្វាមីអញ ! គួរឲ្យសប្បាយចិត្តពន់ពេក ! ដ៏យបុរសនោះ ប្រាកដជាស្វាមីអញៗ បានស្វាមីមានរូបឆោមលោមពណ៌ ស្រស់ប្រិមប្រិយណាស់ ៗ

នាងក៏ជូតទឹកភ្នែក, តែទឹកភ្នែកនោះចេះតែហូរស្រោកចេញមក ៗ នាងក៏ប្រែប្រួលមើលស្បែកកញ្ចាញ់ចេកនោះ ជាច្រើនលើកច្រើនសា ហើយនាងមានសេចក្តីតូចចិត្តក៏ពោលថា: "ឱស្វាមី! ម្តេចបងចូលចិត្តពួនលាក់ខ្លួនបងនៅក្នុងស្បែកកញ្ចាញ់ចេកដ៏អាក្រក់ដូច្នេះ ? ម្តេចក៏បងចូលចិត្តធ្វើខ្លួនបងឲ្យតូច ឲ្យអាក្រក់ដូច្នេះ ? ប្រហែលជាបងយល់ថា ខ្ញុំជាស្ត្រីមិនសមជាគូស្រករនឹងបងឬ ?" ៗ

ដល់នាងពិចារណានូវស្បែកកញ្ចាញ់ចេកនោះ នាងកាន់តែមានចិត្តទោមនស្សឡើង ហើយនាងពោលថា: "អញយកស្បែកនេះ ទៅដុត ដើម្បីកុំឲ្យស្វាមីអញ ចូលនៅក្នុងស្បែកនេះបានទៀត", នាងពោលដូច្នេះ, ក៏យកស្បែកនោះទៅដុតឆេះអស់គ្មានសល់ ៗ

ក្នុងពេលនោះ, ព្រះសុរិយាទៀបនឹងអស្តង្គត . ស្វាមីនាងក៏ជិះសេះមកដល់គេហដ្ឋាន, បានឃើញស្បែកកញ្ចាញ់ចេកឆេះក្នុងភ្លើង, បុរសក៏មុខស្វាយភ័យតក់ស្លុតរន្ធត់ឥតអប្បមា, លោតពីលើខ្នងសេះ ស្ទុះមក

កន្ត្រាក់ដណ្ដើមយកស្បែកកញ្ចាញ់ចេកពីដៃនាង តែជាការឥតអំពើ. . . ស្បែកនោះឆេះអស់ទៅហើយ ។ បុរសក៏ថយរ៉ន់ ដួលនៅជិតថ្មមួយធំ ចំមុខផ្ទះ ។

នាងជាភរិយា ក៏ស្ទុះទៅគ្រាហ៍ស្វាមី នាំចូលទៅក្នុងផ្ទះ ពោលដោយសេចក្ដីទុក្ខក្រៀមក្រំថា: " ឱស្វាមី ! សំឡាញ់ប្អូនអើយ ! បងជាអស្សុរកោវិទដ៏វិសេសវិសាល, ម្ដេចក៏បងចូលចិត្តប្ដូរខ្លួនជាកញ្ចាញ់ចេក ស្ត្រីទាំងឡាយ មានស្វាមីសុទ្ធតែមនុស្សជាតិ, ហេតុម្ដេចក៏ខ្ញុំមានស្វាមីកញ្ចាញ់ចេកដូច្នេះ, ខ្ញុំកើតទុក្ខលំបាកឥតឧបមា " ។

បុរសក៏តបទៅវិញថា : " អូនសំឡាញ់អើយ ! អូនគ្មានចិត្តខន្តីសោះ, អូនធ្វើកិច្ចការនេះដោយឆាប់រហ័សពេក បើអូនរង់ចាំឱកាសបន្តិចទៀត, ពេលដែលកំឡាំងបង មានអានុភាពឡើងវិញ អូននឹងបានរស់ជាមួយនឹងបង បានសេចក្ដីសុខសប្បាយមិនខាន ។ តែឥឡូវនេះ, បងមានតែសេចក្ដីស្លាប់ម្យ៉ាង, ហើយប្រជារាស្ត្រនឹងមិនបានទទួលនូវសុភមង្គលដែលបងប្រាថ្នាបំពេញយ៉ាងម៉ឺងម៉ាត់" ។

នាងជាភរិយាក៏តបថា: " នេះជាកំហុសរបស់ខ្ញុំ ! តើមានមធ្យោបាយអ្វីមួយល្មមកែកំហុសនោះបានដែរឬ ? " ។

ស្វាមីក៏តបទៅភរិយាវិញថា: " មិនមែននាងធ្វើកំហុសទេ ចំពោះរឿងនេះ, កំហុសមកពីបងប្រមាទទៅវិញ, បងចង់ពិសោធមើល

ពលកាភរបស់បង, បានជាបងបានទៅជិះសេះប្រណាំងនឹងគេ, ដូច្នេះយើងតាំងពីនោះ មិនបានទទួលនូវសុភមង្គល ដូចសេចក្ដីប្រាថ្នាទេ ហើយប្រជារាស្ត្រ ក៏មិនបានទទួលនូវសេចក្ដីសុខកាយសប្បាយចិត្តដែរ ។ បងមិនមែនមនុស្សសាមញ្ញទេ បងជាឱរសនៃនាងគង្ហីងព្រះធរណី ។ បងរេដំតាំខ្លួនមានកំឡាំងកំហែងសមគួរ នឹងបំពេញករណីយកិច្ចគ្រប់យ៉ាង ដើម្បីសុភមង្គលប្រជារាស្ត្រ ។ បើបងបានសម្រេចដូចបំណង អូននឹងបានឃើញផ្កាថ្កុលយ៉ាងស្អាតមួយ កាត់តម្រង់ចំទៅរាជធានីបើកាំងតែម្ដង អូននឹងបានឃើញមហារាជហង្ស (១) ធ្វើព្រះអំណោយនូវពូជគ្រាប់ស្រូវដល់យើង ។ នឹងថ្វាយទៅវិញនូវគោនឹងចៀម, តែសព្វថ្ងៃ បងមិនទាន់មានពលកាពល្មមគួរដល់ការនោះឡើយ, បងមិនអាចនឹងដេកគង់ពេលយប់ ក្រៅពីស្បែកកញ្ចាញ់ចេករបស់បងបានទេ បើបងគ្មានស្បែកនេះខ្លួនបងមុខជានឹងស្លាប់មុនពេលព្រះអាទិត្យរះឡើងពុំខានឡើយ ក្រោយដែលបងមានកំឡាំងល្មមហើយ, បងអាចគស៊ូនឹងសេចក្ដីនោះបាន បងនឹងបានបំពេញបេសកកម្មជាប្រយោជន៍ដល់ប្រជារាស្ត្រ, សភាពអាកាសក៏ត្រជាក់ត្រជុំ ហើយបងនឹងបានទំលាក់ចោលស្បែកកញ្ចាញ់ចេកនេះបាន

---

១- ហង្សជា ព្រះរាជសន្តតិវង្សបិនទី ៤ ដែលសោយរាជ្យ២សតវត្ស មុនគ្រិស្តសករាជ ។

តែឥឡូវនេះ ពេលវេលាបងផុតហើយ បងនឹងត្រូវស្លាប់ជាពិតប្រាកដ, យប់នេះ បងនឹងត្រឡប់ទៅកាន់ព្រះនាងគង្គាព្រះធរណី ដែលជាមាតាបងវិញហើយ ។

បុត្រីទីបីនៃស្តេចត្រាញ់ ទ្រង់បានសវនាទូវវាចាស្វាមីហើយ ទ្រង់ព្រះកន្សែងអាណិតអាសូរស្វាមីពន់ពេកណាស់ ។ ព្រះនាងទ្រង់មានព្រះបន្ទូលតាំងទុក្ខក្រៀមក្រំក្នុងឧរាថា : "ឱព្រះស្វាមីម្ចាស់ថ្លៃប្អូនអើយ! សូមព្រះអង្គកុំទ្រង់ទិវង្គតអី! សូមព្រះអង្គទ្រង់គង់នៅជាមួយនឹងខ្ញុំម្ចាស់! ខ្ញុំម្ចាស់យល់ថា ព្រះអង្គនឹងរស់រានមានជីវិតតទៅទៀតពុំខានឡើយ" ។

អស្សកោរិទបានឮព្រះវាចាព្រះនាងទេពីហើយ នឹកខ្លោចផ្សាក្នុងឧរាអាណិតអាសូរទេពីពន់ពេកក៏មានបន្ទូលថា :

"ឱព្រះនាង! កុំព្រួយបារម្ភអ្វី! បើព្រះនាងចង់ឲ្យបងរស់រានមានជីវិតតទៅ, ត្រូវមានសេចក្ដីសង្ឃឹមចុះ ប៉ុន្តែ លុះត្រាតែព្រះនាងបានបំពេញករណីយកិច្ចគ្រប់គ្រាន់បរិបូណ៌ទៅតាមលំនាំ ដែលបងប្រាប់ព្រះនាងឲ្យបានពេញលក្ខណៈ" ។

ទ្រង់មានបន្ទូលដូច្នេះ ទ្រង់យកព្រះហស្ត ចង្អុលទៅទិសបស្ចិម

---

:ហើយមានបន្ទូលថា :

-« ត្រៅយើងសូមឲ្យព្រះអាទិទេពលោកជួយយើង ហើយឲ្យលោកមានធនូៈជួយយើងផង ទើបបងរស់នៅបាន, សូមព្រះនាងគង់លើពាជីបង, ពាជីនេះ មានល្បឿនយ៉ាងអស្ចារ្យ អាចនាំទៅដល់វិសបស៊ិមបាន ព្រះនាងនឹងបានទៅដល់ទាន់ពេលវេលា នៅទីនោះ មានប្រាសាទព្រះអាទិទេពមួយ, ព្រះនាងចូលទៅក្នុងប្រាសាទនោះ ហើយអង្វរគេព្រះអាទិទេពក្នុងនាមនៃសុគមង្គលប្រជាកស្រ្ត, ហើយព្រះនាងធ្វើសំណូមពរយ៉ាងចំពោះព្រះអាទិទេព , ហើយសូមព្រះអង្គប្រទានសំណូមពរមុនថ្ងៃរះគឺ ៖

- សំណូមពរទីមួយ, សូមព្រះអង្គទ្រង់ព្រះកជានុញាតរបនាប្រជាកស្រ្តកុំឲ្យមាន អ្នកមាន ឬ អ្នកក្រ ។

- សំណូមពរទីពីរ, សូមព្រះអង្គសម្រេចថា ពួកអភិជននៃប្រទេសយើង កុំឲ្យធ្វើបាប កំហែងតម្រាមប្រជាកស្រ្ត ។

- សំណូមពរទីបី, សូមព្រះអង្គទ្រង់សម្រេចឲ្យមានថ្នល់មួយទៅពីទីនេះ ទៅដល់កជធានី " ប៉េកាំង " ដើម្បីនឹងបានទទួលផលិតផលពីមហាកជហង្ស ព្រមទាំងថ្វាយទៅវិញនូវគោនឹងចៀម ។ បើព្រះអាទិ-ទេពទ្រង់នឹងព្រះកជានុញាតនូវសំណូមពរទាំងបីនេះហើយ ប្រទេសនឹងទៅជាត្រជាក់ត្រជុំ , បងនឹងបានចេញពីស្បែកកញ្ជ្រោញចេក ដោយរស់កនមានជីវិតមិនស្លាប់ឡើយ " ។

ព្រះនាងជាភរិយាក៏ឡើងគង់លើអាជានេយ្យ បំផាយយ៉ាងលឿន ដូចជាគេហោះកណ្តាលពពក អណ្តែតត្រសែត លឿនលើនកាល័យ ក់តបន្ទន់ ។ ព្រះនាងទ្រង់ស្តេចទៅដល់ព្រះមហាប្រាសាទក្តីសន្តោសន្តៅ ត្រចះត្រចង់ប្រកបដោយសោភណភាពនឹងអច្ឆរិយវត្ថុយ៉ាងអស្ចារ្យ, ព្រះនាងទ្រង់យាងចូលទៅក្នុងព្រះមហាប្រាសាទនោះហើយ ទ្រង់អង្វរសូមព្រះអាទិទេពដោយព្រះមធុរសវាចាផ្អែមល្ហែម ទាល់តែព្រះអង្គទ្រង់មានព្រះឱហទ័យទោរទន់អាណិតអាសូរព្រះនាងពន់ពេកណាស់ ។

ព្រះអាទិទេពទ្រង់មានព្រះឱង្ការនូវព្រះបន្ទូលសួរសីហនាទ ទៅកាន់ព្រះនាងថា: "ឱព្រះនាង! ដោយព្រះនាងមានព្រះទ័យស្មោះត្រង់ចំពោះស្វាមី, យើងនឹងអនុញ្ញាតឲ្យព្រះនាងនូវសំណូមពរតាំងបី សូមព្រះនាងទទួលដោយចិត្តរីករាយចុះ តែដើម្បីឲ្យសំណូមពរបានសម្រេចទៅតាមលទ្ធផលដ៏ប្រសើរនោះ, ត្រូវព្រះនាងយកដំណឹងនេះ ទៅប្រាប់ប្រជារាស្ត្រនៅក្នុងភូមិឲ្យបានមុនថ្ងៃរះ ។ បើព្រះនាងធ្វើបានមុនព្រះសុរិយារះ, នៅទីនោះ លែងរងាហើយ ។ ស្វាមីនាងនឹងបានចេញពីស្បែកកញ្ចាញ់ចេកពុំខាន" ។

ព្រះនាងទ្រង់ថ្លែងនូវព្រះគុណចំពោះព្រះអាទិទេពហើយ ទ្រង់បំផាយពាជីវិលត្រឡប់ទៅកាន់គេហដ្ឋានវិញ, ព្រះនាងទ្រង់ប្រញាប់

ប្រញាល់នឹងយកដំណឹងនេះ ទៅប្រាប់ក្រុមគ្រួសារក្នុងភូមិឲ្យបានជ្រាបទាំងអស់គ្នា ។ តែក្នុងពេលដែលព្រះនាងទ្រង់ស្ដេចទៅដល់ជ្រោះភ្នំខាងចុងទ្រង់បានជួបនឹងព្រះបិតាព្រះនាង ទ្រង់កំពុងប្រថាប់នៅមុខប្រាសាទ ។

បិតាព្រះនាង, លុះបានឃើញព្រះរាជបុត្រីគង់លើពាជី បំផាយយ៉ាងលឿន, ទ្រង់មានព្រះបន្ទូលសួរព្រះនាងថា:

"ឱកូនស្រី ! តើនាងមានការអ្វី ? ម្ដេចក៏នាងបំផាយអាជានេះយ៉ាងពេលយប់ងងឹតដូច្នេះ ? " ។

ព្រះនាងទ្រង់ឆ្លើយតបទៅព្រះបិតាវិញថា: ខ្ញុំម្ចាស់មានកិច្ចសំខាន់ណាស់, បិតា! ព្រះអាទិទេពបានសន្យានឹងកូនថា ព្រះអង្គនឹងឲ្យមកកូននូវវត្ថុមួយដ៏វិសេសវិសាល កូននឹងយកដំណឹងនេះ ទៅប្រាប់ក្រុមគ្រួសារទាំងឡាយក្នុងភូមិនេះ" ។

បិតាសួរបញ្ជាក់ព្រះនាងថា: "កូនឯង ម្ដេចក៏ប្រញាប់ប្រញាល់ដូច្នេះ, ចូរកូនប្រាប់បិតាផង ព្រះអាទិទេពទ្រង់បានសន្យានឹងកូនដូចម្ដេចខ្លះ? " ។

ព្រះនាងទ្រង់តបទៅបិតាថា: "កូនគ្មានពេលវេលានឹងជំពបបិតាទេ, កូននឹងជំពបបិតាក្នុងពេលបន្តិចទៀត " ។

បិតាព្រះនាងទ្រង់យាងចុះមកក្រោម ហើយចាប់បង្ហៀរពាជីមានព្រះបន្ទូលថា:

«បិតាជាស្តេចគ្រាញ់កាន់កាប់ការនៅទីនេះ, នាងត្រូវប្រាប់បិតាជាមុនសិន » ។

ដើម្បីទឹងទ្រង់បេញឲ្យបានរហ័សឆាប់. ព្រះនាងទ្រង់បានក្រាបបង្គំទូលព្រះបិតា នូវកិច្ចសន្យាសព្វគ្រប់នៃព្រះអាទិទេពថា: ព្រះអាទិទេពទ្រង់បានឲ្យពរកូនបីយ៉ាងគឺ :

- ទីមួយ ទ្រង់មិនឲ្យមាន អ្នកមាន ឬអ្នកក្រ នៅទីនេះ ។

ស្តេចគ្រាញ់ បានបញ្ឈប់ព្រះកេតព្រះនាង ហើយមានព្រះបន្ទូលដោយញាក់ព្រះភ្ជុមោថា:

«បើគ្មានអ្នកមាន ឬអ្នកក្រ តើគេអាចសំគាល់បានពួកអភិជន នឹងពួកហិនជនដូចម្តេចកើត ? » ។

ព្រះបិតាព្រះនាងក៏នៅតែចាប់បង្ហៀរពារជាប់យ៉ាងមាំ ។ ឯព្រះ. នាងក៏ទូលព្រះបិតាតទៅទៀតថា :

" សំណូមពរទីពីរគឺ កុំឲ្យអ្នកធំធ្វើទុក្ខបុកម្នេញក៏ហែងគំកមប្រជា. រាស្ត្រនៅទីនេះ " ។

ព្រះបិតាព្រះនាងបានគ្រវីព្រះសិរហើយមានព្រះបន្ទូលយ៉ាងខ្លាំងថា:

" បើដូច្នេះ តើអ្នកណាធ្វើការជាប្រយោជន៍យើង ? អ្នកណាឃ្វាលសត្វពាហនៈរបស់យើង អ្នកណាធ្វើស្រែកាប់ចម្ការរបស់យើង" ។

ស្ដេចត្រាញ់ ទ្រង់មិនបានលែងបង្ហៀរពាជីសោះឡើយ ។

ឯព្រះនាងទ្រង់មានបន្ទូលតទៅទៀតថា:

" សំណូមពរទីបី គឺយើងត្រូវធ្វើថ្នល់មួយពីទីនេះ ទៅកាន់កជ-ធានីប៉ាំង ទើបមហាកជហង្សប្រទានផលានុផលដល់យើង ។ ត្រូវថ្វាយទៅវិញនូវគោនឹងចៀម បើសំណូមពរទាំងបីនេះបានសម្រេចទៅតាមប្រាថ្នាហើយ យើងលែងមានរឿង ។

ស្ដេចត្រាញ់កាត់ព្រះបន្ទូលព្រះនាងហើយមានព្រះបន្ទូលថា: « ខុចជាលង់មែន ! គោ, ចៀមយើងមានគ្រប់គ្រាន់ហើយ តើយើងត្រូវការយកផលានុផលនៃមហាកជហង្ស មកធ្វើអ្វីទៀត ! នេះចង់ជាគំនិតខ្ញុំ ! ព្រះអាទិ-ទេពមិនមែនមានព្រះកជឧត្ដមដូចនាងថាទេ, បិតាមិនជឿកូនទេ បិតាមិនឲ្យកូនទៅនិយាយប្រាប់កស្ដ្រទេ រឿងនេះ ! » ។

ព្រះនាងក៏អង្វរព្រះបិតា សូមលែងបង្ហៀរសេះឲ្យព្រះនាងទៅ ហើយទ្រង់មានបន្ទូលថា: « បិតា! សូមបិតាមេត្តាឲ្យកូនទៅប្រាប់ប្រជាកស្ដ្រ, បិតា! កូនមិនអាចនៅទីនេះបានទេ, កូនប្រញាប់ប្រញាល់ណាស់ . . . ហើយព្រះនាងទ្រង់យកខ្សែក៏យពាជី ស្រែកបំផាយឲ្យបោលទៅ តែបិតានោះកាន់បង្ហៀរពាជីជាប់មាំ ។ ព្រះនាងក៏ទ្រង់មានព្រះទ័យតោ-មនស្សនឹងបិតា . . ។ ក្នុងពេលនោះមាន់ស្រាប់តែរងាវ ។ ព្រះនាងទ្រង់

ភ័យណាស់ ទ្រង់ខំរើពីកណ្ដាប់ព្រះហស្ដព្រះបិតា តែមិនអាចរើរួចបាន ដោយព្រះបិតាកាន់បង្ហៀរពាដីនោះមាំណាស់ ។ កូនពាញទៅខាងនេះ បិតាពាញទៅខាងនោះ, ពាញចុះពាញឡើង ។ បិតាព្រះនាងទ្រង់ព្រះពិរោធ មានព្រះបន្ទូលទៅកាន់ព្រះនាងថា :

តើនាងគ្មានព្រួយបារម្ភអ្វីទេឬ ? បើបិតាគ្មានអ្នកបម្រើ ? តើនាងចង់កុំឲ្យមានបុគ្គលម្នាក់ ដើម្បីនឹងមើលថែរក្សាសត្វពាហនៈ នឹងគួររបស់កាប់គាស់ស្រែចម្ការឬ? នេះហៅពេញជាឆ្កួត . . . ។

ក្នុងពេលដែលព្រះនាងទ្រង់ខំរើបម្រាស ពីកណ្ដាប់ដៃបិតា . . ., មាន់ស្រាប់តែរងាវតែរងង ។ ព្រះនាងទ្រង់មានសេចក្ដីព្រួយជាខ្លាំង . . . ទ្រង់យកខ្សែតីពយពាដីយ៉ាងខ្លាំង ស្រែកចំជាយពាដីទៅមុខ ។ ពាដីហោតឡើង លើស្ដេចត្រាញ់ៗ ក៏ទ្រង់ដួលទៅលើផែនដី ។ ដល់ព្រះនាងទ្រង់យាងទៅដល់គេហដ្ឋានអ្នកស្រុកខាងដើមកូម , មាន់រងាវជាលើកទីបី ។ កាលបើព្រះសុរិយារះឡើង, ព្រះនាងទ្រង់មានបន្ទូលចំពោះអ្នកស្រុកដោយភាគតិចណាស់អំពីរឿងនេះ ។ ក្រោយបន្តិចមក ព្រះនាងទ្រង់ទតឃើញព្រះអរុណរះ, ទ្រង់ក៏ជ្រាបថា ជាការហួសពេលវេលា ទឹងបំពេញកិច្ចនោះហើយៗ ទ្រង់ញាក់ពាដីវិលត្រឡប់មកកាន់ព្រះដំណាក់វិញ ។

លុះយានមកដល់ ព្រះនាងទ្រង់បានទតទៅយល់បិតាមាតាក្មេក កំពុងសោកសង្រេង ចំពោះមុខសាកសពកូនដែលទើបនឹងទទួលមរណភាព ។ មាតាលើកអញ្ជលីថ្វាយបង្គំព្រះអាទិទេព សូមជួយកូនឲ្យរស់រានមានជីវិតឡើងវិញ ។ តែបើទុកជាធ្វើយ៉ាងណា ក៏ជាការអស់សង្ឃឹម ជាការឥតប្រយោជន៍ ។ ព្រះនាងទ្រង់ស្ទុះទៅក្រាលលើសាកសពព្រះស្វាមី ដែលជាទីស្នេហាស្មើជីវិតរបស់ព្រះនាង ហើយទ្រង់ព្រះកន្សែងរៀបរាប់ថា "បុព្វហេតុនៃការទុក្ខសោកនេះ មកពីបិតារបស់អញ, ឱបិតា! មិនគួរឡើយមកធ្វើបាបកូនសោះ . . . " ។

បិតាមាតាក្មេកព្រះនាង ក៏សែងសាកសពកូនទៅដល់ពាក់កណ្ដាលចង្កេះភ្នំ កប់នៅជិតជ្រោះមួយ ។ រាល់ពេលល្ងាច ព្រះនាងតែងយាងទៅកាន់ទីនោះ ហើយទ្រង់សម្រក់ទឹកព្រះនេត្រានៅលើផ្នូរព្រះស្វាមី ដោយសេចក្ដីសោកស្ដាយអាឡោះអាល័យឥតឧបមា ។ ថ្ងៃមួយ ព្រះនាងកំពុងទ្រង់ព្រះកន្សែង ក៏ស្រាប់តែក្លាយខ្លួនទៅជាថ្ម ។

ថ្មនោះ ស្ថិតនៅរហូតសព្វថ្ងៃ ហើយស្ថិតនៅមាំមួនឥតកម្រើក នៅមាត់ជ្រោះភ្នំនោះ ។ ពីចម្ងាយ, គេមើលថ្ម ទ្រង់ទ្រាយជុំវិញ ដូចជាស្រីក្រមុំមានសក់វែងរំសាយចុះ, មានទ្រង់ទ្រាយហាក់ដូចជាធ្វើសំណូមពរ សូមឲ្យស្វាមីព្រះនាងបានរស់រានមានជីវិតឡើងវិញ ។

X X X

# ២ - រឿងសេះឈើ

មានសេចក្ដីដំណាលថា មានជាងឈើម្នាក់ និងជាងដែកម្នាក់បានជជែកគ្នាកាន់តែខ្លាំងៗ ឡើង ។

ជាងដែកពោលកេតាទៅកាន់ជាងឈើថា: « ខ្ញុំធ្វើការប្រសើរជាងលោក! » ។

ជាងឈើតបវិញថា: « ខ្ញុំចេះកិច្ចការទាំងឡាយវិសេសវិសាលជាងលោក » ។

ជាងទាំងពីរជជែកគ្នាអស់កាលដ៏យូរមិនដាច់ស្រេច, ក៏ព្រមព្រៀងគ្នាថា នឹងទៅក្រាបបង្គំទូលព្រះមហាក្សត្រិយ៍ សូមទ្រង់ប្រោសព្រះរាជទានសម្រេចទៅតាមព្រះរាជយោបល់តាមការគួរគេទៅ ។

អ្នកទាំងពីរ លុះទៅដល់ព្រះបរមរាជវាំង ក៏បានចូលទៅគាល់ព្រះមហាក្សត្រិយ៍ ។ ព្រះអង្គទ្រង់មានព្រះរាជឧង្ការត្រាស់សួរអ្នកទាំងពីរថា: « តើលោកអញ្ជើញមកមានការអ្វី ? » ។

ជាងឈើក៏ក្រាបបង្គំទូលព្រះមហាក្សត្រថា: « ទូលព្រះបង្គំជាខ្ញុំជាជាងឈើ , ទូលព្រះបង្គំជាខ្ញុំយល់ថា គ្មានជាងឈើណាឲ្យជំនាញការជាងទូលព្រះបង្គំជាខ្ញុំសោះឡើយ , តែជាងដែកនេះបានអួតអាងខ្ពងថា ចេះការយ៉ាងជំនាញជាងទូលព្រះបង្គំជាខ្ញុំទៅទៀត » ។

ជាងដែកក៏ក្រាបបង្គំទូលព្រះមហាក្សត្រថា: «វត្ថុដែលទូលព្រះបង្គំជាខ្ញុំបានធ្វើ ជាវត្ថុដែលអ្នកទាំងពួងតែងតែសរសើរគ្រប់គ្នា តែជាងឈើនេះមកចេញកថាថា ខ្លួនចេះការប្រសើរជាងទូលព្រះបង្គំជាខ្ញុំទៅទៀត»។

អ្នកទាំងពីរក៏ក្រាបបង្គំទូលព្រះមហាក្សត្រតទៅទៀតថា: «សូមទ្រង់ព្រះមេត្តាប្រោស, សូមល្អងធូលីព្រះបាទ ទ្រង់វិនិច្ឆ័យចំពោះរឿងនេះ តើទូលព្រះបង្គំជាខ្ញុំទាំងពីរនាក់, អ្នកណាចេះការជំនាញជាងអ្នកណា!” ។

ព្រះរាជាទ្រង់មានព្រះរាជឱង្ការថា: «ឲ្យយើងវិនិច្ឆ័យយ៉ាងណាបាន, បើយើងមិនដែលបានស្គាល់នូវសមត្ថភាព មិនដែលបានឃើញនូវស្នាដៃរបស់លោកដល់ម្តងសោះ តែយើងអនុញ្ញាត ១០ ថ្ងៃ ឲ្យលោកទាំងពីរ ធ្វើវត្ថុអ្វីតាមចិត្តចុះ, រួចឲ្យលោកយកវត្ថុនោះមកឲ្យយើងពិនិត្យ » ។

ដប់ថ្ងៃក្រោយមក, អ្នកទាំងពីរក៏ចូលមកក្រាបបង្គំគាល់ ព្រះមហាក្សត្រិយ ឯព្រះបរមរាជវាំង, ជាងដែកបានយកត្រីមួយធំធ្វើពីដែក ។

ព្រះមហាក្សត្រិយ៍ ទ្រង់មានព្រះបន្ទូលសួរសីហនាទទៅកាន់ជាងដែកថា:

«តើត្រីនេះ មានប្រយោជន៍អ្វីខ្លះ ? ។

ជាងដែកក៏ក្រាបបង្គំទូលព្រះរាជាថា: " សូមទ្រង់ព្រះមេត្តាប្រោស, ត្រីនេះ អាចផ្ទុកនូវគ្រាប់ឈើមួយពាន់បាវ ហើយអាចហែលកណ្ដាលមហាសាគរបានថែមទៀតផង " ។

ព្រះរាជាទ្រង់ព្រះសម្រួលយ៉ាងខ្លាំង ហើយទ្រង់មានព្រះរាជឱង្ការថា: "វត្ថុធ្ងន់ម៉្លេះ, បើគេយកទៅដាក់លើទឹក, មុខជាលិចមិនខាន, ហើយគេថាវាចេះហែលដូចត្រីមែនទែន " តែទ្រង់មានព្រះបន្ទូលស្ងួរ. សីហនាទ ឲ្យយកគ្រាប់ឈើមួយពាន់បាវមកផ្ទុក ក្នុងពោះត្រីដែកនោះ, ហើយយកត្រីនោះបោះទៅក្នុងទឹក ទ្រង់មានព្រះរាជឱង្ការថា: "ត្រូវតែពិសោធន៍មើល " ។

តែគួរឲ្យប្លែកអស្ចារ្យ, ត្រីដែកនោះចេះហែលហើសនៅលើទឹកនោះដូចត្រីមែនទែន! អ្នកទស្សនាទាំងឡាយក៏មានចិត្តងឿងឆ្ងល់ពន់ពេក ។ ព្រះរាជាទ្រង់បានសរសើរជាងដែកនោះ ជាអនេកបរិយាយ ។

ទ្រង់មានព្រះរាជឱង្ការថា : "យើងសប្បាយចិត្តនឹងលោកពន់ពេក, យើងនឹងឲ្យគោរម្យងារជាផ្លូវការនៅក្នុងសំណាក់យើង " ។ រួចទ្រង់តែងតាំងជាងដែកជាមេសង្កាត់នៃរាជធានី ។

( នៅមានត )

# ភូមិសាស្ត្រសេដ្ឋកិច្ចនៃសហភាពអាហ្វ្រិកខាងត្បូង

លោក រ៉ូបារ្ឋមបែរត៍ អតីតសាស្ត្រាចារ្យ

នៃមហាវិទ្យាល័យច្បាប់ប្រទេសកម្ពុជា បាននិពន្ធក្នុងឆ្នាំ ១៩៥៩-៦០

លោក ញ៉ែម-ទឹម ប្រែសម្រួល

---

សហភាពអាហ្វ្រិកខាងត្បូង ស្ថិតនៅចុងខាងត្បូងបង្អស់ នៃទ្វីប-អាហ្វ្រិក, ជាប្រទេសចំណុះចក្រភពអង់គ្លេស, កកើតទៅជាសហរដ្ឋកាលពីឆ្នាំ ១៩១០ ។ សហភាពអាហ្វ្រិកខាងត្បូងបម្រុងនឹងបោះបង់ចោលចក្រភពអង់គ្លេស ពីឆ្នាំ ១៩៦១ ។ សហរដ្ឋនេះ មានផ្ទៃដីទំហំ ១១.២០០ ០០០គ.ម$^2$, ដោយឥតគិតបញ្ចូលផ្ទៃ នៃរដ្ឋអាហ្វ្រិកទិសនិរតីផង ដែលជាអតីតប្រទេសចំណុះអាល្លឺម៉ង់ ហើយមានផ្ទៃដីទំហំ ៨០០.០០០.គ.ម$^2$ ។

នៅខាងត្បូងនៃប្រទេស. មានរដ្ឋមួយហៅថាឡឺកាប់ ។ រដ្ឋកាប់នេះ ប្រកបទៅដោយព្រៃភ្នំធំ-តូច មានកំពស់មធ្យមប្រហែល ២០០០ម. ហើយភ្នំទាំងនោះ បានលយទៅកាន់ទិសខាងជើង កាត់តាមខ្ពង់រាប ហៅថា ការូស ។

នៅទិសអគ្នេយ៍នឹងនៅទិសខាងកើតនៃប្រទេស, មានជួរភ្នំដ៏ខ្ពស់មួយ

ដែលលយទៅតាមត្រង់ទៅមហាសមុទ្រឥណ្ឌា ហៅថា ដ្រាកិនស្បែក មានកំពស់រហូតដល់ ៣.៧០០ម ។

ចំណែកឯនៅខាងក្នុងនៃប្រទេសវិញ, ត្រង់តំបន់ខាងកើត, គេឃើញមានខ្ពង់រាបយ៉ាងខ្ពស់មួយ មានកំពស់ពី ១០០០ ទៅ ១៨០០ម-ហៅថា វែលដ៍ (Veld) គឺវាលស្មៅធំ ។

សហភាពអាហ្វ្រិកមានផែនដីរាងដូចជាចង្អេរ គឺខ្ពស់ជុំវិញ តាមកណ្ដាល ហើយនៅកណ្ដាលនៃផ្ទៃប្រទេស, គេឃើញមានវាលខ្សាច់មួយដ៏ធំហៅថា កាឡាហារី ។

អំពីធាតុអាកាស:

ផែកខាងត្បូងនៃប្រទេសមានធាតុអាកាសនៃសមុទ្រ មេឌីទែរ៉ាណេ គឺសិសិររដូវក្ដៅ, វស្សន្តរដូវ ស្ងួត ។ ភ្លៀងច្រើនធ្លាក់នៅសិសិររដូវ ឯរុក្ខជាតិ គេសង្កេតឃើញមានចំការទំពាំងបាយជូ, ដើមឈើមានផ្លែ, ដើមក្រូចនឹងដើមឈើឯទៀត ដែលមានផ្លែស្រដៀងគ្នានឹងក្រូចដែរ ។

ខេត្តណាតាល់(១) មានធាតុអាកាសក្ដៅ ព្រោះស្ថិតនៅក្រោមផ្លូវគោចរនៃព្រះអាទិត្យ ។ នៅក្នុងខេត្តនេះ គេសង្កេតឃើញផលដំណាំដូចតទៅ : ចេក, អំពៅ នឹងដើមឈើល្អៗឯទៀត ដែលមានដុះតែនៅក្នុងប្រទេសក្ដៅ ។

---

១– ជាខេត្តមួយនៃសភាពអាហ្វ្រិកខាងត្បូង ។

ភរីសាស្ត្រ (Hydrographie) :

ប្រទេសអាហ្វ្រិកពុំសូវសម្បូរផ្លូវទឹកទេ ។ គេសង្កេតឃើញមានតែទន្លេធំមួយហៅថា អូរ៉ង់ និងដៃទន្លេដែលនេះឈ្មោះ វ៉ាល់ ។

អំពីប្រជាជននិងបញ្ហាមនុស្ស :

ប្រជាជនពិតប្រាកដ ដែលកើតក្នុងស្រុកមានចំនួនតែ ៤០ ឬ ៧០ ពាន់ប៉ុណ្ណោះ ។ ប្រជាជនទាំងនេះ រស់នៅតាមរបៀបមនុស្សបុរាណ នៅក្បែរវាលខ្សាច់ ក្នុងខ្ទមតូចៗធ្វើពីមែកឈើស្លឹកឈើ ប៉ុន្តែសព្វថ្ងៃជិតបាត់អស់ហើយ ប្រកបរបរបាញ់សត្វ និងដើររើសពងសត្វ ។

ក្រៅពីនេះ មានពួកប្រជាជនស្បែកខ្មៅមកពីទ្វីបអាហ្វ្រិកកណ្ដាល បានចូលមកកាត់ក្បាលក្នុងប្រទេស ។ បណ្ដាប្រជាជនទាំងនោះ, គេសំគាល់ឃើញ :

– ពួកហូតង់តូត, សុទ្ធតែជាអ្នកគង្វាលសត្វនៅតំបន់ខាងលិចនៃប្រទេស ។

– លុះមកដល់សតវត្សរ៍ទី ១៤ ឬ ១៦ មានជនស្បែកខ្មៅមួយពួកទៀតឈ្មោះ បង់ទូ, មានអារ្យធម៌គ្រាន់បើជាងពួកមុន, គឺចេះភ្ជួររាស់, ចេះដាំដំណាំ, បានចូលមកលុកលុយសហភាពអាហ្វ្រិកខាងត្បូងៗ ពួកនេះ រស់នៅតំបន់ខាងកើតនៃប្រទេស ហើយបានតស៊ូយ៉ាងពេញទំហឹងប្រឆាំងនឹងពួកស្បែកស ។

– បន្ទាប់មកនៅសតវត្សរ៍ទី ១៧, ប្រជាជនដែលនៅក្រោមចំណុះប្រទេសហុល្លង់ បានចូលមកតាំងនៅក្នុងតំបន់ខាងត្បូងបង្អស់ នៃប្រទេសដែលគេហៅថា ខេត្តកាប់ ។ តមក លុះមកដល់ចុងសតវត្សរ៍ទី ១៧ បារាំងដែលជាអ្នកកាន់សាសនាប្រូតេស្តង់ បានចូលមកនៅជាមួយនឹងពួកអ្នកអាណានិគមហុល្លង់ ។ ពួកប្រជាជនចំណុះហុល្លង់នេះ សុទ្ធតែជាអ្នកកសិករ និងជាអ្នកចិញ្ចឹមគោដែលគេឲ្យឈ្មោះថា ប៊ួរ ។ ពួកកសិករក្នុងអាណានិគមតាំងនោះ បានប្រើប្រាស់ជនជាតិស្បែកខ្មៅឲ្យធ្វើជាកម្មករខ្លួន និងបានញ៉ាំងពួកជនជាតិស្បែកខ្មៅឲ្យទៅជាទាសកម្មករ ។

– នៅឆ្នាំ ១៨១៤ ខេត្តកាប់ក៏ត្រូវប្រគល់ឲ្យទៅរាជការអង់គ្លេស ។ ពួកកសិករក្នុងអាណានិគមអង់គ្លេស ក៏ចូលមកតាំងទីលំនៅ ក្នុងខេត្តកាប់ ។ រួចនៅឆ្នាំ ១៨៣៣ , អំពើទាសភាពក៏ត្រូវគេបំបាត់ចោលទាំងអស់ នៅក្នុងបណ្ដាប្រទេសដែលជាអាណានិគមអង់គ្លេស ។ ដូច្នោះដោយគ្មានពួកទាសកម្មករ សម្រាប់ជួលធ្វើការតទៅទៀត , ពួកប៊ួរ ក៏សម្រេចចិត្តដើរចេញពីខេត្តកាប់ , ទៅនៅក្នុងខេត្តណាតាល់វិញ ប៉ុន្តែមកដល់ឆ្នាំ ១៨៤៣ , ពួកអង់គ្លេសបានចូលមកកាន់កាប់ខេត្តណាតាល់ទៀត, ពួកប៊ួរ[១] ក៏ចេញពីខេត្តណាតាល់ទៀត ទៅនៅលើខ្ពង់រាប

---

១. ប្រជាជនដែលរស់នៅក្នុងរដ្ឋត្រង់ស្វាល់ និងអូរ៉ង់ហ្វ្រ បានឈ្មោះថា ប៊ួរ (Boers) មានដើមកំណើតមកពីប្រទេសហុល្លង់ ។

កណ្តាលប្រទេស , រួចក៏ញុំាងខេត្តត្រង់ស្វាល់ និងអូរ៉ង់(១) ឲ្យទៅជាសាធារណរដ្ឋ ។

នៅឆ្នាំ ១៨៧០ , គេបានរកឃើញអណ្តូងរ៉ែពេជ្រដ៏សំខាន់ពីរនៅក្នុងរដ្ឋអូរ៉ង់ , និងអណ្តូងរ៉ែមាសដ៏សម្បើមមួយនៅក្នុងរដ្ឋត្រង់ស្វាល់ ក្នុងឆ្នាំ ១៨៨៥ ។

ពួកអង់គ្លេសសំឡឹងឃើញសម្បត្តិ ដ៏សម្បើមពន់ពេកក្នុងលោកនេះ ក៏ប្រើមធ្យោបាយចង់ដណ្តើមយកសាធារណរដ្ឋពីរនេះមកកាន់កាប់ ។ អាស្រ័យហេតុនេះសង្គ្រាមក៏កើតឡើងនៅឆ្នាំ ១៨៩៩ ។ លុះដល់ឆ្នាំ ១៩០២ អង់គ្លេសបានច្បាំងឈ្នះ ហើយក៏បញ្ចូលរដ្ឋពីរនេះ ឲ្យនៅក្រោមអាណាព្យាបាលខ្លួន ។ នៅឆ្នាំ ១៩១០, ខេត្តទាំងបួនគឺ: កាប់, ណាតាល់, ត្រង់ស្វាល់ និងអូរ៉ង់ បានរួមគ្នាទៅជាសហរដ្ឋមួយ បានឈ្មោះថា សហភាពអាហ្វ្រិកខាងត្បូង ។

សព្វថ្ងៃនេះ សហភាពអាហ្វ្រិកខាងត្បូងមានប្រជាជនទាំងអស់ចំនួន ១៣.៥០០.០០០ នាក់ គឺមានជាតិស្បែកស ចំនួន ៣.០០០.០០០នាក់ (៣ លាន) ។ ក្នុងបណ្តាជនជាតិស្បែកសបីលាននាក់នេះ ៦០% ជាជាតិប៊ួរ ( កសិករ ) ៤០% ជាប្រជាជាតិមានដើមកំណើតចេញមកពីជាតិអង់គ្លេស គឺជនជាតិខាងក្រោយនេះហើយ ដែលជាអ្នកត្រួតត្រា

---

១– រដ្ឋមួយនៃសហភាពអាហ្វ្រិកខាងត្បូង ។

សេដ្ឋកិច្ចក្នុងប្រទេស ។ ក្រៅពីពួកស្បែកស គេសង្កេតឃើញ ជនស្បែកខ្មៅចំនួន ៩ លាននាក់, កូនកាត់ ១ លាននាក់ នឹង ៤ សែននាក់ជាជាតិឥណ្ឌា ។

រឿងប្រជាជននេះ បានចោទជាបញ្ហាយ៉ាងធំក្រៃលែង ព្រោះពួកស្បែកស ប្រកាន់ពណ៌សម្បុរហួសហេតុ ហើយចង់តែធ្វើជាត្រួតត្រាលើប្រជាជាតិស្បែកខ្មៅ ។ បញ្ហានេះ កាន់តែស្មុគស្មាញទៅៗ រកដោះស្រាយពុំបាន ដោយពួកអង់គ្លេសចង់សម្រួលស្ថានការណ៍ឲ្យបានស្រួល កុំឲ្យកើតទៅជាចាស់ទែងគ្នា, ឯជាតិបួរដែលមានចំនួនមនុស្សកើតក្នុង ១ ឆ្នាំៗ ច្រើនលើសលុបជាងជាតិស្បែកស, ចង់តែញ៉ាំងស្ថានការណ៍ឲ្យរកតែជួន់ជួរឡើង ។ ដូច្នេះ នៅក្នុងប្រទេសនោះ គេសង្កេតឃើញមានភាសាពីរគឺ: ភាសាអាហ្វ្រិកមួយ នឹងភាសាបួរមួយ ។

ពួកបួរចង់ប្រកាសសាធារណរដ្ឋ, ត្រូវការឲ្យមានទង់ជាតិជានិមិត្តរូបនៃប្រទេស, នឹងសុំចេញពីសមាគមអង់គ្លេស ។

ជាយូរក្រែលណាស់មកហើយ គេបានចែកដីដល់ជនជាតិស្បែកខ្មៅធ្វើរបរ, តែដីនោះជាដីអាក្រក់គ្មានជីជាតិធ្វើដំណាំពុំកើត ហើយប្រ-ជាជនខ្មៅកាន់តែកើតច្រើនឡើងៗ លុះត្រាតែសព្វថ្ងៃចង្អៀតរកដីនៅពុំចង់បាន ។ ដូច្នោះ ជនជាតិស្បែកខ្មៅពុំអាចបបួលគ្នារស់នៅលើដីនោះ

ទៀតបានឡើយ ,  ម៉្លោះហើយ ត្រូវតែដើរចេញពីដីដែលគេចែកឲ្យនោះ ដើម្បីទៅរកការធ្វើនៅទីដទៃៈក្រៅទៀត,  ដូចជាទៅធ្វើការ នៅក្នុងអណ្ដូងរ៉ែ, ក្នុងកេងចក្រ ។ ឯធ្វើការនេះ គឺធ្វើការដោយជាប់កិច្ចសន្យាជាមួយនឹងនាយទុនចំនួន ២ ឬ ៣ ឆ្នាំ  ហើយពួកខ្មៅត្រូវរស់នៅក្នុងសង្កាត់មួយដោយឡែក  គ្មានសិទ្ធិចេញទៅលេងក្រៅពីកន្លែងដែលគេបានកំណត់ឲ្យនោះឡើយ ។ ពួកស្បែកខ្មៅទោះបីធ្វើការដូចគ្នានឹងជនស្បែកសក៏ដោយ, ក៏ត្រូវបានប្រាក់បំណាច់តិចជាងជនស្បែកសដែរ ។

គេសង្កេតឃើញជនជាតិស្បែកខ្មៅ  ធ្វើការនៅក្នុងអណ្ដូងរ៉ែចំនួន ៣០០.០០០ នាក់  នៅក្នុងកេងឧស្សាហកម្មចំនួន ៥០០.០០០ នាក់ ។ ក្រៅពីនេះ, គេប្រកបរបរកសិកម្ម  ហើយមានជីវភាពគ្រាន់បើជាងអ្នកធ្វើការនៅក្នុងអណ្ដូងរ៉ែ, នៅក្នុងកេងចក្រ ។ ពួកប្រជាជនស្បែកខ្មៅគ្មានសិទ្ធិធ្វើនយោបាយទេ,  ហើយត្រូវធ្វើដំណើរទៅណាមកណាតាមយានជំនិះផ្សេងពីពួកស្បែកស  ទីងរៀនក្នុងសាលាខុសពីពួកស្បែកស ។ អាកប្បកិរិយានៃពជការអង់គ្លេស ដែលប្រើនយោបាយប្រកាន់ពណ៌សម្បុរហួសហេតុនេះ អាចនឹងបណ្ដាលឲ្យកើតទៅជារឿងរ៉ាវដ៏ធំពុំខាន  ព្រោះចំនួន ២-៣ ឆ្នាំទៅខាងមុខទៀត  ពួកជនជាតិស្បែកខ្មៅនឹងមានចំនួន ៤ ៥ ដងលើសប្រជាជាតិស្បែកស  ហើយម្យ៉ាងទៀត, ដោយរដ្ឋឯទៀតៗ

នៅក្នុងទ្វីបអាហ្វ្រិកបានទទួលឯករាជ្យយ៉ាងច្រើនមកហើយ សហភាពអាហ្វ្រិកខាងត្បូងប្រាកដជាកើតសម្បជញ្ញៈ ចង់បានឯករាជ្យនឹងគេដែរពុំខាន ( រឿងនេះ បានកើតមានជាស្រេចទៅហើយ កាលពីដើមឆ្នាំ ១៩៦១) ។ មិនតែប៉ុណ្ណោះ ពួកស្បែកសបានប្រើអាកប្បកិរិយាដូចគ្នានេះ ទៅលើពួកឥណ្ឌា ដែលរស់នៅក្នុងសហភាពអាហ្វ្រិកនេះ ប្រកបរបរដាំអំពៅនៅក្នុងខេត្តណាតាល់ ហើយជារៀងរាល់ឆ្នាំ ប្រទេសឥណ្ឌាតែងលើកបញ្ហានេះ ទៅដាក់ជូនអង្គការសហប្រជាជាតិវិនិច្ឆ័យ ប៉ុន្តែ គ្មានបានលទ្ធផលអ្វីសោះ ។

ប្រជាជនពុំសូវស្ថិតនៅក្នុងទីក្រុងទេ ប៉ុន្តែគេសង្កេតឃើញមានទីក្រុងធំៗ ខ្លះ ដូចជាឡឺកាប (៧០០·០០០នាក់) ជាកំពង់ផែទី១ នៃប្រទេស ។ ទីតាំងស្ថិតបែរមុខទៅរកមហាសមុទ្រ ។ ឡឺកាបនេះជាកន្លែងនាវាមួយយ៉ាងសំខាន់ ហើយជាកន្លែងសំខាន់បំផុតក្រៃលែង សំរាប់នាវាឈប់យកស្បៀង នៅពេលដែលព្រែកជីកស៊ុយអេត្រូវគេបិទមិនឲ្យនាវាចេញចូល។

- ហ្សូហាន់ណេស្បួរ ១.០០០.០០០នាក់ ។ កាលពីឆ្នាំ ១៨៨០ ទីក្រុងនេះជាភូមិតូចមួយ ។ ឥឡូវនេះ, ទីក្រុងហ្សូហាន់ណេស្បួរជាទីក្រុងធំក្រៃលែងតាមរបៀបអាមេរិកាំង, កើតឡើងដោយសារសម្បត្តិមាស, ជាទីក្រុងសម្បូរទៅដោយមាសជាងគេបង្អស់ នៅក្នុងសាកលលោក ។

- ខៀវចេង ៤០០.០០០ នាក់ , ជាកំពង់ផែដ៏ធំនៃរដ្ឋណាតាល់ ។

- ប្រេតូរីយ៉ា ជាពដធានី ទីងជាទីតាំងនៃរដ្ឋាភិបាល ទីងជាមជ្ឈដ្ឋានឧស្សាហកម្មមួយយ៉ាងសំខាន់ ។

អំពីកសិកម្ម .- របរកសិកម្មមានសារៈសំខាន់តែល្មមទេ ព្រោះដីដែលអាចធ្វើដំណាំបាន មានតិចណាស់ គឺ ១/១៥ នៃផ្ទៃដីក្នុងប្រទេសដែលបានធ្វើដំណាំ ។ នៅក្នុងខេត្តកាប់, គេមានដាំស្រូវសាលី ទំពាំងបាយជូ , ឈើមានផ្លែ ចំណែកឯនៅក្នុងខេត្តណាតាល់វិញ ដែលមានធាតុអាកាសក្តៅ គេដាំអំពៅ, ដាំរុក្ខជាតិនៃប្រទេសក្តៅ ។

ការចិញ្ចឹមសត្វ .- ការចិញ្ចឹមសត្វមានសារៈសំខាន់ជាងកសិកម្មទៅទៀត ដោយហេតុថា នៅក្នុងវាលការូសសម្បូរស្មៅណាស់, គេសង្កេតឃើញមានចៀមចំនួន ៣៥ លានក្បាល , កាត់ពូជមកពីចៀមអេស្ប៉ាញ៉ុលហៅថា មេរីណូស ។ ចៀមមេរីណូសនេះ ផ្តល់រោមល្អណាស់ ហើយសហភាពអាហ្វ្រិកខាងត្បូងជាប្រទេសមួយក្នុងបណ្តាប្រទេសឯទៀតក្នុងសាកលលោក ដែលសម្បូរដោយរោមចៀម ។ នៅលើវាលស្មៅហៅវែល , គេមានចិញ្ចឹមសត្វគោដើម្បីយកសាច់និងទឹកដោះ ។

(នៅមានត)

## ផ្នែកកំណត់និងប្រវត្តិការណ៍

# អនុសំវច្ឆរមហាសន្និបាតនៃមន្ត្រីសង្ឃលើកទី ១៨

លោក ជង់-វង់ រៀបរៀង

---

អនុសំវច្ឆរមហាសន្និបាតនៃមន្ត្រីសង្ឃលើកទី ១៨ បានធ្វើចាប់តាំងពីថ្ងៃសៅរ៍ ១៥ កើត ដល់ថ្ងៃព្រហស្បតិ៍ ៥ រោច ខែបុស្សឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥០៤ (២០-២៥ មករា ១៩៦២) ក្រោមអធិបតីភាពនៃសម្តេចព្រះសង្ឃនាយកទាំង ២ គណ: គឺនៅវត្តបទុមវតីរាជវរារាម និងវត្តឧណ្ណាលោម ។

### ទិវាទី ១

ថ្ងៃសៅរ៍ ទី ២០ មករា ១៩៦២, ពីម៉ោង ១៤ ទៅម៉ោង ១៥ នៃថ្ងៃនោះ ជាពេលបើកឱកាសធ្វើមហាសន្និបាតនៃមន្ត្រីសង្ឃ, សហជីវិន ស៊ុន.បុប្ផកោ រដ្ឋលេខាធិការក្រសួងធម្មការ ដោយមានសហការីរបស់លោកជូនដំណើរផង បានអញ្ជើញទៅកាន់វត្តបទុមវតី និងវត្តឧណ្ណាលោម ដើម្បីបើកសម័យធ្វើមហាសន្និបាត ។

### ទិវាទី ២

ថ្ងៃអាទិត្យទី ២១ មករា ១៩៦២, ពេលព្រឹក ម៉ោង ៧ និង៣០នាទី មានការនិមន្តព្រះសង្ឃទាំង ២ គណ: ចំនួន ៤០ អង្គ ស្វាធ្យាយ

ព្រះសត្ថុប្បករណាកិច្ច ទទួលព្រះរាជកុសលថ្វាយចំពោះព្រះបិតរ ទៅព្រះចេតិយទាំងគូ ខាងមុខព្រះវិហារព្រះកែវមរកត ។ លុះដល់ម៉ោង ១០ និង ៣០ នាទី ព្រះសង្ឃទាំងពីរគណៈ ទទួលចង្ហាន់តាមវត្តគឺនៅវត្តបទុមវតី ទីងវត្តខុណ្ណាលោម ចំពោះមុខរដ្ឋមន្ត្រីក្រសួងធម្មការ ។

ពេលរសៀលម៉ោង ១៦ ក្រសួងធម្មការ បានបើកធ្វើពិធីអនុសំ-វច្ឆរមហាសន្និបាតនៃមន្ត្រីសង្ឃ លើកទី ១៨ នៅយ៉ាងនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ នៃសម្តេចព្រះមហា-ក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង ។

នៅក្នុងប្រារព្ធពិធីនោះ គេបានសង្កេតឃើញ សម្តេចព្រះមហា-សុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ, សម្តេចព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្តិកនិកាយ , ព្រះពោធិវង្ស ហួត-តាត ចាងហ្វាងខួទៅនៃពុទ្ធិកសិក្សា , ព្រះសង្ឃជារាជាគណៈ ឋានានុក្រម មេគណ អនុគណ គ្រប់ខេត្តគ្រប់ស្រុក ចៅអធិការគ្រប់វត្តក្នុងរាជធានីព្រមទាំងព្រះសង្ឃជាច្រើនពាន់អង្គទៀត ដែលបាននិមន្តមកអំពីវត្តនានាក្នុងរាជធានីនឹងខេត្តក្រៅ ដើម្បីប្រជុំក្នុងមហាសន្និបាតនេះ ដែលប្រកបដោយរបៀបរៀបរយ សមរម្យទៅតាមសមណសារូប ។

ផ្នែកខាងឥស្សរជន គេបានសង្កេតឃើញ អ្នកអង្គម្ចាស់នរោត្តម-កន្តុល ប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ ឯកឧត្តមទេព-ផន ទេស-

រដ្ឋមន្ត្រីទទួលបន្ទុកខាងក្រសួងផែនការនិងសាលាក្រុងភ្នំពេញ ឯកឧត្តម ស៊ីន-សាន ទេសរដ្ឋមន្ត្រីទទួលបន្ទុកខាងក្រសួងហិរញ្ញវត្ថុ និង សេដ្ឋកិច្ច-ជាតិ ព្រមទាំងសមាជិកព្រះរាជរដ្ឋាភិបាល សមាជិកនៃសភាទាំងពីរ, ខាងក្រសួងធម្មការ មានសហជីវិន ស៊ុន-បុប្ផោ រដ្ឋលេខាធិការក្រ-សួងធម្មការ ជាអ្នកតាក់តែងពិធី សហជីវិន ចន្ទ-ស៊ុន នាយកនៃការិយា-ល័យ សហជីវិន លឹម.ង៉ូន-សេង នាយខុទ្ទកាល័យ ព្រមទាំងមន្ត្រីដំណាង ក្រសួងនានា ប្រធានពុទ្ធិកសមាគម ប្រធានសមាគមគិលានសង្គ្រោះ សាស្ត្រាចារ្យ នៃមហាវិទ្យាល័យព្រះសីហនុរាជ និងពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ព្រមទាំងមន្ត្រីរាជការជាច្រើនរូបទៀត បានស្តេចយាង អញ្ជើញមក ដើម្បីរួបរួមជាកិត្តិយសក្នុងពិធីនេះដែរ ។

នៅវេលាម៉ោង ១៦ និង ៣០ នាទី សម្តេចព្រះមហាក្សត្រិយានីព្រះមាតាជាតិ និងសម្តេចព្រះប្រមុខរដ្ឋ ជាទីគោរពនិងជាទីស្នេហាស្មើដោយជីវិតនៃយើង ដោយមានឯកឧត្តមផូ-ព្រឿង អនុប្រធានឧត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក ឯកឧត្តមគូ.រុន សមាជិកឧត្តមក្រុមប្រឹក្សាព្រះរាជ.បល្ល័ង្ក ព្រមទាំងព្រះរាជបរិពារផ្ទាល់ព្រះអង្គជាច្រើនទៀត អមព្រះរាជដំណើរផង បានស្តេចយាងមកដល់កន្លែងប្រារព្ធពិធី ដោយបានទទួលគារវកិច្ចយ៉ាងខ្ពង់ខ្ពស់បំផុត អំពីក្រុមទាហានរក្សាព្រះអង្គ ដែលបានលើក

អាវុធធ្វើនូវកិច្ច និងបន្លឺនូវបទភ្លេងបវេលា ថ្វាយជាព្រះរាជកិត្តិយសចំពោះព្រះអង្គផង ។

ក្រោយពេលដែលស្ដេចយាងទទួលការក្រាបថ្វាយបង្គំ អំពីឥស្សរ-ជនជាន់ខ្ពស់ និងមន្ត្រីអ្នករាជការទាំងឡាយរួចហើយ ក្រុមតន្ត្រីព្រះរាជទ្រព្យ ក៏បានបន្លឺនូវបទភ្លេងជាតិ ថ្វាយជាព្រះរាជកិត្តិយសចំពោះព្រះអង្គ ។ តមក ឥស្សរជនទាំងឡាយ ដែលនៅរង់ចាំក្រាបថ្វាយបង្គំទទួល និងសំដែងសេចក្ដីស្វាមីភក្ដិ ចំពោះព្រះអង្គ ក៏បានដង្ហែព្រះរាជដំណើរចូលថ្វាយបង្គំព្រះសង្ឃ ហើយស្ដេចគង់ប្រថាប់ លើព្រះសុវណ្ណកោច្ឆៈ នៅក្នុងយ៉ៃនពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រិត ដោយព្រះឥរិយាបថយ៉ាងសមរម្យ ។

លុះទីប្រជុំបានរៀបរយរួចហើយ, សហជីវិន ស៊ិន.ប៊ុប្ផោ រដ្ឋ-លេខាធិការក្រសួងធម្មការ បានថ្លែងសុន្ទរកថាមួយ មានសេចក្ដីដូចតទៅនេះ ៖

សូមព្រះតេជៈដ៏កល់លើត្បូង,

សូមព្រះរាជទានក្រាបបង្គំទូល សម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិត

សូមព្រះរាជទានក្រាបបង្គំទូល សម្ដេចព្រះឧបយុវរាជព្រះប្រមុខរដ្ឋ

សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។

ក្នុងនាមនៃក្រសួងធម្មការ សាសនៈសិក្សាធិការ និងក្នុងនាមផ្ទាល់នៃទូលព្រះបង្គំជាខ្ញុំ ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានព្រះបរមរាជវរោកាស ថ្វាយនូវព្រះមហាករុណាធិគុណដ៏ថ្លៃថ្លា ដោយកតញ្ញូតាធម៌ដ៏ស្មោះស្ម័គ្រ និងដោយគារវៈភក្តី ស្វាមីភក្តិ ចំពោះសម្តេចព្រះមាតាជាតិ និងសម្តេចសហជីវិន ដែលទ្រង់សព្វព្រះរាជហឫទ័យ ស្តេចយាងមកជាព្រះរាជាធិបតី ក្នុងឱកាសបើកពិធីអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទី ១៨ សម្រាប់ឆ្នាំឆ្លូវត្រីស័ក ដោយសោមនស្សចេតនាជាទីបំផុត ។

សូមទ្រង់ព្រះមេត្តាប្រោស ,

ក្នុងវារៈតទៅនេះ ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានព្រះបរមរាជវរោកាស លួងធូលីព្រះបាទ ដើម្បីប្រគេនពតិមានខ្លះ ចំពោះព្រះសង្ឃ មានសម្តេចទាំង ២ ព្រះអង្គជាប្រធាន ដែលបាននិមន្តពីទីនានាទាំងក្នុងក្រុង និងខេត្តក្រៅ ទូទៅក្នុងព្រះរាជអាណាចក្រទាំងមូល មករួមប្រជុំក្នុងមហាសន្និបាតនេះ ដូចតទៅ ៖

សូមថ្វាយបង្គំសម្តេចទាំង ២ ព្រះអង្គ ព្រមទាំងព្រះថេរានុត្ថេរៈជាព្រះរាជាគណៈ ឋានានុក្រម មេគណ- អនុគណ- ចៅអធិការ គ្រប់ព្រះអង្គដោយគោរព ។

ខ្ញុំព្រះករុណាសូមថ្វាយនូវអំណរព្រះគុណ ជាអតិបរមាចំពោះសម្តេច និងព្រះករុណាគ្រប់ព្រះអង្គ ដែលបាននិមន្តមកជួបជុំនេះ ព្រោះការជួបជុំ

នេះបង្កើតនូវបរិយាកាសមួយដ៏ល្អប្រពៃ ដែលអាចផ្តល់នូវសេចក្តីសុខចំរើន រុងរឿងជូនជាតិសាសនាព្រះរាជបល្ល័ង្ក និងមាតុប្រទេសតទៅជាអនេកប្បការ ដោយហេតុត្រូវតាមគន្លងអបរិហានិយធម៌ពុទ្ធសាសនាដែលសំដែងថា : ការប្រជុំគ្នាប្រជុំដោយមូលមតិគ្នាជាឯកច្ឆន្ទ រមែងបានសេចក្តីរុងរឿងចំរើន ឈ្នះមារសត្រូវគ្រប់ទិសានុទិស ឥតនរណាផ្ចាញ់បានឡើយ ។

សម្តេច !

ព្រះករុណាគ្រប់ព្រះអង្គ !

ដូចសម្តេចនិងព្រះករុណាគ្រប់ព្រះអង្គបានជ្រាបស្រាប់ហើយ តាំងពីពុទ្ធសតវត្សទី ៣ ដែលព្រះពុទ្ធសាសនាបានមកប្រតិស្ឋានទៅប្រទេសខ្មែរយើងមក ព្រះពុទ្ធសាសនាចេះតែមានជាប់ដកបរៀងមក រហូតដល់សព្វថ្ងៃ ពុំដែលបាត់សូន្យក្នុងកាលណាមួយឡើយ ។ ខ្មែរទាំងប្រទេសសុទ្ធសឹងជាពុទ្ធសាសនិក មានសទ្ធាដ៏ស្មោះចំពោះត្រៃសរណគមន៍ ។ លទ្ធផលដ៏ប្រសើរ ការរីកសាយទូលំទូលាយ នៃព្រះពុទ្ធសាសនាក្នុងកម្ពុជាណាចក្រនេះ គឺអាស្រ័យដោយបុព្វហេតុជាច្រើន តែជាពិសេសគឺដោយសារព្រះរាជូបត្ថម្ភដ៏មុះមុត នៃព្រះមហាក្សត្រយើងគ្រប់ព្រះអង្គព្រមទាំងព្រះរាជវង្សានុវង្ស ។

សព្វថ្ងៃនេះ គឺដូចជាកាលជំនាន់ព្រះបាទអសោកមហារាជដែរ ព្រះរាជបល្ល័ង្កនិងព្រះរាជវង្សានុវង្ស ព្រមទាំងព្រះរាជរដ្ឋាភិបាល ដែលមាន

សម្តេចព្រះឧបយុវរាជ ជាព្រះអគ្គមគ្គទេសក៍ដ៏ឆ្នើម ទ្រង់បានយកព្រះទ័យទុកដាក់ខំខ្នះខ្នែងលើកស្ទួយពុទ្ធនិយម ឲ្យមានរបៀបរៀបរយល្អ ថ្លៃថ្នូរ ឧត្តុង្គឧត្តម សមជាទីពឹងផ្អែកនៃសត្វលោក និងជាទីគោរពសក្ការៈនៃជនានុជន គ្រប់ប្រភេទ គ្រប់ជាន់ថ្នាក់ ។ ទ្រង់បានធ្វើកិត្តិសព្ទកិត្តិនាមនៃព្រះពុទ្ធ-សាសនាឲ្យលេចឮសុសសាយក្លីគ្រប៖ពេញពិភពលោក ។ ប្រទេសនានា ជាពុទ្ធសាសនិកក្ដី ពុំមែនជាពុទ្ធសាសនិកក្ដី សឹងបានសំដែងសេចក្ដីកោត-សរសើរ បានទទួលស្គាល់ថាប្រទេសកម្ពុជា មានភ័ព្វសំណាងល្អណាស់ ព្រោះជារដ្ឋអព្យាក្រិតកាន់ព្រះពុទ្ធសាសនា មានការប្រតិបត្តិជាមជ្ឈិមា-បដិបទា តាមលំអាននៃព្រះពុទ្ធោវាទ ពីព្រោះព្រះសង្ឃខ្មែរទាំងប្រទេស ទោះភិក្ខុក្ដីសាមណេរក្ដី ក្រោមការដឹកនាំដ៏ភ្លឺស្វាង នៃសម្ដេចព្រះសង្ឃ-នាយកទាំង ២ ព្រះអង្គ និងព្រះរាជាគណៈ ឋានានុក្រម មេគណ-អនុគណ ចៅអធិការឧបជ្ឈាយាចារ្យ ព្រមទាំងភិក្ខុសាមណេរជាបរិស័ទ ពុំបាន ភ្លេចនូវព្រះបណ្ដាំនៃព្រះពុទ្ធជាបរមគ្រូ ដែលទ្រង់បានផ្ដាំថា ៖ ព្រះពុទ្ធ-សាសនានឹងចំរើនរុងរឿងក្ដី សាបសូន្យទៅក្ដី ក៏ដោយសារតែកូនចៅតថាគត ។

ដើម្បីជាទស្សនានុត្តរិយៈ ខ្ញុំព្រះករុណាសូមបញ្ជាក់ថា ទោះបីជា-មានមធ្យោបាយដ៏ខ្សត់ខ្សោយយ៉ាងណាក៏ដោយ ក្នុងក្របខ័ណ្ឌនៃចលនាសង្គមរាស្ត្រនិយម ប្រទេសយើងបានឧបត្ថម្ភដោយពេញលក្ខណៈ ដល់

ព្រះពុទ្ធសាសនាច្រើនបែបច្រើនបទ បានព្យាយាមពង្រីកព្រះពុទ្ធសាសនាឲ្យរីកសាយទៅក្នុងសាកលលោក មានទំនុកបំរុងសមណៈនិស្សិតដែលទៅបន្តវិជ្ជាខាងសាសនានៅនានាប្រទេសជាដើម ហើយជាពិសេសបានរៀបចំធ្វើពិធីបុណ្យធំៗ ភស្តុតាងដូចបុណ្យព្រះអរហន្តធាតុ បុណ្យពុទ្ធសករាជ ២.៥០០ ដែលហៅថា បុណ្យពាក់កណ្ដាលសាសនា ដ៏មហោឡារិកព្រមទាំងបានចាត់គណៈប្រតិភូជាច្រើន ឲ្យទៅរួមប្រជុំក្នុងពិធីបុណ្យពុទ្ធសករាជ ២៥០០ ជាច្រើននគរ ឲ្យទៅរួមប្រជុំក្នុងមហាសន្និបាតដែលហៅថា សន្និសីទពុទ្ធិកសមាគមពិភពលោក ក្នុងប្រទេសនានាមានប្រទេសស្រីលង្កាជាដើម ហើយជាពិសេសនៅពេលថ្មីៗនេះ បានចាត់ចែងធ្វើក្នុងលើកទី ៦ នៅក្រុងភ្នំពេញយើង ពីថ្ងៃទី ១៤ ដល់ទី ២៣ ខែវិច្ឆិកា ពុទ្ធសករាជ ២៥០៥ គ្រិស្តសករាជ ១៩៦១ ក្រោមព្រះការឧបត្ថម្ភដ៏ខ្ពង់ខ្ពស់នៃសម្តេចសហជីវិន ព្រះប្រមុខរដ្ឋដ៏ឆ្នើម ជាទីស្នេហាស្មើជីវិតនៃយើង ដែលព្រះអង្គទ្រង់ខ្នះខ្នែងពេញលក្ខណៈ ទោះបីប្រទេសកំពុងមានការគំរាមពីបរទេសយ៉ាងណា ក៏ជំនះធ្វើទាល់តែកើតឡើងបានជាមហាសន្និសីទដ៏មហោឡារិក មានរបៀបរៀបរយថ្លៃថ្នូរ ដែលនាំឲ្យសាកលលោកស្គាល់នូវគុណភាពនៃប្រទេសខ្មែររឹតតែច្រើនឡើងៗ ហើយដែលបានទទួលសេចក្ដីសរសើរពីសំណាក់គណៈប្រតិភូទាំង ២៦ ប្រទេស ដែលបានមករួមប្រជុំក្នុងសន្និសីទនេះ ។

សន្និសីទទី ៦ នៃពុទ្ធិកសមាគមពិភពលោក ដែលធ្វើនៅប្រទេសយើងនេះ បានធ្វើសេចក្តីសម្រេចចិត្តចំនួន ២១ ខ ដែលបានចុះផ្សាយក្នុងសារពត៌មានរួចមកហើយស្រាប់ ។

សូមទ្រង់ព្រះមេត្តាប្រោស,

ក្នុងនាមនៃពុទ្ធមាមកជនទាំងអស់ ទូលព្រះបង្គំជាខ្ញុំ សូមទ្រង់ព្រះបរម-ពជានុញ្ញាតទៀតយកឱកាសដ៏ប្រពៃនេះ ដើម្បីថ្លែងជាជូននូវកតញ្ញុតាធម៌ដ៏ជ្រាលជ្រៅចំពោះព្រះមហាករុណាធិគុណនៃសម្តេចព្រះបិតាឯករាជ្យជាតិក្នុងព្រះឋានៈដែលព្រះអង្គមានព្រះរាជហឫទ័យជ្រះថ្លា ចំពោះព្រះពុទ្ធសា-សនា ទ្រង់ព្រះរាជបញ្ជាឲ្យចាត់ការធ្វើសន្និសីទលើកទី ៦ នៃពុទ្ធិកសមា-គមពិភពលោកនៅប្រទេសយើង ដូចបានពណ៌នាមកហើយដោយសង្ខេបនេះ ។ សន្និសីទនេះផ្តល់នូវគុណធម៌ដ៏ប្រសើរដែលជាមូលដ្ឋាននៃព្រះពុទ្ធ-សាសនា ពោលគឺ អហឹសា: ការមិនបៀតបៀនអ្នកដទៃ, មេត្តាធម៌ : ការផ្សាយសេចក្តីរាប់អានទៅរកសព្វសត្វ ករុណាធម៌ : ការផ្សាយសេចក្តីអា-ណិតអាសូរទៅរកសត្វលោក ចំពោះពេលដែលលោកសន្និវាសកំពុងតែបញ្ចេញសូរស័ព្ទសង្គ្រាមត្រជាក់ ប៉ុន្តែក្តៅក្រៃលែងក្តៅ និងជួបប្រទះការពិសោធន៍អាវុធបរមាណូ ដែលជាវត្ថុធាតុល្អិត តែអាចបណ្តាលឲ្យពិភពលោកមានសេចក្តីអន្តរាយយ៉ាងធំក្រៃលែងធំ ។ ទូលព្រះបង្គំជាខ្ញុំយល់ថាមានតែព្រះពុទ្ធសាសនាមួយទេ ដែលប្រដៅឲ្យប្រតិបត្តិធម៌ខាងចេតោ-

និយម ជាសន្តិវប្បធម៌ អាចទម្រុឌទម្រោមនូវ លោភៈ ទោសៈ មោហៈ របស់សត្វលោក ឲ្យទ្រុឌទ្រោម នាំឲ្យពិភពលោកមានសន្តិភាពបាន ។

មុននឹងបញ្ចប់

ក្នុងឋានៈជារដ្ឋលេខាធិការក្រសួងធម្មការ និងសាសនៈសិក្សាធិការ ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានព្រះបរមរាជានុញ្ញាត ដើម្បីថ្លែងនូវការប្រព្រឹត្តិនៃពុទ្ធបរិស័ទខ្លះដូចនេះ ៖

តាមការសង្កេតឃើញសព្វថ្ងៃនេះ ពុទ្ធបរិស័ទខ្មែរយើងមានសេចក្តីប្រឹងប្រែងណាស់ ក្នុងការធ្វើបុណ្យទាន បុណ្យអ្វីក៏ដោយឲ្យតែជាបុណ្យខាងព្រះពុទ្ធសាសនា ពុទ្ធបរិស័ទទាំងប្រទេស ទោះបីមានជីវភាពធុនដាបយ៉ាងណា ក៏ស៊ូប្បូរបរិច្ចាគធនធានយកទៅធ្វើបុណ្យនោះជាដរាប ដើម្បីជំរះចិត្តរបស់ខ្លួនឲ្យបរិសុទ្ធផុតចាកលោភៈ ទោសៈ មោហៈ ឈោងយកសេចក្តីសុខក្នុងលោកនេះ និងលោកខាងមុខ ហើយនិងព្រះនិព្វាន ។

ប៉ុន្តែនៅមានពុទ្ធបរិស័ទខ្លះ ប្រកាន់ពួកក្រុមហួសហេតុពេក ពុំពិចារណាឲ្យដិតដល់សោះ សូម្បីតែបព្វជិតខ្លះជាស្រែបុណ្យ មានស្មៅឬព្រៃស្បាតដុះច្រុបច្រុល ពោលគឺមានមន្ទិលសៅហ្មង ដោយគរុកាបត្តិ ដែលមន្ត្រីសង្ឃស្រុក-ខេត្ត ឬថេរសភាជាន់ខ្ពស់ បានជំនុំជំរះរកទោសកំហុសឃើញពិតប្រាកដ ហើយតម្រូវឲ្យផ្លាស់ភេទចាកបព្វជិតភាពក៏ដោយ ពុទ្ធបរិស័ទខ្លះជាពួកក្រុមនោះ ធ្វើជាមិនដឹងមិនគោរពច្បាប់ពុទ្ធ-

ចក្រ-អាណាចក្រសោះ នៅតែទទួលស្គាល់ថា បព្វជិតនោះបរិសុទ្ធឥតទោសពៃរ៍ ថែមទាំងជួយកាន់ជើងតវ៉ាប្ដឹងផ្ដល់ ដោយអាងសាក្សីទុច្ចរិត ឬមានះរឹងត្អឹងក្រៅគន្លងច្បាប់ ដើម្បីបទ្រាបសេចក្ដីសម្រេចរបស់ជំនុំសង្ឃជាន់ខ្ពស់ឲ្យសាបរលាប ពុំព្រមជួយជំរះស្មៅឬកាប់ឆ្ការព្រៃស្បាតក្នុងស្រែបុណ្យស្មោគគ្រោកនោះ ឲ្យស្អាតបាត ឲ្យមានដីជាតិល្អទុកសម្រាប់សាបព្រួសពូជស្រូវ គឺការផ្ដើមានឲ្យបានផលល្អវិសេសឡើងទៅសោះ ។ ការជួយបិទបាំងទោសកំហុសបែបនេះ ឈ្មោះថាបង្អាប់ព្រះពុទ្ធសាសនាឲ្យអាប់ឱន ព្រោះព្រះពុទ្ធសាសនាដែលនឹងរុងរឿងឬសាបសូន្យ ក៏ព្រោះតែពុទ្ធបរិស័ទនោះផង ។

តែក្រសួងធម្មការសង្ឃឹមថា ក្នុងអនាគតដ៏ខ្លីនេះ ដោយអានុភាពព្រះរាជូបត្ថម្ភនៃសម្ដេចព្រះប្រមុខរដ្ឋ នឹងសម្ដេចព្រះសង្ឃនាយកទាំង ២ ព្រះអង្គ ព្រមទាំងព្រះករុណាគ្រប់ព្រះអង្គ អប់រំពេញលក្ខណៈក៏មុខជាពុទ្ធបរិស័ទខ្មែរទៅក្នុងព្រះរាជអាណាចក្រ នឹងចេះពិចារណារកខុសត្រូវហើយទទួលគោរពច្បាប់ពុទ្ធចក្រ នឹងអាណាចក្រពុំខានឡើយ ។

ក្នុងឋានៈជាពលរដ្ឋខ្មែរ១ រូប ដែលចង់ឲ្យជាតិ សាសនា ព្រះរាជ-បល្លង្ក បានទទួលនូវវឌ្ឍនភាពចំរើនរុងរឿងពេញលក្ខណៈ សមឋានៈជាអារ្យប្រទេស ទូលព្រះបង្គំជាខ្ញុំមានសេចក្ដីរីករាយជាអតិបរមា ដោយឃើញថា ព្រះសង្ឃខ្មែរទាំងឡាយ ដែលឋិតនៅក្នុងព្រះរាជអាណាចក្រក្ដី

ឬដែលបានចេញទៅបន្តសាសនវិជ្ជាឯបរទេសក្តី សឹងបានជ្រាបនិងយល់ច្បាស់នូវគោលនៃហេតុទាំងឡាយ ដែលទូលព្រះបង្គំជាខ្ញុំបានពណ៌នាត្រួស ៗ ខាងដើមនេះហើយ ព្រះសង្ឃដែលគាប់តែជួយស្រោចស្រង់នូវជាតិនិយមខ្មែរគោលគឺ ជាតិ សាសនា ព្រះរាជបល្ល័ង្ក ដែលបានទ្រទ្រង់រៀងរាបដរាបមកនូវអារ្យធម៌ និងវប្បធម៌ខ្មែរ ក៏បានជួយទ្រទ្រង់ដោយកាយវាចាចិត្តពេញសមត្ថភាពនូវ ព្រះរាជបេសកកម្ម និងព្រះរាជនយោបាយដ៏ឆ្នើម នៃសម្តេចព្រះឧបយុវរាជ មាននយោបាយអព្យាក្រឹតជាដើម ព្រោះអព្យាក្រឹតជានយោបាយស្របនឹងមជ្ឈិមាបដិបទា ដែលព្រះសម្ពុទ្ធបរមគ្រូបានត្រាយទុកមក និងព្រះនយោបាយលើកដំកើងជីវភាពពលរដ្ឋ ព្រោះកាលបើពលរដ្ឋដែលជាពុទ្ធសាសនិកមិនសម្បូណ៌សប្បាយខ្ពស់ថ្កើងទេ ព្រះពុទ្ធសាសនាដែលមានព្រះសង្ឃជាតំណាង ក៏ពុំអាចលូតលាស់សមតាមបំណងយើងទាំងអស់គ្នាឡើយ ៗ ព្រោះហេតុនេះ បានជាចក្រទាំងពីរគឺ : ពុទ្ធចក្រ និងអាណាចក្រដែលជាកង់របស់ប្រទេសខ្មែរយើង ត្រូវតែវិលទៅស្មើគ្នា គឺថាត្រូវមានការប្រាស្រ័យគ្នាកាន់តែជិតស្និទ្ធឡើង ទើបអាចជួយបំពេញមុខការ និងប្រយោជន៍ផ្សេង ៗ ដល់គ្នានិងគ្នាទៅវិញទៅមក ឲ្យរីកចំរើន សុខសន្តិភាពពេញលក្ខណៈទៅបាន ៗ

ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ជឿជាក់ចំពោះពុទ្ធភាសិតថា :

ធម្មញ្ចរេ សុចរិតំ ន តំ ទុច្ចរិតំ ចរេ

ធម្មចារី សុខំ សេតិ អស្មឹ លោកេ បរម្ហិ ច

សេចក្តីថា: បុគ្គលគប្បីប្រព្រឹត្តធម៌ឲ្យសុចរិត កុំគប្បីប្រព្រឹត្តធម៌នោះឲ្យទុច្ចរិតឡើយ ព្រោះអ្នកប្រព្រឹត្តធម៌សុចរិត តែងបានសុខទាំងបច្ចុប្បន្ន ទាំងអនាគត ។

អាស្រ័យដោយអានិសង្សនៃធម៌សុចរិត ដែលពុទ្ធបរិស័ទជាតិខ្មែរបានប្រព្រឹត្តកាន់តាមព្រះពុទ្ធសាសនា ជាយូរអង្វែងមកហើយផង ដែលកំពុងប្រព្រឹត្តកាន់តាមក្នុងបច្ចុប្បន្ននេះផង ព្រមទាំងដោយព្រះតេជះបារមីនៃសម្តេចព្រះមហាក្សត្រិយានី ព្រះមាតាជាតិ នឹងសម្តេចសហជីវិនព្រះប្រមុខរដ្ឋ ទ្រង់បានបំពេញលក្ខណៈផង នឹងទ្រង់ប្រព្រឹត្តកាន់តាមព្រះពុទ្ធសាសនាត្រឹមត្រូវផង ប្រទេសកម្ពុជា នឹងពុំជួបប្រទះនូវបុព្វវិន្តរាយអ្វីមួយឡើយ សត្រូវទាំងឡាយ មានពួកក្បត់ឧត្តមប្រយោជន៍នៃជាតិ សាសនា ព្រះរាជបល្ល័ង្កជាដើម មុខជានឹងវិនាសសាបសូន្យគ្មានសេសសល់ ។

ទីបំផុតនេះ ទូលព្រះបង្គំជាខ្ញុំ ក្រោមល្អងធូលីព្រះបាទ សូមប្រសិទ្ធិពរបួងសួងចំពោះគុណព្រះរតនត្រ័យ ព្រមទាំងទេវតាទាំងមុនលោក. ជាតុ សូមជួយអភិបាលរក្សាព្រះពុទ្ធសាសនាព្រមទាំងសម្តេចព្រះមហា. ក្សត្រិយានី ព្រះមាតាជាតិជាអម្ចាស់ជីវិតលើត្បូង នឹងសម្តេចសហជីវិន

ព្រះប្រមុខរដ្ឋ សូមព្រះអង្គគង់នៅជាបរមសុខក្នុងសិរីរាជសម្បត្តិ ដើម្បីជាម្លប់ដ៏ត្រជាក់នៃប្រជាពលរដ្ឋគ្រប់ប្រកែទតទៅ ។

មួយទៀត សូមព្រះករុណាគ្រប់ព្រះអង្គ មានសម្ដេចព្រះសង្ឃនាយកទាំង ២ ព្រះអង្គជាប្រធាន បានប្រកបដោយសេចក្ដីសុខចំរើនគ្រប់ប្រការ ដើម្បីរក្សាព្រះពុទ្ធសាសនាឲ្យបានថ្កុំថ្កើងរុងរឿងរហូតដល់ ៥០០០ វស្សា កុំបីឃ្លៀងឃ្លាត ។

សូមឲ្យអនុសំវច្ឆរមហាសន្និបាតទី ១៨ នៃមន្ត្រីសង្ឃ ប្រកបដោយនូវជោគជ័យកុំបីខានឡើយ ។

× × ×

បន្ទាប់មក ព្រះតេជព្រះគុណ ព្រះគ្រូសិរីសេត្ថា កែវ-សាង វត្តកំផែងអនុគណ ស្រុកបាត់ដំបង បានថ្លែងសុន្ទរកថាមួយ ក្នុងនាមនៃសម្ដេចព្រះសង្ឃនាយកទាំងពីរគណៈ នឹងព្រះសង្ឃក្នុងកម្ពុជរដ្ឋទាំងមូលមានសេចក្ដីដូចតទៅនេះ៖

សូមថ្វាយព្រះពរ សម្ដេចព្រះមហាក្សត្រិយានី ជាម្ចាស់ជីវិត

សូមថ្វាយព្រះពរ សម្ដេចឧបយុវរាជព្រះប្រមុខរដ្ឋ

សូមទ្រង់ជ្រាប ។

ក្នុងនាមនៃមន្ត្រីសង្ឃគ្រប់ឋានៈ ក្នុងព្រះរាជធានីភ្នំពេញ នឹងក្នុងខេត្តក្រៅ ដែលឋិតនៅក្រោមឱវាទនៃសម្ដេចសង្ឃនាយកទាំងពីរគណៈ

ហើយដែលបាននិមន្តមកជួបជុំក្នុងមហាសន្និបាតនេះ អាត្មាភាព សូមថ្វាយនូវព្រះពរ ថ្លែងនូវអំណរព្រះមហាករុណាទិគុណដ៏ខ្ពង់ខ្ពស់បំផុត នៃអង្គសម្តេចព្រះប្រមុខរដ្ឋ ដែលទ្រង់សព្វព្រះរាជហឫទ័យស្តេចយាងមកជាអធិបតី ក្នុងពិធីអនុស្សាវរីយ៍មហាសន្និបាតទី ១៨ នៃមន្ត្រីសង្ឃនេះ ។

សូមថ្វាយព្រះពរ

អម្បាញ់មិញនេះ លោកអ្នកឧកញ៉ារដ្ឋលេខាធិការក្រសួងធម្មការ បានថ្លែងសេចក្តីថ្វាយពត៌មានអំពីវឌ្ឍនភាព នៃព្រះពុទ្ធសាសនា ក្នុងប្រទេសកម្ពុជារួចហើយ ។

ឥឡូវនេះ អាត្មាភាព ជាតំណាងមន្ត្រីសង្ឃទាំងអស់ សូមព្រះរាជទានព្រះរាជឱកាស ដើម្បីថ្វាយពត៌មានខ្លះ អំពីសេចក្តីពេញចិត្ត សេចក្តីរីករាយរបស់សង្ឃ ចំពោះភព្វព័សនានៃប្រទេសកម្ពុជា និងព្រះពុទ្ធសាសនាក្នុងកម្ពុជរដ្ឋទាំងមូល ដោយសង្ខេបដូចតទៅនេះ:

ព្រះសង្ឃទាំងអស់បានដឹងច្បាស់លាស់ណាស់ថា ប្រទេសកម្ពុជា ដែលបានរួចផុតអំពីអំណាចនៃបរទេស ហើយបានទទួលឋានៈជាប្រទេសឯករាជ្យ អព្យាក្រិតគឺដោយសារព្រះរាជសកម្មភាពដ៏អង់អាច និងព្រះរាជឧបាយដ៏ឧត្តមនៃសម្តេចព្រះប្រមុខរដ្ឋ ។ លុះបានដឹងដូច្នេះ ហើយក៏កើតមានចិត្តរីករាយយ៉ាងខ្លាំងក្លា ព្រមទាំងមានគារវភក្តិប្រកបដោយកតញ្ញូតាធម៌យ៉ាងក្រៃលែង ចំពោះអង្គសម្តេចព្រះប្រមុខរដ្ឋ ឥតមានអ្វីនឹង

មកបំបាក់បំបែកបានឡើយ មិនត្រឹមតែប៉ុណ្ណោះ ព្រះសង្ឃទាំងអស់សឹងមានសេចក្ដីសង្ឃឹមកក់ក្ដៅជាទីបំផុត ចំពោះព្រះរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយមបច្ចុប្បន្ន ដែលមានអង្គសម្ដេចព្រះប្រមុខរដ្ឋជាអគ្គនាយកជាអាចនឹងជួយទំនុកបំរុងព្រះពុទ្ធសាសនាឲ្យមានវឌ្ឍនភាពតទៅអនាគត យ៉ាងប្រសើរជាងបច្ចុប្បន្នកាលនេះទៅទៀតពុំខាន ព្រោះព្រះសង្ឃទាំងអស់បានយល់ឃើញថា ព្រះពុទ្ធសាសនាដែលមាននៅក្នុងប្រទេសកម្ពុជាតាំងពីក្នុងពុទ្ធសតវត្សទី ១៣ មករហូតដល់ពុទ្ធសតវត្សទី ២៦ នេះប្រមាណជាងពីរពាន់ឆ្នាំហើយ តែងបានទទួលនូវព្រះបរមរាជូបត្ថម្ភជាដរាបមក ។

ក៏ក្នុងបច្ចុប្បន្នកាលនេះ ព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជា បានទទួលឋានៈជាសាសនារបស់រដ្ឋ នេះជាសក្ដិភាពនៃព្រះបរមរាជូបត្ថម្ភដ៏ខ្ពង់ខ្ពស់បំផុត នាំឲ្យព្រះសង្ឃពុទ្ធសាសនិក មានចិត្តរីករាយជាទីបំផុតឥតមានអ្វីនឹងប្រៀបផ្ទឹមបាន ដោយមានជំនឿថា បើរដ្ឋបានចំរើនរុងរឿងព្រះពុទ្ធសាសនាក៏បានចំរើនរុងរឿងដែរ ព្រោះព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ជាប់នៅជាមួយនឹងរដ្ឋ ។

ដោយហេតុដូច្នេះ បានជាព្រះសង្ឃទាំងអស់ដែលជានិមិត្តរូបនៃព្រះពុទ្ធសាសនា មិនព្រងើយកន្តើយនឹងកិច្ចការរបស់រដ្ឋឡើយ សឹងបានតាំងចិត្តគំនិតរួបរួមជាមួយនឹងព្រះរាជរដ្ឋាភិបាល ហើយជួយបំពេញកិច្ចការគ្រប់យ៉ាង ដែលនាំឲ្យរដ្ឋបានចំរើនរុងរឿងមានការសង់សាលានឹងការ

ដីកស្រះជាដើម វៀរលែងតែកិច្ចការខ្លះដែលផ្ទុយនឹងពុទ្ធវិន័យ ។

សូមថ្វាយព្រះពរ ។

ម្យ៉ាងទៀត ព្រះសង្ឃទាំងអស់ មានចិត្តរីករាយយ៉ាងខ្លាំងចំពោះការសម្រេចនៃសមាជជាតិលើកទី ១២ អំពីបញ្ហាដែលត្រូវបញ្ចូលការសិក្សាខាងព្រះពុទ្ធសាសនាទៅក្នុងការសិក្សាទូទៅ ក្នុងព្រះរាជាណាចក្រ ដោយមានសង្ឃឹមថា យុវជនទាំងឡាយនឹងបានទទួលការសិក្សាខាងព្រះ-ពុទ្ធសាសនាខ្លះៗ ហើយការសិក្សានេះ នឹងទុកជាការអប់រំឲ្យយុវជនខ្មែរមានអនាគតរបស់ខ្លួន អាចស្ថិតនៅក្នុងរង្វង់នៃព្រះពុទ្ធសាសនាបាន ពោះបើយុវជនទាំងនោះ មិនបានទៅជាពុទ្ធសាសនិកក៏ដោយ ក៏គង់បានចេះដឹង បានស្គាល់តម្លៃព្រះពុទ្ធសាសនាខ្លះពុំខាន ។

នៅអវសាននេះ អាត្មាភាពក្នុងនាមនៃព្រះសង្ឃទាំងអស់សូមថ្វាយនូវព្រះពរបវរសួស្តី ជោគជ័យមហាមង្គលវិបុលសុខគ្រប់ប្រការ ចំពោះសម្តេចមហាក្សត្រិយានី ចំពោះសម្តេចព្រះប្រមុខរដ្ឋ សូមទ្រង់បានប្រកបដោយព្រះជន្មវស្សាយឺនយូរ មានព្រះសុខភាពបរិបូណ៌ ឈ្នះអស់មារសត្រូវគ្រប់ទិសទី កុំបីឃ្លៀងឃ្លាតទៅជាបការៈដទៃក្រៅពីនេះឡើយ ។

សូមព្រះពុទ្ធសាសនា នឹងប្រទេសកម្ពុជាបានចំរើនរុងរឿង ។

X

X X

លុះចប់សុន្ទរកថានេះហើយ ព្រះសង្ឃក៏បាន ស្វាធ្យាយធម៌ជយន្តោ ប្រសិទ្ធិពរជ័យ ថ្វាយចំពោះសម្ដេចព្រះមាតាជាតិ និងសម្ដេចព្រះប្រមុខ-រដ្ឋ ដើម្បីជាសុភមង្គលដ៏ប្រសើរចំពោះព្រះអង្គ ។

តមក សម្ដេចព្រះប្រមុខរដ្ឋ បានថ្លែងព្រះសង្ឃថាឥតព្រាងទុកមួយ ក្នុងព្រះបរមនាមនៃសម្ដេចព្រះមាតាជាតិ និងព្រះបរមនាមផ្ទាល់ព្រះអង្គ ថ្លែងអំណរព្រះគុណចំពោះព្រះសង្ឃទាំងអស់ ដែលបាននិមន្តមករួបរួម ធ្វើអនុសំវច្ឆរមហាសន្និបាត ដើម្បីផ្សៀងផ្ទាត់ធម៌វិន័យសម្រាប់ព្រះសង្ឃ និងរំលឹកអំពីការប្រជុំសន្និសីទព្រះពុទ្ធសាសនាពិភពលោក នៅកម្ពុជរដ្ឋ យើង និងបញ្ជាក់អំពីការស្ថាបនាកិច្ចការនានា ជាប្រយោជន៍ជាតិនិងព្រះពុទ្ធសាសនា ដើម្បីស្វែងរកឧត្តមប្រយោជន៍ គុណភាពនិងសេចក្ដីថ្លៃថ្នូរ និងពង្រីកវប្បធម៌ជាតិ ឲ្យជ្រួតជ្រាបដល់ប្រជាពលរដ្ឋគ្រប់ឋានៈទាំងអស់ ក្នុងកម្ពុជរដ្ឋយើង ។ ជាពិសេស ព្រះអង្គបានថ្លែងអំពីនយោបាយក្នុងប្រទេស និងក្រៅប្រទេស ព្រមទាំងអធិប្បាយអំពីសារពត៌មានបរទេសនានា ដែលបានអធិប្បាយអំពីគុណភាពនៃប្រទេសកម្ពុជាយើង ។

លុះចប់ព្រះរាជសន្ទ្ថា ដ៏មានខ្លឹមសារនេះហើយ សម្ដេចព្រះមហា-ក្សត្រិយានី និងសម្ដេចព្រះប្រមុខរដ្ឋ ក៏បានក្រាបថ្វាយបង្គំលាព្រះសង្ឃ ទាំងអស់ ដែលមានសម្ដេចព្រះសង្ឃនាយកទាំងពីរគណៈ ជាប្រធាន ហើយដោយមានព្រះរាជបរិពារដែលដង្ហែអមផង បានស្ដេចយាងនិវត្តន៍

ចូលព្រះបរមរាជវាំង ដោយមានការធ្វើការកិច្ចថ្វាយជាព្រះរាជកិត្តិយស ដូចកាលស្តេចយាងមកដល់ដែរ ។

ពិធីអនុស្សាវរីយមហាសន្និបាតលើកទី ១៨ នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត បានចប់សព្វគ្រប់នៅវេលាម៉ោង ៨ និង ៣០ នាទី ក្រោយពេលដែលព្រះសង្ឃ បានទទួលភេសជ្ជៈរួច ។

ចាប់ពីថ្ងៃទី ២២ រហូតដល់ថ្ងៃទី ២៤ មករា ១៩៦២ តទៅ ព្រះសង្ឃ ទាំង ២ គណៈ ប្រជុំនៅវត្តទុណ្ណាលោម និងវត្តបទុមវតីរាជវរារាម ក្រោមអធិបតីភាពនៃសម្តេចព្រះសង្ឃនាយកតាមគណៈ ទីងតាមកម្មវិធី ដែលសម្តេចទាំងពីរគណៈចាត់ធ្វើ ។

នៅវេលារសៀលនៃថ្ងៃទី ២៤ មករា ១៩៦២, នៅមន្ទីរសង្ឃពេទ្យ កុសុមៈ កងសង្កាត់លេខ ៣ ក្រុងភ្នំពេញ មានធ្វើមហាសន្និបាតមួយ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ នៃសម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង ។

ចាប់តាំងពីម៉ោង ៤រសៀលទៅ, នៅទីប្រជុំ គេបានសង្កេតឃើញ ជាអាទិ៍គឺ សម្តេចព្រះសង្ឃនាយកទាំងពីរគណៈ រាជាគណៈឋានានុក្រមគណ អនុគណគ្រប់ខេត្ត ចៅអធិការកុងក្រុងនិងខេត្តក្រៅខ្លះ ព្រមទាំងភិក្ខុសាមណេរជាច្រើនរយអង្គទៀត ។

ផ្នែកគ្រហស្ថ សហជីវិន ទេព-ផន ព្រះរាជប្រតិភូប្រចាំក្រុងភ្នំពេញ

សហជីវិន ស៊ិន.បុប្ផកោ រដ្ឋលេខាធិការក្រសួងធម្មការ សហជីវិន ប៉េ-កេងហ៊ាន នាយខុទ្ទកាល័យជាជំណាងលោករដ្ឋមន្ត្រីក្រសួងសាធារណ-សុខាភិបាល សហជីវិន កំយ.លុត អធិបតីនៃសមាគម សហជីវិន គុង-គកចាងហ្វាងគយ សហជីវិន ទេព-យុត ហិរញ្ញិកនៃសមាគម និងសមាជិកសមាជិកានៃសមាគមព្រមទាំងឧបាសក ឧបាសិកាជាច្រើនរូបទៀត ។

នៅវេលាម៉ោង ៩ និង ១៥ នាទី សម្តេចព្រះមាតាជាតិ ដោយមានសម្តេចក្រុមព្រះ ស៊ីសុវត្ថិ- មុនីរេត ប្រធានឧត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក ឯកឧត្តម ផូ.ព្រឿង ឯកឧត្តមពិទូដឺម៉ុងតេរូ អនុប្រធានសមាជិកឧត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក លោកឧកញ៉ា ឆេង.ហាក់ ចាងហ្វាងរដ្ឋ-បាល ក្នុងព្រះបរមរាជវាំង លោកវរសេនីយ៍ទោ សរ.ហោ ព្រះរាជអង្គរក្ស ព្រមទាំងព្រះរាជបរិវារផ្ទាល់ព្រះអង្គ ជាច្រើនទៀតដង្ហែព្រះអង្គផង បានស្តេចយាងដល់មន្ទីរសង្ឃពេទ្យកុសុមៈ ដែលក្នុងខណៈនោះ ក្រុមទាហានរក្សាព្រះអង្គ និងក្រុមទាហានក្មេង បានថ្វាយគារវៈកិច្ចលើកអាវុធបទ្វីបទក្មេងជាព្រះរាជកិត្តិយស ។ នៅពេលចុះពីព្រះទីនាំងរថយន្ត សម្តេចព្រះមាតាជាតិ ទ្រង់បានទទួលការក្រាបថ្វាយបង្គំពីលោក ឃួន-ណៃ អធិបតីសមាគម សហជីវិន ទេព-ផុន សហជីវិន ស៊ិន.បុប្ផកោ និងសមាជិកសមា-ជិកាសមាគមដទៃទៀត ហើយពិធីគោរពក្មេងជាតិក៏ចាប់ផ្តើមឡើង ។ តមក សម្តេចព្រះមាតាជាតិ ស្តេចយាងចូលក្នុងឧបដ្ឋានសាលា ថ្វាយបង្គំ

ព្រះសង្ឃ ដែលមានសម្តេចព្រះសង្ឃនាយកទាំងពីរគណៈជាប្រធាន ។

ក្រោយដែលសម្តេចព្រះមាតាជាតិ ទ្រង់គង់ប្រថាប់លើព្រះសុវណ្ណ-កោដ្ឋៈរួចហើយ , លោកអធិបតីនៃសមាគមតិលានុបដ្ឋានព្រះមហាក្សត្រិ-យានីបានថ្លែងសុន្ទរកថាមួយ រៀបរាប់អំពីដំណើរការលូតលាស់នៃសមា-គមនេះ ដែលជាពិសេសគឺអំពីប្រាក់ចំណូលនឹងចំណាយក្នុងឆ្នាំ ១៩៦១ នឹងការគ្រោងទុកក្នុងឆ្នាំ ១៩៦២ តទៅទៀត ។

លុះចប់សុន្ទរកថា នៃលោកអធិបតីសមាគមហើយ សម្តេចព្រះមាតាជាតិ ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យថ្លែងនូវព្រះសង្កថាមួយដូចតទៅនេះ ៖

ខ្ញុំព្រះករុណា សូមនមស្ការសម្តេចព្រះសង្ឃនាយកទាំងពីរគណៈដោយគោរព !

ព្រមទាំងព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ !

មួយអន្លើនឹងពលរដ្ឋជាកូនចៅ ដែលមានគណៈកម្មាធិការជាដើម ។

ខ្ញុំព្រះករុណា - ខ្ញុំ សូមសំដែងនូវសេចក្តីអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះពរស្វាគមន៍របស់អធិបតី នៃសមាគមតិលានុបដ្ឋាន ព្រះ-មហាក្សត្រិយានី ដែលបានថ្វាយចំពោះខ្ញុំ ។

ខ្ញុំព្រះករុណា - ខ្ញុំ មានហឫទ័យសោមនស្សជាពន់ពេក ដោយមានកិត្តិយសមកជាអធិបតី ក្នុងមហាសន្និបាតនេះ ។

ដោយបានជ្រាប នូវសេចក្តីថ្លែងការពីសីលធម៌និងហិរញ្ញវត្ថុ ដែលបានចំរើនលូតលាស់ក្នុងឆ្នាំ ១៩៦១ កន្លងទៅ ឃើញថា មានលទ្ធផលប្រសើរជាទីពេក ។ ខ្ញុំព្រះករុណា-ខ្ញុំ មានសេចក្តីសង្ឃឹមយ៉ាងមាំថា : តទៅអនាគត កិច្ចការដ៏ប្រពៃដែលបំរុងនឹងធ្វើតទៅនេះ នឹងចំរើនជាកិយេ្យភាព ដោយស្នាដៃយ៉ាងចំណាន របស់គណៈកម្មាធិការដែលមានឯកឧត្តម ឃួន-ណៃ ជាប្រធាន ។

ជាអវសាន ខ្ញុំព្រះករុណា-ខ្ញុំ សូមប្រគេនជូនពរស័ព្ទសាធុការ សូមព្រះអង្គនិងកូនចៅ បានប្រកបដោយសេចក្តីសុខ-ចំរើនគ្រប់ប្រការកុំបីឃ្លាត ។

លុះចប់ព្រះសង្កថានេះហើយ ព្រះសង្ឃក៏ចាប់ស្វាធ្យាយធម៌ជយន្តោ ថ្វាយចំពោះព្រះអង្គ ។

នៅវេលាម៉ោង ៩ និង ៤៥ នាទី បន្ទាប់ពីទ្រង់បានថ្លែងនូវព្រះសង្ក-ថាចប់ហើយ សម្តេចព្រះមាតាជាតិ ដោយមានព្រះរាជបរិពារដែលតាមហែផង បានថ្វាយបង្គំសម្តេចព្រះសង្ឃនាយកទាំងពីរព្រះអង្គ ព្រមទាំងព្រះសង្ឃ និងលាឧបាសក ឧបាសិកា ជាកូនចៅព្រះអង្គ យាងត្រឡប់មកព្រះបរមរាជវាំងវិញ ដោយមានក្រុមទាហានបានថ្វាយគារវកិច្ច ដូចកាលស្តេចយាងមកដល់ដែរ ។

បន្ទាប់មក សមាជិកសមាជិកានៃសមាគម ទាំងព្រះសង្ឃ ទាំង

គ្រហស្ថ កំបានបន្តកិច្ចធ្វើមហាសន្និបាតសាមញ្ញ ដូចដែលធ្លាប់បានធ្វើជារៀងរាល់ឆ្នាំមក ។

ម្យ៉ាងទៀត ក្នុងពេលប្រជុំធ្វើអនុសំវច្ឆរមហាសន្និបាតទី ១៨ នៃមន្ត្រីសង្ឃ ពីថ្ងៃ២០ ដល់ថ្ងៃទី ២៥ មករា ឆ្នាំ ១៩៦២ នេះ, នៅវត្តឧណ្ណាលោម មហាសន្និបាតនៃមន្ត្រីសង្ឃ បានធ្វើសេចក្ដីសម្រេចចិត្តមួយ មាន ១៩ ខ ដូចតទៅនេះ ៖

១- សេចក្ដីព្រាងករណីយកិច្ច នៃលោកចៅអធិការ អនុគណ.មេគណ ។

បកតាមសេចក្ដីព្រាងទាំងស្រុករបស់គណៈកម្មការ ដែលបានតែងតាំងឡើងតាមលិខិតបង្គាប់ការក្រសួងធម្មការលេខ ១៩ ក-ធ- និង លេខ ៩៣ ក.ធ- ចុះថ្ងៃទី ១៦ កុម្ភៈ និងថ្ងៃទី ២២ សីហា ១៩៦១ ។

២- លោករដ្ឋលេខាធិការ ក្រសួងធម្មការ ស្នើសុំឲ្យភិក្ខុសាមណេរ ដើរអើតើតតាមផ្លូវផ្សារដូចគ្រហស្ថ ដោយធ្លាប់បានឃើញពេលម៉ោង ៩ ឬ ១០ យប់ ។

រឿងនេះ ត្រូវធ្វើការអប់រំផង ត្រូវប្រគល់ការៈទៅសម្ដេចព្រះសង្ឃនាយកទាំងពីរគណៈ និងរដ្ឋមន្ត្រីក្រសួងធម្មការ ចាត់ការធ្វើព្រះសង្ឃប្បញ្ញត្តិផង ។

៣- ព្រះតេជគុណ កឹម-គួរ វត្តឧណ្ណាលោម ស្នើសុំគ្រងបញ្ចប់

អនុមោទនាយថា ខានចុនត្រន់ អាយុ វណ្ណា សុខំ ពលំ ។

មហាសន្និបាតសម្រេចថា :

យកតាមរបៀបវត្ត កុនក្រុនក្នុពេញ ដែលព្រះសង្ឃនាយកគណៈ

មហានិកាយ បានបង្ហាត់តាលពីពេលមុនបុណ្យ ២៥០០ វស្សា ។

៤- ព្រះឥន្ទមុនី សេខ-នាង វត្តខុណ្ណលោម ស្នើសុំឲ្យវត្ត

នីមួយៗ ធ្វើវប្បកុដិ ឲ្យសមរម្យតាមអនាម័យ ។

មហាសន្និបាតសម្រេចថា :

យល់ព្រមធ្វើវប្បកុដិ តាមសេចក្តីស្នើតាំងស្រេច របស់ព្រះឥន្ទមុនី

សេខ - នាង ។

កុនពេលពិភាក្សារឿងនេះ មានលោកអ្នកមានសទ្ធា ២ រូប គឺ

គហបតី បេ - យ៉ាន នឹង លី - ស៊ុន - ង៉ួន បានទទួលពប់រង ជួយប្រ-

គេនប្រដាប់បង្គន់ តាមសម័យនិយមខ្លះ ដែលអាចជួយបាន ។

៥- អនុគណស្រុកបាត់ដំបង ខែត្របាត់ដំបង ស្នើសុំ ៤ ខ:

ក- អំពីភិក្ខុសាមណេរខ្លះ ធ្វើដំណើរតាមរថភ្លើងជាដើម មាន

សណ្តាប់ធ្នាប់ពុំសមរម្យ ។

ខ- អំពីភិក្ខុសាមណេរខ្លះ មានវិទ្យុស្ពាយបើកសំឡេង តាមភូមិ

អ្នកស្រុក ។

គ- អំពីលោកអាចារ្យបង្រៀនសាលាពុទ្ធិកបឋមសិក្សា នឹងលោក

ទៅអធិការវត្ត ទេះតែមានការខ្វែងយោបល់គ្នា ។

ឃ- អំពីរឿងរៀនកម្មដ្ឋាន ដោយគ្រូនិងគ្រូ សិស្សនិងសិស្ស មិនត្រូវគ្នា ។

មហាសន្និបាតសម្រេចថា:

ត្រង់ ក និង ខ ត្រូវធ្វើការអប់រំ ព្រោះមានក្នុងករណីយកិច្ចនៃលោកទៅអធិការ អនុគណ មេគណស្រាប់ហើយ ។

ត្រង់ គ ព្រះពោធិវង្សជាអគ្គាធិការនៃពុទ្ធិកសិក្សាបានពន្យល់ឲ្យស្តាប់បានហើយ, ត្រូវអនុវត្តតាមបទបញ្ជាសម្រាប់សាលាពុទ្ធិកបឋមសិក្សា ។

ត្រង់ ឃ ត្រូវសុំឲ្យក្រសួងធម្មការ តាំងគណៈកម្មការមួយក្រុមពិនិត្យរៀបចំគ្រូបង្រៀនកម្មដ្ឋាន ឲ្យបានត្រឹមត្រូវតាមច្បាប់ព្រះពុទ្ធសាសនា ។

៦- មេគណខេត្តស្វាយរៀង ស្នើសុំឲ្យពង្រីកវិបស្សនាធុរៈឲ្យមានក្នុងព្រះរាជអាណាចក្រ ។

មហាសន្និបាតសម្រេចថា:

មុននឹងពង្រីកវិបស្សនាធុរៈ ត្រូវចាត់ការរៀបចំរបៀបបង្រៀនកម្មដ្ឋានឲ្យបានត្រឹមត្រូវសិន ចាំពង្រីកជាខាងក្រោយ ។ ចំពោះទីកន្លែងរៀនកម្មដ្ឋាន ឬ វិបស្សនាធុរៈ ត្រូវរៀបចំកន្លែងរៀនក្នុងវត្តមួយ ១ ប្រសិនបើត្រូវការ មិនចាំបាច់រៀបចំកន្លែងដទៃទេ ។

៧- ព្រះវិន័យធរ អ៊ុម . ស៊ុម វត្តសាកលនៈស្នើសុំ ៤ ខ:

ក- សុំបំបាត់ពាក្យថា កេរ្តិ៍មតកគ្រូ,

ខ- សុំឲ្យផ្តាំផ្ញើកិច្ចការវត្តចំពោះសង្ឃ,

គ- សុំឲ្យធ្វើសាវតារសម្រាប់វត្ត,

ឃ- ស្ថាបនកម្មទាំងអស់ មុននឹងធ្វើសុំឲ្យសង្ឃសំដែងទិឲ្យសិន ។

មហាសន្និបាតសម្រេចថា:

ត្រង់ ក.ខ នឹង ឃ មានក្នុងព្រះវិន័យស្រាប់ ហើយជាករណីយកិច្ចរបស់ក្រសួងព្រះសង្ឃនាយក ត្រូវរៀបចំធ្វើព្រះសង្ឃប្រកាស ។

ត្រង់ គ សាវតារវត្ត ត្រូវតែធ្វើទុកសម្រាប់វត្ត ។

៨- ព្រះអាចារ្យ ខៀវ-ជុំ វត្តលង្កា ស្នើពីការបញ្ចូលពុទ្ធសាសនាទៅក្នុងសាលាសិក្សាយុវជនកុមារ ។

មហាសន្និបាតសម្រេចថា:

បញ្ហានេះ ទាក់ទងនឹងរាជរដ្ឋាភិបាល ហើយរដ្ឋាភិបាលបានសម្រេចរួចហើយ តាំងពីក្នុងកាលនៃសមាជទី ១២, ដូច្នេះ មហាសន្និបាតនៃមន្ត្រីសង្ឃនេះ មិនចាំបាច់យកមកពិចារណាទៀតទេ ។

៩- ព្រះវិនយ័ មេគណខែត្របាត់ដំបង ស្នើសុំឲ្យបន្ថែមការអប់រំពួកពុទ្ធិកជន ទាំងបព្វជិតទាំងគ្រហស្ថ ។

មហាសន្និបាតសម្រេចថា :

ត្រូវអនុវត្តតាមករណីយកិច្ចនៃចៅអធិការ អនុគណ មេគណ ។

១០- មេគណខែត្រតាកែវ ស្នើសុំឲ្យរាជការមានសមត្ថកិច្ចជួយរកមធ្យោបាយ បង្កើតពុទ្ធិកវិទ្យាល័យឲ្យបានគ្រប់ខែត្រ ។

មហាសន្និបាតសម្រេចថា:

បញ្ហានេះ ត្រូវសូមឲ្យរាជរដ្ឋាភិបាល បង្កើតពុទ្ធិកវិទ្យាល័យនៅខែត្រណា ដែលអាចបង្កើតបានមុនគេ ហើយចេះតែបង្កើត តទៅទៀតឲ្យបានគ្រប់ខែត្រ ប្រសិនបើអាច ។

១១- មេគណខែត្រកោះកុងស្នើសុំ ២ ខ:

ក- សុំឲ្យរាជរដ្ឋាភិបាល នឹងសមាគមពុទ្ធសាសនា ជួយបង្កើតសាលាពុទ្ធិកបឋមសិក្សា ជួយផ្តល់សិក្ខូបករណ៍ផ្សេងៗ ជួយតាក់អាចារ្យបង្រៀនធម្មវិន័យ នឹងបង្រៀនបាលី នៅខែត្រកោះកុងតាមផ្ទវការ ។

ខ- សុំឲ្យព្រះសង្ឃខែត្រកោះកុង មានសិទ្ធិចូលមករៀននៅពុទ្ធិក-វិទ្យាល័យព្រះសុរាម្រិតបាន មិនបាច់ប្រឡងប្រជែង បើមានវិញ្ញាបនបត្រពុទ្ធិកសិក្សាហើយ ហើយឲ្យសម្ដេច ព្រះរាជាគណ:ឋានានុក្រម មេត្តាជួយទទួលព្រះសង្ឃខែត្រកោះកុងឲ្យស់ណាក់អាស្រ័យដោយអនុគ្រោះ ។

១២- មេគណខែត្រកំពង់ឆ្នាំងស្នើ ៤ ខ:

ក- អំពីបញ្ហារកមធ្យោបាយបំបាត់អធិករណ៍

ខ- សុំឲ្យក្រសួងធម្មការ បង្កើតការអប់រំវិជ្ជាគរុកោសល្យ ដល់អាចារ្យបង្រៀនក្នុងសាលាធម្មវិន័យកល់ឆ្នាំ,

គ- សុំឲ្យរដ្ឋាភិបាល ជួយរកមធ្យោបាយឲ្យយុវជនអនាគតបាន ចូលបួសមុននឹងចូលកាន់មុខដំណែងរាជការ,

ឃ- សុំឲ្យក្រសួងធម្មការ ជួយរកមធ្យោបាយឲ្យលោកអាចារ្យ ដែលបង្ហាត់បង្រៀនក្នុងសាលាពុទ្ធិកបឋមសិក្សានីមួយ ៗ ឲ្យបានយ៉ាងតិចបំផុតត្រឹម ៦ ឆ្នាំ ។

មហាសន្និបាតសម្រេចថា :

ត្រង់ក- បានសម្រេចពីក្នុងអនុសំវច្ឆរមហាសន្និបាតទី ១៧ រួចហើយ,

ត្រង់ ខ- ត្រូវតាំងគណៈកម្មការមួយក្រុម សម្រាប់ត្រួតត្រាសាលាធម្មវិន័យសិន ។

ត្រង់ គ- ស្រេចនៅលើចិត្តរបស់យុវជន ព្រោះព្រះពុទ្ធសាសនាគ្មានបង្ខំទេ,

ត្រង់ ឃ- ត្រូវបង្កើតសមាគមគ្រប់ខេត្ត ដែលមានមូលដ្ឋានតែមួយនៅក្រុងភ្នំពេញ ដើម្បីជួយឧបត្ថម្ភលោកអាចារ្យបង្រៀនសាលាពុទ្ធិកបឋមសិក្សា ហើយសុំរដ្ឋាភិបាលជួយឧបត្ថម្ភសមាគមនេះផង ។

១៣- ព្រះវិន័យធរជាអនុគណស្តីទីខេត្តកំពតស្នើសុំ ៣ ខ:

ក- បញ្ហាលំបាកចំពោះសិស្សពុទ្ធិកបឋមសិក្សារៀនមិនចប់ឆ្នាំ ,

ខ- បញ្ហាពិបាករកអាចារ្យ,

គ- បញ្ហាវិញ្ញាសា ប្រឡងចេញពីពុទ្ធិកបឋមសិក្សា ។

មហាសន្និបាតសម្រេចថា :

ត្រង់ក. ជាការៈរបស់មេគណ អនុគណ ដែលជាអធិការខែត្រ អធិការស្រុក ពិនិត្យត្រួតត្រាឲ្យម៉ត់ចត់ ,

ត្រង់ខ. ស្រេចលើលោកចៅអធិការជាម្ចាស់សាលា ត្រូវគិតរកអាចារ្យដោយខ្លួនឯង

ត្រង់គ. ជាការៈក្រសួងធម្មការ ទីងអគ្គាធិការដ្ឋាននៃពុទ្ធិកសិក្សាចាត់ការ ។

១៤- មេគណខែត្រក្រចេះ ស្នើសុំឲ្យសង្ឃមហាសន្និបាតរិះរកមធ្យោបាយបញ្ហាឲ្យគឹងរឹងទៅលើចៅអធិការវត្តខ្លះ ដែលមិនព្រមប្រតិបត្តិតាមព្រះត្រៃបិដក តាមព្រះសង្ឃប្រកាសនិងតាមសាកលបរផ្សេង ។ ។

មហាសន្និបាតសម្រេចថា :

រឿងនេះ មិនត្រូវធ្វើសង្ឃប្រកាសបញ្ហាឲ្យតឹងរឹងទៅទៀតទេ ព្រោះមានព្រះសង្ឃប្រកាសនិងព្រះរាជក្រមនៅជាធរមាននៅឡើយ គ្រាន់តែអនុវត្តន៍ឲ្យសមគួរ តាមកាលៈទេសៈប៉ុណ្ណោះបានហើយ ។

១៥- មេគណខែត្រកំពង់ស្ពឺស្នើសុំ ២ ខ:

ក- សុំគ្រប់សាលាធម្មវិន័យ ធ្វើបំពិតបកខែត្រ បញ្ជូនទៅសាលាអនុគណ មេគណ ។

១- អគ្គការដែលមន្ត្រីសង្ឃ បានសម្រេចជាឯកច្ឆន្ទ ក៏ងអនុសាវរីយ៍ -

មហាសន្និបាតហើយ បើបព្វជិតរូបណាមិនប្រតិបត្តិតាម សុំឲ្យលោកគ្រូអនុគណធ្វើសេចក្តីរាយការណ៍ អំពីបព្វជិតរូបនោះ ប្រគេនទៅក្រសួងព្រះសង្ឃនាយក ដើម្បីវិនិច្ឆ័យតាមដំណើរការណ៍ ។

មហាសន្និបាតសម្រេចថា:

ត្រង់ក- ត្រូវតែធ្វើ ប៉ុន្តែនេះជាករណីយកិច្ចរបស់មេគណ អនុគណ ចាត់ការ ,

ត្រង់ខ- ជាភារៈលើមេគណ អនុគណ ធ្វើសេចក្តីរាយការណ៍ជូនទៅក្រសួងព្រះសង្ឃនាយក តាមរយៈក្រសួងធម្មការដើម្បីចាត់ការតទៅ ។

១៦- ព្រះមុនីកោសល សួរ-ហាយ ស្នើសុំឲ្យបំបាត់ ពាក្យថា " ប្រាក់សន្តត់ត្រៃ "

មហាសន្និបាតសម្រេចថាះ

ត្រូវបំបាត់ពាក្យថា " ប្រាក់សន្តត់ត្រៃ " ដោយយកពាក្យថា "បច្ច័យលទ្ធផលកឋិន" ប្រើជំនួសវិញ ហើយកុំឲ្យលោកចៅអធិការទុកប្រាក់កឋិននោះដោយខ្លួនឯង គឺត្រូវប្រគល់ឲ្យគណៈកម្មការវត្តទុកដាក់ ។

១៧- មេគណខេត្តស្ទឹងត្រែងនឹងរតនគិរី ស្នើសុំឲ្យបញ្ចូលវិជ្ជាផ្លូវលោក មានគណិតសាស្ត្រជាដើម ទៅក្នុងសាលាធម្មវិន័យ ។

មហាសន្និបាតសម្រេចថា :

អាចបញ្ចូលបានតាមសេចក្តីត្រូវការ ប៉ុន្តែ មិនត្រូវតែប្រែកម្មវិធីប្រឡងឡើយ ។

១៨- អនុគណស្រុកមុខកំពូល ស្នើសុំកុំឲ្យមេគណ អនុគណ ទីងទៅអធិការគ្រប់វត្ត ទទួលស្គាល់គ្រូវិជ្ជាទដែលមានវិទ្យាយប័ត្រថេរសកាសម្រេចជ្រះស្រឡះហើយ ។

មហាសន្និបាតសម្រេចថា:

មិនអាចសម្រេចបានទេ, ក្នុងកាលៈទេសៈនេះ ។

១៩- អនុគណស្រុកកំពង់សៀមស្នើសុំ ៣ ខ:

ក- សុំឲ្យដាក់បទបញ្ញត្តិឲ្យបានតឹងរឹងទៅលើរូបចៅអធិការដែលពុំព្រមចូលទៅកាន់ទីប្រជុំអនុសំវច្ឆរមហាសន្និបាតតាមសាលាអនុគណ ។

ខ- បើចៅអធិការណាមានអាពាធ ឬចាស់ជរាពុំអាចចូលទៅកាន់ទីប្រជុំបានទេ ដោយមានសេចក្ដីបញ្ជាក់គ្រប់គ្រាន់ហើយ ចៅអធិការនោះត្រូវចាត់ឲ្យគ្រូសូត្រស្ដាំ ឬលោកដែលមានសមត្ថភាពទៅប្រជុំជំនួសខ្លួន ។

គ- បើលោកចៅអធិការរូបណា ខានចូលកាន់ប្រជុំអនុសំវច្ឆរមហាសន្និបាត នៅសាលាអនុគណគ្រប់កំណត់ ៣ ដង ត្រូវឲ្យចៅអធិការនោះលាចេញពីដំណែង ។

មហាសន្និបាតសម្រេចថា:

សេចក្ដីស្នើសុំទាំង ៣ ខនេះ សូមទុកជាភារៈលើសម្ដេចព្រះសង្ឃនាយកសម្រេចក្នុងពេលខាងមុខ ។

---